# អដ្ឋកថា ទីឃនិកាយ

## នៃព្រះសុត្តន្តបិដក

# ឈ្មោះ សុមង្គលវិលាសិនី

## សីលក្ខន្ធវគ្គ ទុតិយភាគ

## ភាគ ១៥

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ទីឃនិកាយ ទុតិយភាគ

## នៃព្រះសុត្តន្តបិដក

## សីលក្ខន្ធវគ្គ

## ភាគ ១៥

ឈ្មោះ

# សុមង្គលវិលាសិនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

កូដទន្ត.មហាលិ.ជាលិយ.មហាសីហនាទ.ពោដ្ឋបាទ.សុភ.កេវដ្ដ.លោហិច្ច.តេវិជ្ជ

A

# ស្រៈនិស្ស័យ

## *Signes et accents:*



B

ស្រះពេញតួ

*Voyelles:*



# ព្យញ្ជនៈ

# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

D


Cambodgien
Romain
c ch j jh ñ
Siamois
Laotien
Cinghalais
Birman

## E

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូប Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฎ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ | ទ្ទ | ធ្ធ | ន្ន |
| រ៉ូម Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ຕ | ຖ | ທ | ຘ | ນ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

G

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| [illegible] Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຠ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

H



# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមាន គាថា និងពុទ្ធវចនៈ ដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

***វេទល្ល*** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដីរីករាយ និងសួរជាបន្ត ៗ ទៅ ។

*ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖*

***ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាមឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែលបណ្ឌិតគប្បីដឹងបាន ។***

*ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញុំាងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។*

*ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖*

***១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង*** *ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។*

***២ ទ្រង់សម្ដែងធម៌មានហេតុផល*** *ដែលអ្នកស្ដាប់អាចពិចារណាឃើញតាម*

សេចក្តីពិតបាន ។

**៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់ បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

**១ ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-

បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

**២ សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់

ដល់ច្បាប់វេជ្ជធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ   ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ  សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌   ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកបា្បដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះ ធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្ញាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។
២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។
៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។
៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។
៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។
៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។
៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។
៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ពានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថាឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកប្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត ( ឈ្មោះដូចអគ្គសាវក ) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធ-ទត្តត្ថេរៈ ដែលបាននិមន្តជួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ១៖ ( សិរិកុថៈ ) ១៖ ( សិរិកូដ្ឋៈ ) ១៖ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀង ផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែល មានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោក រចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈ បានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយ បទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបាន សាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញ សេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បាន ប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោស:និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ: ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទួន ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់ ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ ឧបាសិកា ពូ ហ៊ាង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

ព្រះភិក្ខុបវរធម្មោ អ៊ុល សុធា សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទួន ឧបាសក ហុក សឹងហួត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **អដ្ឋកថា កូដទន្តសូត្រ ទី៥** | |
| រឿង កូដទន្តព្រាហ្មណ៍ | ១ |
| បរិក្ខារបួន | ១០ |
| និច្ចទាន | ២៣ |
| ការសម្ដែងខ្លួនជាឧបាសក | ៣៧ |
| **អដ្ឋកថា មហាលិសូត្រ ទី៦** | |
| ព្រាហ្មណទូតវត្ថុ | ៣៩ |
| ចតុអរិយផល | ៤៧ |
| អរិយដ្ឋង្គិកមគ្គ | ៥០ |
| រឿងបព្វជិត ២ រូប | ៥៦ |
| **អដ្ឋកថា ជាលិយសូត្រ ទី៧** | |
| ជាលិយសូត្រ | ៥៨ |
| **អដ្ឋកថា មហាសីហនាទសូត្រ ទី៨** | |
| ពោលអំពីអាចេលកស្សបៈ | ៦៦ |
| ការសាកសួរ | ៧៣ |
| មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ | ៧៧ |
| ការផ្ដើមនូវតបៈ | ៧៨ |
| ការព្យាយាមបំពេញតបៈ | ៨៦ |

សម្បទា ៣ យ៉ាង ៨៨
សីហនាទក្នុងបរិស័ទ ៩០
តិត្ថិយបរិវាស ៩៧

## អដ្ឋកថា ចោដ្ឋបាទសូត្រ ទី៩

រឿង ពោដ្ឋបាទបរិញ្វជក ១០៣
អភិសញ្ញានិរោធ ១១២
អហេតុកសញ្ញុប្បាទនិរោធ ១១៨
អត្តសញ្ញា ១៣០
ចិត្ត កូនទ្រមាក់ដ៏រី ១៣៧
ឯកំសិកធម្ម ១៤០
ការបានអត្តភាព ១៤២

## អដ្ឋកថា សុភសូត្រ ទី១០

រឿង សុភមាណព ១៥១
សីលក្ខន្ធ ១៥៨
សមាធិខន្ធ ១៥៩

## អដ្ឋកថា កេវដ្តសូត្រ ទី១១

រឿង កេវដ្តគហបតិបុត្ត ១៦១
ឥទ្ធិបាដិហារ ១៦៤
អាទេសនាបាដិហារ ១៦៥
អនុសាសនីបាដិហារ ១៦៦
ភូតនិរោធសកវត្ថុ ១៦៩

## អដ្ឋកថា លោហិច្ចសូត្រ ទី ១២


លោហិច្ចសូត្រ ១៧៧

រឿង លោហិច្ចព្រាហ្មណ៍ ១៨១

ការចោទបីប្រការ ១៨៤

សាស្តាមិនគួរចោទ ១៨៧


## អដ្ឋកថា តេវិជ្ជសូត្រ ទី ១៣


តេវិជ្ជសូត្រ ១៨៨

ឧបមាអំពីស្ទឹងអចិរវតី ១៩៧

# អដ្ឋកថា សុត្តន្តបិដក

# ឈ្មោះ សុមង្គលវិលាសិនី

# អដ្ឋកថា ទីឃនិកាយ

# លេខ ១៥

## កូដទន្តសូត្រទី ៥

[១] កូដទន្តសូត្រមានបាលីចាប់ផ្ដើមថា ឯវម្មេ សុតំ ។ល។ មគធេសូតិ កូដទន្តសុត្តំ ។

ក្នុងកូដទន្តសូត្រនោះ មានការពណ៌នាតាមលំដាប់បទ ដូចតទៅនេះ ៖

បទថា **ក្នុងមគធជនបទ** សេចក្ដីថា រាជកុមារទាំងឡាយ អ្នកមានប្រក្រតីនៅក្នុងជនបទ មានឈ្មោះថា មគធជនបទ សូម្បីជនបទតែមួយដែលជាទីនៅរបស់រាជកុមារពួកនោះ លោកហៅថា មគធា ដោយសព្ទដែលបន្ថែមចូលមក ។ ក្នុងជនបទ ក្នុងដែនមគធនោះ ខាងមុខពីនេះទៅមានន័យដូចពោលហើយ ក្នុងសូត្រទាំងពីរខាងដើមនុ៎ះឯង ។ សួនអម្ពលដ្ឋិកា ក៏ដូច

គ្មានឹងពាក្យពោលហើយក្នុងព្រហ្មជាលសូត្រ ។

ពាក្យថា **កូដទន្ត** ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។

[២] បទថា **ត្រៀមរៀបចំ** គឺ ចាត់ចែង ។ បទថា វច្ឆតរសតានិ គឺ កូនគោច្រើនរយ ។ ពពែតូចៗ លោកហៅថា **ឧរព្ភ** ។ សត្វទាំងនោះមានមកក្នុងព្រះបាលីត្រឹមប៉ុណ្ណោះ ។ តែម្រឹគ និងសត្វជាច្រើន មួយមុខៗ ៧០០ សូម្បីមិនបានមានមកក្នុងព្រះបាលី ក៏គប្បីជ្រាបថា លោកប្រមូលចូលមកដូចគ្នា ។ បានជ្រាបថា កូដទន្តព្រាហ្មណ៍នោះ មានប្រាថ្នានឹងបូជាយញ្ញមួយមុខៗ ៧០០ គ្រប់យ៉ាង ។ បទថា **ត្រូវនាំទៅចងទុកនឹងបង្គោល** គឺ ត្រូវគេនាំចូលទៅកាន់គោល ពោលគឺ បង្គោលយញ្ញ ដើម្បីត្រូវការនឹងចងទុក ។

[៣-៦] បទថា **ស្នាក់នៅ** គឺ ពួកព្រាហ្មណ៍ទាំងឡាយ ស្នាក់នៅដើម្បីត្រូវការបរិភោគរបស់ដែលគេឲ្យទាន ។

បទថា **៣ ប្រការ** សេចក្តីថា ការតាំងទុក គឺ ការតាក់តែង លោកហៅថា វិធ ក្នុងពាក្យនេះ ។ បទថា **មានបរិក្ខារ ១៦** គឺ មានបរិវារ ១៦ ។

[៧] ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងបុព្វចរិត ដែលកពបិទបាំងទុក ដូចអ្នកជីករណ្តៅទ្រព្យដែលកប់នៅក្នុងដី ហើយធ្វើឲ្យជាគំនរទុក

ចំពោះមុខ ទើបត្រាស់ព្រះតម្រាស់នេះថា **រឿងនេះធ្លាប់មានមកហើយ** ដូច្នេះ ។ បទថា **មានព្រះនាមថា មហាវិជិត** សេចក្តីថា បានឮថា ព្រះរាជានោះទ្រង់ឈ្នះបឋវីមណ្ឌល ដែលមានសមុទ្រជាទីបំផុត ព្រោះហេតុនេះ ព្រះអង្គទើបទ្រង់ដល់ភាពរាប់ថា មហាវិជិតរាជ ព្រោះបឋវីមណ្ឌលដែលព្រះអង្គទ្រង់ឈ្នះហើយយ៉ាងធំ ។

ក្នុងបទថា **ស្តុកស្តម្ភជាដើម** សេចក្តីថា អ្នកណាក៏ដោយ ជាអ្នកស្តុកស្តម្ភដោយទ្រព្យសម្បត្តិដែលជារបស់ខ្លួន ។ តែព្រះបាទមហាវិជិតរាជនេះ មិនជាអ្នកស្តុកស្តមតែម្យ៉ាងប៉ុណ្ណោះទេ ព្រះអង្គនៅជាអ្នកមានឈ្មោះថា មានទ្រព្យច្រើន គឺ ដល់ព្រមដោយទ្រព្យច្រើនណាស់ គឺ រាប់មិនបាន ។ ឈ្មោះថា **មានភោគៈច្រើន** ព្រោះមានភោគសម្បត្តិច្រើនណាស់ គឺ ធំក្រៃលែងដោយអំណាចនៃកាមគុណប្រាំ ។ ឈ្មោះថា **មានមាសប្រាក់ច្រើន** ព្រោះប្រកបដោយមាស និងប្រាក់ជាដុំៗ និងដោយអំណាចជាមាសកៈមាស និងមាសកៈប្រាក់ជាដើម ។ អធិប្បាយថា ដល់ព្រមដោយមាស និងប្រាក់រាប់ដោយច្រើនកោដិ ។

បទថា **សេចក្តីរីករាយ** គឺ សេចក្តីត្រេកអរ ។ គ្រឿងឧបករណ៍នៃ

សេចក្តីរីករាយ ឈ្មោះ **វិត្តូបករណ** សេចក្តីថា ហេតុនៃសេចក្តីត្រេកអរ ។ អ្នកឈ្មោះថា មានគ្រឿងឧបករណ៍នៃសេចក្តីរីករាយចិត្តច្រើន ព្រោះគេមានគ្រឿងឧបករណ៍ដែលជាទីរីករាយចិត្តទាំងឡាយច្រើនប្រភេទ ជាដើមថា គ្រឿងប្រដាប់ផ្សេង ៗ និងភាជនៈមាសប្រាក់ជាដើម ។ អ្នកឈ្មោះថា មានធញ្ញ-ជាតិជាទ្រព្យច្រើន ព្រោះទ្រព្យ ពោលគឺ កែវ ៧ ប្រការ ដែលកប់ទុក និងស្រូវ ដែលរួមរហូតដល់បុព្វណ្ណជាតិ និងអបរណ្ណជាតិទាំងពួងមានច្រើន ។ ន័យមួយទៀត បទនេះ លោកពោលទុកដោយអំណាចការឲ្យ និងការទទួលទ្រព្យសម្បត្តិរាល់ថ្ងៃរបស់គេ ដោយអំណាចទ្រព្យ និងស្រូវអង្ករ ដែលផ្លាស់ប្តូរគ្នា ។

បទថា **មានជង្រុក និងឃ្លាំងពេញបរិបូណ៌** សេចក្តីថា អាគារដែលរក្សាវត្ថុ លោកហៅថា ឃ្លាំង អធិប្បាយថា មានឃ្លាំងពេញបរិបូណ៌ដោយទ្រព្យដែលកប់ទុក មានជង្រុកពេញបរិបូណ៌ដោយស្រូវ ។ ន័យមួយទៀត ឃ្លាំងមាន ៤ យ៉ាង គឺ ដំរី សេះ រថ ទាហានថ្មើរជើង ។ ជង្រុកមាន ៣ យ៉ាង គឺ ជង្រុករក្សាទ្រព្យ ជង្រុករក្សាស្រូវ ជង្រុករក្សាសំពត់ ។ វត្ថុគ្រប់យ៉ាងសូម្បីទាំងអស់នោះរបស់គេបរិបូណ៌ ព្រោះដូច្នោះ គេទើបឈ្មោះ

ថា មានជង្រុក និងឃ្លាំងពេញបរិបូណ៌ ។

បទថា **បានកើតឡើង** គឺ កើតឡើងហើយ ។ បានឮថា ក្នុងថ្ងៃមួយ ព្រះរាជានេះ ស្តេចចេញទៅត្រួតមើលរតនៈ ។ ព្រះអង្គត្រាស់សួរអ្នករក្សាឃ្លាំង រក្សាវត្ថុថា នែបា ទ្រព្យច្រើនសន្ធឹកសន្ធាប់យ៉ាងនេះ អ្នកណាសន្សំមក ។ កណ្ឌាគារិកទូលថា ព្រះរាជបិតា និងសម្តេចតាជាដើម របស់ព្រះអង្គសន្សំមក រហូតដល់អស់ ៧ ត្រកូល ព្រះរាជាត្រាស់សួរថា ក៏ជនទាំងនោះសន្សំទ្រព្យនេះទុកហើយ ទៅកាន់ទីណា ។ កណ្ឌាគារិកទូលថា បពិត្រសម្មតិទេព ជនទាំងអស់នោះ តែងតែទៅកាន់អំណាចរបស់សេចក្តីស្លាប់ ។ ព្រះរាជាត្រាស់សួរថា ពួកគេមិនកាន់យក ទ្រព្យរបស់ខ្លួនទៅផងទេឬ ។ កណ្ឌគារិកទូលថា បពិត្រសម្មតិទេព ព្រះអង្គត្រាស់អ្វី ពួកគេត្រូវលះបង់ចោលទ្រព្យនោះដោយពិត កាន់យកទៅមិនបាន ។ លំដាប់នោះ ព្រះរាជាស្តេចត្រឡប់មកវិញ ប្រថាប់អង្គុយក្នុងបន្ទប់ដ៏មានសិរី ទ្រង់ត្រិះរិះថា យើងគ្រប់គ្រងភោគសម្បត្តិច្រើនណាស់ ដូច្នេះជាដើម ។ ព្រោះហេតុនោះ លោកទើបពោលថា បានកើតបរិវិតក្កៈផ្លូវចិត្តយ៉ាងនេះ ដូច្នេះ ។

បទថា **ត្រាស់ហៅព្រាហ្មណ៍មក** សួរថា ព្រោះហេតុអ្វី ទើបត្រាស់

ហៅមក ។

បានឮថា ព្រះរាជានេះ ទ្រង់ត្រិះរិះយ៉ាងនេះថា ធម្មតាអ្នកដែលនឹងឲ្យទាន បានប្រឹក្សានឹងបណ្ឌិតត្រឹមតែម្នាក់មុនហើយឲ្យ ទើបនឹងគួរ ព្រោះកម្មដែលមិនបានប្រឹក្សា ធ្វើចុះទៅ រមែងធ្វើសេចក្ដីក្ដៅក្រហាយក្នុងខាងក្រោយ ដូច្នេះ ព្រោះហេតុនោះព្រះអង្គទើបត្រាស់ហៅមក ។

[៨] លំដាប់នោះ ព្រាហ្មណ៍គិតថា ព្រះរាជានេះ មានព្រះរាជបំណងនឹងថ្វាយមហាទាន និងក្នុងជនបទរបស់ព្រះអង្គ នៅមានចោរច្រើនណាស់ ចោរទាំងនោះក៏មិនទាន់ស្ងប់ កាលព្រះអង្គថ្វាយទាន ស្រុករបស់ពួកជនអ្នកនាំគ្រឿងសម្ភារៈនៃទាន មានទឹកដោះស្រស់ ទឹកដោះជូរ និងបាយសាលីជាដើមមក រមែងមិនមានអ្នកចាំ , ចោរទាំងនោះក៏នឹងប្លន់ ជនបទក៏នឹងពាសពេញទៅដោយចោរភ័យ ពេលនោះ ទានរបស់ព្រះរាជាក៏មិនប្រព្រឹត្តទៅបានយូរ សូម្បីព្រះទ័យរបស់ព្រះអង្គក៏នឹងមិនតម្កល់មាំ យើងនឹងឲ្យព្រះអង្គទ្រង់ពេញព្រះទ័យក្នុងសេចក្ដីនេះ ដូច្នេះ លំដាប់នោះ គេកាលនឹងញុំាងព្រះអង្គឲ្យទ្រង់ពេញព្រះទ័យក្នុងសេចក្ដីនោះ ទើបពោលពាក្យថា ជនបទរបស់ព្រះរាជាដ៏ចម្រើន ជាដើម ។

ក្នុងបទទាំងនោះ បទថា **ប្រកបដោយចម្រូង** គឺ នៅមានចម្រូង ដោយចម្រូង គឺ ចោរ ។ បទថា **ចាំស្កាត់តាមផ្លូវ** គឺ ការប្ល័ន់ក្នុងផ្លូវស្ងាត់ សេចក្តីថា ការសម្លាប់គ្នាក្នុងផ្លូវស្ងាត់ ។ បទថា **ជាអ្នកធ្វើដែលមិនគួរធ្វើ** សេចក្តីថា គប្បីជាអ្នកធ្វើកិច្ចដែលមិនគួរធ្វើ គឺ គប្បីជាអ្នកប្រព្រឹត្តមិនត្រឹមត្រូវតាមធម៌ ។ បទថា ឧស្សុជ្ជិលំ ប្រែថា ដន្គត់កំណាច គឺ ចោរ ។

បទថា **ដោយការសម្លាប់** គឺ ដោយការធ្វើឲ្យស្លាប់ ឬដោយការសំពង ។ បទថា ពន្ធនេន ដោយការចង គឺ ដោយការចង មានការចងដោយខ្នោះជាដើម ។ បទថា **ដោយការរឹបជាន់** គឺ ដោយការឲ្យវិនាសទ្រព្យ , អធិប្បាយថា ដោយអាជ្ញាប្រព្រឹត្តទៅយ៉ាងនេះថា ពួកលោកចូរបង់ប្រាក់ ១០០ ចូរបង់ប្រាក់ ១.០០០ ។ បទថា **ដោយការធ្វើទោស** គឺ ដោយឲ្យបានទទួលការធ្វើទោសឲ្យរាងចាល ធ្វើទោសជាដើមយ៉ាងនេះ គឺ ធ្វើឲ្យមានសក់ ៥ កញ្ចុំ , កោរក្បាលឲ្យត្រងោល យកអាចម៍គោបាត់ និងចងដោយខ្នោះត្រង់ក ។ បទថា **ដោយនេរទេស** គឺ ដោយការដេញចេញពីដែន ។ បទថា **អញ្ញទីងជក** គឺ យើងនឹងជកឲ្យអស់ដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ដោយការណ៍ដែលគួរ ។ បទថា **ដ៏សេសពីកម្ចាត់ហើយ**

គឺ ដ៏សេសពីស្នាប់ហើយ ។

បទថា **ប្រឹងប្រែង** គឺ ធ្វើសេចក្តីឧស្សាហ៍ ។ បទថា **សូមប្រទាន** សេចក្តីថា កាលវត្ថុដែលព្រះរាជទានហើយមិនគ្រប់គ្រាន់ មេត្តាព្រះរាជ-ទានពីជភត្ត និងវត្ថុដែលជាគ្រឿងដៃក្នុងការងារកសិកម្ម សូម្បីដទៃគ្រប់យ៉ាងទៀត ។ បទថា **សូមប្រទានព្រះរាជទ្រព្យជាដើមទុន** សេចក្តីថា សូមព្រះអង្គព្រះរាជទានវត្ថុដើមទុន ដោយអំណាចទារការប្រាក់ជាដើមឡើយ មិនត្រូវធ្វើភស្តុតាង មិនត្រូវចុះបញ្ជី ។

ក៏ពាក្យថា **ដើមទុន** នេះ ជាឈ្មោះរបស់វត្ថុដែលជាទុនពីដើមដំបូង ។ ដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ៖

> **បុគ្គលមានបញ្ញា មានវិចារណញាណ រមែងតម្កល់ទុកធ្វើជាដើមទុន សូម្បីត្រឹមតែបន្តិចបន្តួច ដូចជាភ្លើងដ៏តូច ដែលបុគ្គលផ្តើមបង្កាត់ ដូច្នេះ ។**

បទថា **បៀវត្សរ៍** គឺ តម្លៃអាហារប្រចាំថ្ងៃ និងទ្រព្យ មានប្រាក់ជាដើម ។ សេចក្តីថា ចូរព្រះរាជទាន ព្រមទាំងព្រះរាជទានឋានន្តរៈ ស្រុក និងនិគមជាដើម ដោយសមគួរដល់ត្រកូល ការងារ និងសេចក្តីក្លាហាន

របស់គេ ។ បទថា **អ្នកខ្វល់ខ្វាយក្នុងមុខការរបស់ខ្លួន** គឺ ជាអ្នកព្យាយាមធ្វើបានដល់ ដាក់ចិត្តធ្វើក្នុងការងាររបស់ខ្លួន មានកសិកម្ម និងពាណិជ្ជកម្មជាដើម ។ បទថា **គំនរ** គឺ គំនរនៃទ្រព្យ និងស្រូវ ។

បទថា **តាំងនៅដោយក្សេមក្សាន្ត** គឺ តាំងនៅដោយការផុតស្រឡះ គឺ មិនមានភ័យ ។

បទថា **មិនមានចម្រូង** គឺ វៀរចាកចម្រូង គឺ ចោរ ។ បទថា មុទាមោទមានា ប្រែថា **ក៏នឹងនាំគ្នាសរសើរ ត្រេកអររីករាយ** ។ មួយទៀត ពាក្យនេះឯងជាព្រះបាលី ។ អធិប្បាយថា ម្នាក់ៗ មានចិត្តត្រេកអរតាមគ្នា និងគ្នា ។ បទថា **មិនចាំបាច់បិទទ្វារផ្ទះ** សេចក្តីថា ព្រោះមិនមានពួកចោរ ទើបមិនត្រូវបិទទ្វារផ្ទះ បើកទ្វារផ្ទះទុកបាន ។

[៩] បទថា **ទ្រង់ត្រាស់ពាក្យនេះ** គឺ ព្រះបាទមហាវិជិតរាជ ទ្រង់ជ្រាបសេចក្តីដល់ស្រុកនគរស្តុកស្តម្ភ និងចម្រើនដោយអាការទាំងពួង ហើយ ទើបបានត្រាស់ព្រះតម្រាស់នេះ ។

# បរិក្ខារបួន

បទថា តេនហិ ភវំ រាជា សេចក្ដីថា បានឮថា ព្រាហ្មណ៍គិតថា ព្រះរាជានេះកើតព្រះឧស្សាហ៍ក្រៃលែងណាស់ក្នុងការថ្វាយមហាទាន តែបើព្រះអង្គទ្រង់មិនប្រឹក្សាជាមួយពួកក្សត្រិយ៍ប្រទេសរាជជាដើម ហើយថ្វាយក្សត្រិយ៍ប្រទេសរាជជាដើមនោះរបស់ព្រះអង្គ នឹងតូចព្រះទ័យ យើងនឹងធ្វើដោយប្រការដែលនឹងមិនឲ្យក្សត្រិយ៍ទាំងនោះ តូចព្រះទ័យបានក្នុងកាលឥឡូវនេះ ដូច្នេះ ព្រោះដូច្នោះ គេទើបក្រាបទូលថា **សូមទ្រង់ព្រះមេត្តាប្រោសបើដូច្នោះ** ដូច្នេះ ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ពួកអ្នកនិគម** គឺ ជនដែលអាស្រ័យនៅក្នុងនិគម ។ បទថា **ពួកអ្នកជនបទ** គឺ ជនអាស្រ័យនៅក្នុងជនបទ ។ បទថា **ចូរទ្រង់ប្រឹក្សា** គឺ ចូរទ្រង់ពិភាក្សា បានដល់ ចូរទ្រង់ថ្លែងប្រាប់ឲ្យជ្រាប ។ បទថា យំ មម អស្ស គឺ ការរួមដៃរបស់ពួកលោក គប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើង ។ បទថា អមច្ចា ប្រែថា សំឡាញ់ស្និទ្ធ ។ បទថា ចារិសជ្ជា គឺ អ្នកឯទៀតជាកូន ឬជាប្អូនដ៏សេស ។

បទថា យជតំ ភវំ រាជា ប្រែថា សូមទ្រង់បូជាយញ្ញចុះ ។

បានឮថា ជនទាំងនោះគ្រេកអរថា ព្រះរាជានេះ ទ្រង់មិនបង្ខិតបង្ខំថ្វាយទាន ដោយគិតថា យើងជាធំ ទ្រង់ក៏នៅតែហៅពួកយើងមកប្រឹក្សាគួរអស្ចារ្យពិត ព្រះអង្គទ្រង់ធ្វើល្អហើយ ដូច្នេះ ទើបបានពោលយ៉ាងនោះ ។ តែកាលបើពួកគេមិនបានមក ពួកគេក៏មិនគប្បីមក សូម្បីដើម្បីនឹងមើលទីបូជាយញ្ញ របស់ព្រះរាជានោះ ។ បទថា **បពិត្រមហារាជ កាលនេះជាកាលគួរនឹងបូជាយញ្ញហើយ** សេចក្ដីថា ពួកគេកាលនឹងសម្ដែងថា ក៏កាលទេយ្យធម៌មិនមាន ក្នុងវេលាដល់ហើយក៏មិនអាចនឹងឲ្យទានបែបនេះបាន តែលោកមានទ្រព្យ និងនៅកម្លោះពេញកម្លាំង ព្រោះហេតុនោះ ទើបជាកាលសមគួរនឹងបូជាយញ្ញរបស់លោកហើយ ដូច្នេះ ទើបបានពោលឡើង ។ បទថា **ជនអ្នកឃើញប្រពៃ** គឺ ជាចំណែកយល់ព្រម អធិប្បាយថា អ្នកឲ្យការព្រម ។ បទថា **ជាបរិក្ខារ** គឺ ជាបរិវារ ។ តែក្នុងពាក្យនេះថា **រថ** មានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយជាកង់ ដូច្នេះ គ្រឿងប្រដាប់ លោកហៅថា បរិក្ខារ ។

[១០] បទថា **ដោយអង្គ ៨ ប្រការ** គឺ ដោយអង្គ ៨ មាន

ឧភតោសុជាត ជាដើម ។

បទថា **ដោយព្រះយស** គឺ ដោយភាពជាអ្នកអាចក្នុងការដាក់អាជ្ញាបាន ។ បទថា **មានសទ្ធា** គឺ ជឿថា ផលរបស់ទានមាន ។ បទថា **ជាអ្នកឲ្យ** គឺ ជាអ្នកក្លាហានក្នុងការឲ្យ អធិប្បាយថា មិនមែនតាំងនៅត្រឹមតែមានសទ្ធាប៉ុណ្ណោះ គឺ អាចដើម្បីលះបង់ផង ។ បទថា **ជាម្ចាស់ទាន** គឺ ជាម្ចាស់របស់ទានដែលខ្លួនឲ្យមិនជាទាសៈ មិនជាសម្លាញ់ ។ អធិប្បាយថា ក៏អ្នកណាបរិភោគរបស់ឆ្ងាញ់ដោយខ្លួនឯង ឲ្យរបស់មិនឆ្ងាញ់ដល់អ្នកដទៃ អ្នកនោះចាត់ថា ជាទាសៈនៃទេយ្យធម៌ , ឲ្យទានក្នុងវត្ថុណា ខ្លួនឯងក៏បរិភោគក្នុងវត្ថុនោះ អ្នកនោះចាត់ថា ជាសម្លាញ់ , ឲ្យចំណែកអ្នកណា ខ្លួនឯងញ៉ាំងជីវិតដោយអាហារតាមមានតាមបាន តែឲ្យរបស់ឆ្ងាញ់ដល់អ្នកដទៃ អ្នកនោះចាត់ថា ជានាយ គឺ ជាម្ចាស់របស់អ្នកដ៏ក្រៃលែង ព្រះបាទមហាវិជិតរាជនេះ ទ្រង់មានសភាពដូច្នោះ ។

ក្នុងបទនេះថា **ដល់សមណព្រាហ្មណ៍ មនុស្សកំព្រា អ្នកដំណើរ អ្នកពណិនា និងយាចក** សេចក្តីថា អ្នកមានបាបដែលស្ងប់ហើយ ឈ្មោះថា **សមណ** ។ អ្នកមានបាបដែលបន្សាត់បង់ហើយ ឈ្មោះថា **ព្រាហ្មណ៍** ។

អ្នកក្រខ្សត់ គឺ អ្នកដែលក្រលំបាក ឈ្មោះថា **មនុស្សកំព្រា** ។ បទថា អទ្ធិកា ប្រែថា អ្នកដើរផ្លូវឆ្ងាយ ។ ជនពួកណាដើរសរសើរគុណនៃទាន ដោយន័យជាដើមថា លោកដ៏ចម្រើន អ្នកឲ្យទានគួរជាទីប្រាថ្នា គួរជាទីស្រឡាញ់ គួរជាទីពេញចិត្ត មិនមានទោស តាមកាលដែលគួរ ធ្វើចិត្តឲ្យជ្រះថ្លាហើយ ចូលទៅកាន់ព្រហ្មលោក ដូច្នេះ ជនទាំងនោះឈ្មោះថា **វណិពក** ។ ជនពួកណាពោលពាក្យជាដើមថា សូមលោកឲ្យត្រឹមតែមួយទូកដៃចុះ សូមលោកឲ្យត្រឹមតែមួយផ្តិលចុះ ដើរសូមគេទៅ ជនទាំងនោះឈ្មោះថា **យាចក** ។ បទថា **ដូចជាអណ្តូងទឹកសម្រាប់ផឹក** គឺ ដូចអណ្តូងទឹក ។ អធិប្បាយថា ដូចជាស្រះបោក្ខរណី ដែលគេជីកទុកត្រង់ផ្លូវធំបែកជា ៤ ជាទីបរិភោគទូទៅរបស់អ្នកទាំងពួង ។ ក្នុងបទថា ប្រការដែលទ្រង់សិក្សានេះ គឺ ប្រការដែលទ្រង់សិក្សាហើយនុ៎ះឯង ឈ្មោះថា **ទ្រង់សិក្សាហើយ** ។

ក្នុងបទថា **ទ្រង់នឹងព្រះរាជតម្រិះនូវប្រយោជន៍ទាំងឡាយ ដែលជាអតីត អនាគត និងបច្ចុប្បន្នបាន** គប្បីជ្រាបសេចក្តីថា ព្រះអង្គកាលទ្រង់គិតយ៉ាងនេះថា ព្រោះហេតុដែលយើងបានធ្វើបុណ្យទុកក្នុងអតីតនុ៎ះឯង យើងទើបមានសម្បត្តិ ដូច្នេះ ឈ្មោះថា ទ្រង់អាចគិតប្រយោជន៍ដែលជាអតីត ។

កាលទ្រង់គិតថា យើងធ្វើបុណ្យក្នុងកាលឥឡូវនេះឯង អាចនឹងបានទទួលសម្បត្តិក្នុងអនាគត ដូច្នេះ ឈ្មោះថា ទ្រង់អាចគិតប្រយោជន៍ដែលជាអនាគត ។ កាលទ្រង់គិតថា ឈ្មោះថា កម្មដែលជាបុណ្យនេះ ជាអាចិណ្ណកម្មរបស់សប្បុរស សូម្បីភោគទ្រព្យរបស់យើងក៏មាន ទាំងចិត្តគិតនឹងឲ្យក៏មានហើយ ណ្ហើយចុះ យើងនឹងធ្វើបុណ្យ ដូច្នេះ ឈ្មោះថា ទ្រង់គិតប្រយោជន៍ដែលជាបច្ចុប្បន្ន ដូច្នេះ ។

បទថា **អង្គទាំងនេះ ដោយប្រការដូច្នេះ** គឺ អង្គទាំងនេះ តាមដែលពោលមកហើយ ដោយប្រការដូច្នេះ ។ បានឮថា មហាជនចេញពីទិសទាំងពួង រមែងចូលទៅរកទានរបស់បុគ្គលដែលដល់ព្រមដោយអង្គទាំង ៨ នេះ ។ អ្នកខ្លះគិតឃើញហេតុជាដើមយ៉ាងនេះថា អ្នកនេះកើតមិនល្អហើយ នឹងឲ្យទានបានយូរប៉ុនណា ឥឡូវនេះគេក៏នឹងក្តៅក្រហាយ នឹងឈប់ធ្វើទាន ដូច្នេះហើយរមែងមិនសម្គាល់ដល់ទានថា **គួរនឹងចូលទៅរក** ព្រោះដូច្នោះ អង្គទាំង ៨ នេះ លោកទើបពោលថា **ជាបរិក្ខារ** ។

[១១] បទថា **អ្នកទទួលនូវការបូជា** គឺ អ្នកកាន់វែកឲ្យទានក្នុងទីដែលទទួលការឲ្យទានយ៉ាងធំ ។ បទថា **ដោយអង្គទាំង ៤ នេះ** គឺ

ដោយអគ្គ មានការកើតល្អហើយជាដើមទាំងនេះ ។ ពួកជនអ្នកដែលពោលពាក្យជាដើមថា កាលអគ្គ មានកំណើតស្អាតជាដើមមាន ទានដែលប្រព្រឹត្តទៅ ដោយការចាត់ចែងរបស់អ្នកមានកំណើតមិនស្អាតយ៉ាងនេះ នឹងប្រព្រឹត្តបានទៅយូរប៉ុនណា ដូច្នេះ នឹងមិនចូលទៅរកឡើយ តែនឹងចូលទៅរក ព្រោះមិនមានវត្ថុដែលនឹងគប្បីតិះដៀលប៉ុណ្ណោះ ព្រោះហេតុនោះ អគ្គសូម្បីទាំងនេះ លោកទើបពោលថា **ជាបរិក្ខារ** ។

[១២] បទថា ***សម្តែងយញ្ញវិធី ៣ ប្រការ*** គឺ សម្តែងការតាំងមាំ ៣ យ៉ាង ។

បានឮថា គេគិតថា ធម្មតាអ្នកឲ្យទានហើយ រមែងញាប់ញ័រក្នុងឋានៈណាមួយ ក្នុងបណ្តាឋានៈទាំង ៣ នោះ ណ្ហើយចុះ យើងនឹងធ្វើព្រះរាជានេះឲ្យទ្រង់មិនញាប់ញ័រក្នុងឋានៈទាំងនេះ ក្នុងកាលដទៃណាមួយ ដូច្នេះហើយ ទើបសម្តែងយញ្ញវិធី ៣ យ៉ាងដល់ព្រះរាជានោះ ។ ពាក្យនេះថា សោភោគោ រញ្ញោ ជាចដ្ឋីវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ ។

ន័យមួយទៀត បាលីថា ភោគា រញ្ញោ ដូច្នេះ ក៏មាន ។ បទថា **មិនគប្បីធ្វើវិប្បដិសារៈ** លោកសម្តែងថា មិនគួរធ្វើសេចក្តីក្តៅក្រហាយក្នុង

ខាងក្រោយ ដែលមានការចំណាយអស់ទៅនៃភោគសម្បត្តិជាហេតុ តែបុព្វ-
ចេតនាគួរឲ្យតាំងមាំ មិនញាប់ញ័រ ព្រោះទាននោះ រមែងមានផលច្រើន
ដោយប្រការដូច្នេះ ។ ក្នុងឋានៈ ២ យ៉ាង សូម្បីក្រៅនេះ ក៏មានន័យដូច្នេះ
ដូចគ្នា ។ ក៏ចេតនាដែលកំពុងបរិច្ចាគក្តី ចេតនាដែលតាមរឭកដល់កាលក្នុង
ខាងក្រោយក្តី គួរធ្វើមិនឲ្យញាប់ញ័រ កាលមិនធ្វើដូច្នោះ ទានរមែងមិនមាន
ផលច្រើន ទាំងចិត្តក៏នឹងមិនបង្អោនទៅក្នុងភោគសម្បត្តិដែលច្រើនក្រៃលែង
ដូចទានរបស់សេដ្ឋី គហបតី អ្នកទៅកើតក្នុងមហារោរុវនរក ដូច្នោះ ។

**[១៣-២២]** បទថា ***ដោយអាការ ១០*** គឺ ដោយហេតុ ១០ ។ បានឮ
ថា ព្រាហ្មណ៍បុរោហិតនោះ មានសេចក្តីគិតយ៉ាងនេះថា បើព្រះរាជានេះទ្រង់
ឃើញអ្នកទ្រុស្តសីលហើយ គិតថា ទានរបស់យើងនឹងវិនាសពិត អ្នកទ្រុស្ត-
សីលបែបនេះ បរិភោគទានរបស់យើង ដូច្នេះ សូម្បីក្នុងអ្នកមានសីល ក៏នឹង
ឲ្យកើតវិប្បដិសារបាន ទានក៏នឹងមិនមានផលច្រើន ក៏ធម្មតាភាពវិប្បដិសារ
រមែងកើតឡើងដល់ពួកទាយក ព្រោះបដិគ្គាហកៈដោយពិត ណ្ហើយចុះ យើង
នឹងបន្ទោបង់ភាពវិប្បដិសារនោះរបស់ព្រះអង្គ ដូច្នេះ ព្រោះដូច្នោះ គេទើប
បន្ទោបង់វិប្បដិសារសូម្បីក្នុងបដិគ្គាហកៈ ដែលគួរនឹងកាត់ផ្តាច់ដោយអាការ

១០ យ៉ាង ។ បទថា តេសំយេវ តេន លោកសម្តែងថា ផលដែលមិនគប្បីប្រាថ្នា ព្រោះបាបនោះនឹងមានដល់គេទាំងនោះប៉ុណ្ណោះ នឹងមិនមានដល់អ្នកដទៃ ។

បទថា យជតំ ភវំ ប្រែថា សូមព្រះអង្គព្រះរាជទានចុះ ។ បទថា សជ្ជតំ ប្រែថា សូមទ្រង់លះបង់ចុះ ។ បទថា អន្តរំ គឺ ក្នុងខាងក្នុង ។

[២៣-២៨] ក្នុងបទនេះថា **ញុំាងព្រះទ័យឲ្យឃើញតាមដោយអាការ ១៦** គឺ ព្រាហ្មណ៍ប្រារព្ធការអនុមោទនាមហាទានរបស់ព្រះរាជា ។ បណ្តាបទទាំងនោះ បទថា **សម្តែងឲ្យឃើញពិត** គឺ ពោលសម្តែងហើយសម្តែងទៀតថា អ្នកឲ្យទាននេះ នឹងបានសម្បត្តិមានសភាពយ៉ាងនេះ ដូច្នេះ ។ បទថា **ឲ្យកាន់យក** គឺ ពោលឲ្យកាន់យកសេចក្តីនោះដោយប្រពៃ ។ បទថា **ឲ្យអាចហ៊ាន** គឺ ធ្វើឲ្យចិត្តរបស់ព្រះរាជានោះថ្លាផូរផង់ ដោយការបន្ទោបង់វិប្បដិសារ ។ បទថា **ឲ្យរីករាយ** គឺ ពោលសរសើរថា បពិត្រមហារាជ ព្រះអង្គកាលថ្វាយទាន គឺ ទ្រង់ធ្វើនោះ ល្អហើយ ដូច្នេះ ។ បទថា **អ្នកពោលដោយធម៌មិនមាន** គឺ អ្នកពោល គឺ ដោយប្រពៃ បានដល់ ហេតុមិនមាន ។

[២៩] បទថា **មិនកាប់ដើមឈើដើម្បីត្រូវការធ្វើបង្គោលយញ្ញ មិន**

***ប្រូតស្សូវក្ខាំង ដើម្បីត្រូវការបៀតបៀនអ្នកដទៃ*** *ព្រាហ្មណ៍សម្ដែងថា ជនពួកណាឲ្យតាំងសសរធំ ដែលមានឈ្មោះថា សសរយ័ញ្ញ ហើយសរសេរឈ្មោះនឹងសសរថា ព្រះរាជាឯណោះ អាមាត្យឯណោះ ព្រាហ្មណ៍ឯណោះបូជាមហាយ័ញ្ញបែបនេះ ដូច្នេះហើយ តាំងទុក និងប្រូតស្សូវក្ខាំងព័ទ្ធជុំវិញសាលាយ័ញ្ញ ដោយសន្មែបថា ជាព្រៃឈ្មោះ ឬក្រាលលើផែនដី ជនសូម្បីទាំងនោះមិនបានកាត់ដើមឈើ មិនបានប្រូតស្សូវក្ខាំង ក៏ពួកគេនឹងសម្លាប់គោ ឬសត្វ មានពពែជាដើម ដោយហេតុដូចម្ដេច ដូច្នេះ ។*

*បទថា* ទាស *គឺ ទាសៈ មានទាសៈដែលកើតខាងក្នុងផ្ទះជាដើម ។ ជនពួកណាកាន់យកទ្រព្យមុនហើយ ទើបធ្វើការងារឲ្យ ជនទាំងនោះ ឈ្មោះថា* បេស្សា ***អ្នកបម្រើ*** *។ ជនពួកណាទទួលតម្លៃអាហារប្រចាំថ្ងៃ និងតម្លៃឈ្នួលទើបធ្វើការងារឲ្យ ជនទាំងនោះឈ្មោះថា* កម្មករ *។ ជនអ្នកដែលគេកាន់ដំបង និងឈើអន្លូងជាដើម គម្រាមយ៉ាងនេះថា ចូរធ្វើការងារ ចូរធ្វើការងារ ឈ្មោះថា* ***គម្រាមដោយអាជ្ញា*** *។ ជនអ្នកដែលគេគម្រាមដោយភ័យយ៉ាងនេះថា បើអ្នកឯងធ្វើការងារនោះ ជាការល្អ បើមិនធ្វើ យើងនឹងកាត់ ឬនឹងឃុំឃាំង ឬនឹងសម្លាប់ចោល ដូច្នេះ ឈ្មោះថា* ***អ្នកត្រូវភ័យគម្រាម*** *។*

តែជនទាំងនោះ មិនបានទទួលការគម្រាមដោយអាជ្ញា មិនបានទទួលការគម្រាមដោយភ័យ មិនបានមានមុខជោកដោយទឹកភ្នែក ស្រែកទ្រហោយំ ។ ការពិតពួកគេនាំគ្នាធ្វើការងារ រាក់ទាក់ ប្រាស្រ័យរកគ្នាដោយពាក្យរាក់ទាក់ដែលគួរស្រឡាញ់តែម្យ៉ាង ព្រោះក្នុងជនទាំងនោះ ពួកគេមិនហៅខ្ញុំកំដរថា ជាទាសៈ , អ្នកបម្រើថា ជាបេស្សកជន , អ្នកធ្វើការងារថា ជាកម្មករ , តែត្រឡប់ហៅគ្នាដោយពាក្យរាក់ទាក់ដែលគួរស្រឡាញ់ តាមសេចក្ដីពេញចិត្តម្នាក់ៗ សម្ដែងការងារតាមសមគួរដល់ភាពជាស្រី ជាប្រុស មានកម្លាំង និងទុព្វលភាព នាំគ្នានិយាយថា ពួកលោកចូរធ្វើការងារនេះ ៗ សូម្បីគេទាំងនោះ ក៏ធ្វើដោយសេចក្ដីពេញចិត្តរបស់ខ្លួន ។ ព្រោះហេតុនោះ លោកទើបពោលថា ៖

**ពួកជនណាពេញចិត្ត ពួកជននោះ ក៏ធ្វើ ពួកជនណាមិនពេញចិត្ត ពួកជននោះក៏មិនធ្វើ ពេញចិត្តវត្ថុណា ក៏ធ្វើវត្ថុនោះ មិនពេញចិត្តវត្ថុណា ក៏មិនធ្វើវត្ថុនោះ ។**

បទថា **យញ្ញនោះ** បានដល់ ការសម្រេចដោយទឹកដោះថ្លា ប្រេងទឹកដោះខាប់ ទឹកដោះជូរ ទឹកឃ្មុំ និងដុំស្ករអំពៅប៉ុណ្ណោះឯង សេចក្ដីថា

បានឮថា ព្រះរាជាបញ្ជាឲ្យសាងរោងទានធំក្នុងទី ៥ កន្លែង គឺ ក្បែរទ្វារក្រៅនគរ ៤ កន្លែង និងត្រង់កណ្ដាលខាងក្នុងនគរ ១ កន្លែង ក្នុងរោងទានមួយកន្លែងៗ ទ្រង់តាំងប្រមាណប្រាក់ទុក មួយកន្លែងមួយសែនៗ ទ្រង់លះបង់ទ្រព្យមួយថ្ងៃប្រាំសែនៗ ចាប់ផ្ដើមតាំងពីព្រះអាទិត្យឡើង ទ្រង់កាន់វែកមាសដោយព្រះហស្ដរបស់ព្រះអង្គឯង ឲ្យមហាជនឆ្អែតគ្រប់គ្រាន់ដោយបបរ របស់ទំពារ បាយ និងសម្លរជាដើម រួមដោយទឹកដោះថ្លា និងប្រេងជាដើម ដ៏ប្រណីតតាមសមគួរដល់វេលានោះៗ សម្រាប់អ្នកដែលមានប្រាថ្នានឹងកាន់យកទៅ ក៏ទ្រង់ឲ្យដោយទំនងនោះឯង ដរាបពេញភាជនៈ ។ តែក្នុងវេលាល្ងាច ទ្រង់បូជាដោយសំពត់ របស់ក្រអូប និងផ្កាឈើជាដើម ចំណែកពាងធំសម្រាប់ដាក់ទឹកដោះជាដើម ក៏ឲ្យដាក់ឲ្យពេញ ហើយតាំងទុកក្នុងទីច្រើនរយកន្លែង ដោយតាំងព្រះទ័យថា អ្នកណាមានសេចក្ដីប្រាថ្នានឹងបរិភោគវត្ថុណា អ្នកនោះចូរបរិភោគវត្ថុនោះចុះ ដូច្នេះ ។ លោកសំដៅយកហេតុនោះ ទើបពោលថា យញ្ញពិធីនោះ បានដល់ ការសម្រេចបានដោយទឹកដោះថ្លា ប្រេង ទឹកដោះខាប់ ទឹកដោះជូរ ទឹកឃ្មុំ និងស្ករអំពៅដូច្នេះ ។

[៣០] បទថា **ក៏នាំគ្នាយកទ្រព្យសម្បត្តិជាច្រើន** គឺ កាន់យកទ្រព្យមកច្រើនសន្ធឹកសន្ធាប់ ។ បានឮថា ជនទាំងនោះគិតថា ព្រះរាជានេះទ្រង់មិនបានឲ្យនាំទឹកដោះថ្លា និងប្រេង ជាដើមមកពីជនបទ ទ្រង់នាំវត្ថុដែលជាចំណែកព្រះអង្គប៉ុណ្ណោះ ចេញមក ឲ្យជាមហាទាន ការដែលពួកយើងនឹងនៅស្ងៀមដោយគិតថា ក៏ព្រះរាជា ទ្រង់មិនឲ្យពួកយើងនាំវត្ថុណាមក ដូច្នេះមិនគួរទេ ដូច្នេះ ព្រោះថា ទ្រព្យក្នុងផ្ទះរបស់ព្រះរាជានឹងមិនអស់ទៅជាធម្មតាក៏ទេ ក៏កាលពួកយើងមិនឲ្យហើយ នរណាដទៃនឹងថ្វាយចំពោះព្រះរាជាណ្ហើយចុះ យើងនឹងរួបរួមទ្រព្យមកថ្វាយចំពោះព្រះអង្គ ។ ពួកគេទើបរួបរួមទ្រព្យតាមចំណែករបស់ស្រុក តាមចំណែករបស់និគម និងតាមចំណែករបស់នគរ ផ្ទុកដាបដល់ពេញរទេះ ហើយនាំទៅថ្វាយចំពោះព្រះរាជា ។ លោកសំដៅយកទ្រព្យនោះ ទើបពោលពាក្យថា ទ្រព្យច្រើនសន្ធឹកសន្ធាប់ជាដើម ។

[៣១] បទថា **ក្នុងទិសខាងកើតនៃរោងយញ្ញ** គឺ ក្នុងចំណែកនៃទិសបូព៌ារបស់រោងយញ្ញ ត្រង់ទ្វារនគរទិសបូព៌ា ជនទាំងឡាយតាំងទានទុកក្នុងទីដែលសមគួរចុះ ដោយប្រការដែលពួកជនអ្នកមកពីទិសបូព៌ា បរិភោគបបរយាគូក្នុងរោងទានរបស់ក្សត្រិយ៍ហើយ បរិភោគក្នុងរោងទានរបស់ព្រះរាជា

ក៏ចូលទៅកាន់ក្រុងបាន ។

បទថា **ក្នុងទិសខាងត្បូងនៃរោងយ័ញ្ញ** សេចក្តីថា ជនទាំងឡាយតាំងទានទុកក្នុងទិសខាងត្បូង តាមន័យដូចពោលហើយនុ៎ះឯង របស់រោងទានត្រង់ទ្វារនគរទិសខាងត្បូង សូម្បីក្នុងទិសខាងលិច និងទិសខាងជើងក៏មានន័យនេះដូចគ្នា ។

**[៣២]** បទថា អហោ យញ្ញោ អហោ យញ្ញសម្បទា អើហ្ន៎ យ័ញ្ញ យ័ញ្ញសម្បត្តិហ្ន៎ សេចក្តីថា ពួកព្រាហ្មណ៍បានស្តាប់ការដល់សេចក្តីសម្រេចរបស់យ័ញ្ញដោយទឹកដោះថ្លាជាដើម ម្នាក់ៗមានចិត្តត្រេកអរថា វត្ថុណាមានរសឆ្ងាញ់ក្នុងលោក ព្រះសមណគោតមត្រាស់ដល់វត្ថុនោះ ណ្ហើយចុះ ពួកយើងនឹងសរសើរយ័ញ្ញរបស់ព្រះអង្គ ដូច្នេះ កាលនឹងសរសើរ ទើបបានក្រាបទូលដូច្នោះ ។ បទថា **កូដទណ្ឌព្រាហ្មណ៍អ្នកអង្គុយស្ងៀម** គឺ គេកំពុងគិតសេចក្តីដែលនឹងគប្បីពោលតទៅ ទើបនៅអង្គុយស្ងៀម ។ ព្រាហ្មណ៍កាលនឹងទូលសួរ ដោយដោះសំនួរ ទើបក្រាបទូលពាក្យនេះថា **ចុះព្រះគោតមដ៏ចម្រើនទ្រង់ជ្រាបឬ** ដូច្នេះ ។ ព្រោះគេកាលនឹងសួរដោយប្រការដទៃត្រង់ ៗ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ក្នុងកាលនោះព្រះអង្គ

បានជាព្រះរាជា ឬថា ព្រាហ្មណ៍បុរោហិត ដូច្នេះ ក៏នឹងដូចជាថា មិនគោរព ។

# និច្ចទានអនុក្កុលយញ្ញ

[៣៣-៣៦] ព្រាហ្មណ៍កាលនឹងទូលសួរសេចក្ដីនេះថា ការដែលនឹងក្រោកឡើង ហើយក្រោកឡើងឲ្យទាន ជារបស់ធ្ងន់របស់អ្នកជម្ពូទ្វីបទាំងអស់ និងអ្នកជនបទទាំងអស់ កាលមិនធ្វើការងាររបស់ខ្លួនក៏នឹងវិនាស យញ្ញយ៉ាងដទៃអំពីយញ្ញនេះ ដែលមានការត្រៀមតិចជាង និងមានផលច្រើនជាងរបស់ពួកខ្ញុំព្រះអង្គ មានឬទេហ្ន៎ ដូច្នេះ ទើបក្រាបទូលពាក្យនេះថា **បពិត្រព្រះគោតមដ៏ចម្រើន មានដែរឬ** ដូច្នេះ ។

បទថា និច្ចទាន គឺ ទានប្រចាំ បានដល់ និច្ចភត្ត ។ បទថា អនុក្កុលយញ្ញ គឺ ទានណាមួយដែលគេធ្វើដោយគិតថា ឪពុក និងជីតា ជាដើមរបស់ពួកយើងធ្លាប់ធ្វើមកហើយ ដូច្នេះ សូម្បីគេនឹងជាអ្នកក្រខ្សត់ក្នុងខាងក្រោយ ក៏គួរធ្វើតទៅ តាមដែលបន្តគ្នាមករបស់ត្រកូល ។ បានឮថា ទានដែលថ្វាយចំពោះលោកអ្នកមានសីលជាប្រចាំបែបនេះ សូម្បីអ្នកក្រលំបាកក្នុងត្រកូល រមែងមិនកាត់ចេញ ។ ក្នុងសេចក្ដីនេះមាន រឿងដូចតទៅនេះ ៖

បានឮថា ក្នុងផ្ទះរបស់អនាថបិណ្ឌិកៈ ជនទាំងឡាយថ្វាយនិច្ចភត្ត ៥០០ ដែលមានស្លាកធ្វើដោយក្អុក ៥០០ ។ តមកត្រកូលនោះ ត្រូវសេចក្តីក្រលំបាកគ្របសង្កត់ដោយលំដាប់ ។ ក្មេងស្រីម្នាក់ក្នុងត្រកូលនោះ មិនអាចថ្វាយសូម្បីតែស្លាកមួយបាន ។ សូម្បីក្មេងស្រីនោះ ខាងក្រោយដល់វជ្ជសម័យរបស់ព្រះបាទសេតវាហនៈ ក៏បានថ្វាយស្លាកនោះ ដោយអង្ករដែលលាងលានបានមក ។ ព្រះថេរៈមួយរូបបានថ្វាយព្រះពរចំពោះព្រះរាជា ។ ព្រះរាជាទ្រង់នាំនាងមក ហើយតាំងទុកក្នុងតំណែងជាអគ្គមហេសី ។ ចាប់ផ្តើមតាំងពីកាលនោះ នាងក៏បានថ្វាយសលាកភត្ត ៥០០ ទៀត ។

បទថា **ការប្រហារដោយដំបង** សេចក្តីថា ការប្រហារដោយដំបងខ្លះ ការចាប់ត្រង់កខ្លះ ដែលគេពោលមានពាក្យជាដើមថា ពួកអ្នកឯងចូរឈរ ពួកអ្នកឯងចូរឈរតាមលំដាប់ ដូច្នេះ ។ និងថា ពួកអ្នកឯងចូរចាប់ពួកអ្នកឯងចូរចាប់ ធ្វើឲ្យត្រង់ដូច្នេះ ញ៉ាំងឲ្យប្រាកដ ។ ក្នុងបទនេះថា **ព្រាហ្មណ៍ នេះឯងជាហេតុ ។ល។ មានអានិសង្សច្រើន** សេចក្តីថា សេចក្តីត្រូវការដោយអ្នកដែលនឹងធ្វើការជួយនៅសល់ឬ ដោយគ្រឿងឧបករណ៍ជាច្រើន មិនមានក្នុងសលាកភត្តនេះ ដូចក្នុងមហាយញ្ញ ព្រោះដូច្នោះ ទាន

នោះទើបឈ្មោះថា ប្រើទ្រព្យសម្បត្តិតិចជាង ។ ការត្រៀម ការពោល គឺ ការបៀតបៀន ដោយអំណាចការកាត់បង់នៃកម្មរបស់ជនពួកច្រើន ក្នុងផ្លូវនេះមិនមាន ព្រោះហេតុនោះ ទាននេះទើបឈ្មោះថា មានការត្រៀមតិចជាង។ មួយទៀត ទាននេះគេថ្វាយ គឺ បរិច្ចាគដល់សង្ឃ ព្រោះដូច្នោះលោកទើបហៅថា យ័ញ្ញ ។ ក៏ទាននេះមិនមែនជារបស់ដែលធ្វើបានងាយ ដើម្បីធ្វើការកំណត់ការហូរមករបស់បុណ្យនៃទក្ខិណា ដែលប្រកបព្រមដោយអង្គ ៦ ដូចទឹកក្នុងមហាសមុទ្រ អ្នកណាប្រមាណមិនបាន ដូច្នោះ ទាននេះក៏ដូច្នោះ ព្រោះដូច្នោះ ទាននោះ គប្បីជ្រាបថា មានផលច្រើនជាង និងមានអានិសង្សច្រើនជាង ។

ព្រាហ្មណ៍បានស្តាប់ពាក្យនេះហើយគិតថា កាលបុគ្គលក្រោកឡើងហើយ ក្រោកឡើងទៀត ថ្វាយនិច្ចភត្តសូម្បីរាល់ៗ ថ្ងៃ ការងាររបស់អ្នកខ្លះក៏នឹងវិនាស នឹងត្រូវបណ្តុះភាពឧស្សាហ៍ថ្មីៗ ឡើងរឿយៗ យ័ញ្ញយ៉ាងដទៃសូម្បីក្រៅពីនេះ ដែលមានការប្រើទ្រព្យសម្បត្តិតិចជាង និងមានការត្រៀមតិចជាង មានដែរឬ ព្រោះដូច្នោះ គេទើបក្រាបទូលពាក្យនេះថា **បពិត្រព្រះគោតមដ៏ចម្រើន ........ មានដែរឬ** ដូច្នេះ ។ ក្នុងទានទាំងនោះ កាល

សលាកភត្តដែលមិនមានទីបំផុតនៃកិច្ចដែលគប្បីធ្វើ បុគ្គលខ្លះក៏ត្រូវក្រោកឡើងហើយ ក្រោកឡើងទៀត មិនបានធ្វើការងារដទៃ ចាត់ចែងតែសលាកភត្តប៉ុណ្ណោះ ។ ចំណែកក្នុងវិហារទាន មានទីបំផុតនៃកិច្ចដែលគប្បីធ្វើ , ពិតណាស់ ការសាងបណ្ណសាលា ឬការលះបង់ទ្រព្យត្រឹមតែមួយកោដិ សាងមហាវិហារ គេធ្វើការបរិច្ចាគទ្រព្យត្រឹមតែម្ដងសាងឡើងទុក ក៏គង់តែឋិតថេរនៅបាន ៧-៨ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ១.០០០ ឆ្នាំខ្លះ នោះឯង នឹងត្រូវធ្វើខ្លះ ក៏ត្រឹមតែការជួសជុលក្នុងទីដែលទ្រុឌទ្រោម និងទ្រុឌទោមតែម្ដងប៉ុណ្ណោះ ព្រោះដូច្នោះ វិហារទាននេះ ទើបប្រើទ្រព្យសម្បត្តិតិចជាង មានការត្រៀមតិចជាងសលាកភត្តទាន ។ ក៏ក្នុងវិហារទាននេះ លោកពោលអានិសង្សទុក ៩ ប្រការថា ដើម្បីការពារនូវត្រជាក់ជាដើម ដោយបរិយាយនៃព្រះសូត្រ តែដោយបរិយាយនៃខន្ធកៈ លោកពោលអានិសង្សទុក ១៧ ប្រការថា ៖

**ការថ្វាយវិហារ ចំពោះសង្ឃទាំងឡាយ រមែងកម្ចាត់បេញ**
**បាននូវត្រជាក់ ក្ដៅ តអំពីនោះ សត្វសាហាវ ពស់តូច**
**មូស និងតំណក់ភ្លៀង កម្ចាសត់បេញបាន ខ្យល់ និងកំដៅ**

ថ្ងៃដ៏ខ្វាំងក្លាដែលកើតឡើងហើយ ទាំងប្រព្រឹត្តទៅដើម្បី
ការពួនសម្ងំ ដើម្បីសេចក្តីសុខ ដើម្បីបំពេញឈាន និង
ដើម្បីចម្រើនវិបស្សនា ព្រះពុទ្ធទាំងឡាយទ្រង់សរសើរថា
ជាកំពូលទាន ព្រោះហេតុនោះឯង បុគ្គលឆ្លាត កាលឃើញ
ប្រយោជន៍របស់ខ្លួន គប្បីសាងវិហារដែលគួរីកកាយមនោ-
រម្យ ថ្វាយដល់ភិក្ខុជាពហុស្សូត អាស្រ័យនៅក្នុងវិហារនោះ
ហើយគប្បីថ្វាយបាយ ទឹក សំពត់ និងសេនាសនៈដល់ភិក្ខុ
ពួកនោះ ដែលជាអ្នកត្រូវការ ដោយទឹកចិត្តដែលជ្រះថ្លា
ចំពោះភិក្ខុទាំងនោះ នឹងសម្តែងធម៌ជាគ្រឿងបន្ទោបង់សេចក្តី
ទុក្ខទាំងពួងដល់គេ ដែលគេដឹងច្បាស់ហើយ នឹងជាអ្នក
អស់អាសវៈ បរិនិព្វាន ដូច្នេះ ។

ព្រោះដូច្នោះ វិហារទាននេះ គប្បីជ្រាបថា មានផលច្រើនជាង
មានអានិសង្សច្រើនជាងសលាកកត្តទាន ។ តែលោកពោលថា **យញ្ញ** ព្រោះ
ជាទានដែលបរិច្ចាគដល់សង្ឃ ព្រាហ្មណ៍សូម្បីស្តាប់សេចក្តីនេះហើយគិតថា
ដែលឈ្មោះថា ការធ្វើការបរិច្ចាគទានទ្រព្យ ហើយសាងវិហារថ្វាយ ធ្វើបាន

ដោយលំបាក ព្រោះប្រាក់ត្រឹមតែមួយកាកណិក ដែលជារបស់ខ្លួន លំបាក នឹងបរិច្ចាគឲ្យអ្នកដទៃ ណ្ហើយចុះ យើងនឹងសួរយញ្ញដែលប្រើទ្រព្យតិចជាង និងដែលមានការត្រៀមតិចជាងវិហារទាននេះ ដូច្នេះ ។ លំដាប់នោះ កាល នឹងទូលសួរយញ្ញនោះ ទើបទូលថា **បពិត្រព្រះគោតម ដ៏ចម្រើន..... មាន ដែរឬ** ដូច្នេះជាដើម ។

ក្នុងបណ្ដាបទទាំងនោះ វិហារសូម្បីបរិច្ចាគហើយតែមួយលើក ក៏នៅ មានកិច្ចដែលនឹងគប្បីធ្វើ ជាប់ទាក់ទងដោយការប្រក់ដំបូល និងការជួស ជុលវត្ថុដែលបាក់បែក ពុកផុយជាដើមរឿយៗ ចំណែកសរណៈដែលទទួល ហើយតែមួយលើក ក្នុងសំណាក់របស់ភិក្ខុមួយរូប ឬរបស់ព្រះសង្ឃ ឬ របស់គណៈ ក៏រាប់ថា ទទួលរហូត ព្រោះមិនមានកិច្ចដែលនឹងត្រូវធ្វើក្នុង សរណៈនោះរឿយៗ ព្រោះដូច្នោះ សរណៈនោះ ទើបមានការប្រើទ្រព្យតិច ជាង និងដែលមានការត្រៀមតិចជាងវិហារទាន ។ មួយទៀត ឈ្មោះថា ការដល់សរណៈ មានបុញ្ញកម្ម ដែលសម្រេចដោយការបរិច្ចាគជីវិតដល់ព្រះ រតនត្រ័យ រមែងឲ្យសម្បត្តិគ្រប់ប្រការ ព្រោះដូច្នោះ គប្បីជ្រាបថា មានផល ច្រើនជាង និងមានអានិសង្សច្រើនជាង ។ ក៏ការដល់សរណៈនេះ តថាគត

ហៅថា យញ្ញ ព្រោះជាប់ទាក់ទងដល់ការបរិច្ចាគជីវិតដល់ព្រះរតនត្រ័យ ។

ព្រាហ្មណ៍សូម្បីស្តាប់ពាក្យនេះហើយ គិតថា ការដែលនឹងបរិច្ចាគជីវិតដល់ព្រះរតនត្រ័យ ធ្វើបានដោយលំបាក យញ្ញដែលមានការប្រើទ្រព្យតិចជាង និងមានការត្រៀមតិចជាងសរណៈគមន៍នេះ មានដែរឬ ។ លំដាប់នោះ គេកាលនឹងទូលសួរយញ្ញនោះ ទើបទូលថា **បពិត្រព្រះគោតមដ៏ចម្រើន ...... មានដែរឬ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ក្នុងបទមានបទថា **ការសង្រួមវៀរចាកបាណាតិបាត** ជាដើម ការសង្រួម ឈ្មោះថា ការវៀរ ។

ការសង្រួម មាន ៣ គឺ សម្បត្តវិរតិ សមាទានវិរតិ សេតុឃាតវិរតិ ។ បណ្តាវិរតិទាំង ៣ នោះ អ្នកណាសូម្បីមិនបានទទួលសិក្ខាបទឡើយ តែរលឹកដល់ជាតិ គោត្រ ត្រកូល និងប្រទេសជាដើម របស់ខ្លួននោះឯងថា ការធ្វើយ៉ាងនេះ មិនសមគួរដល់យើងទេ ដូច្នេះ ហើយមិនធ្វើបាណាតិបាតជាដើម ចៀសវាងវត្ថុដែលមកដល់ចំពោះមុខ វៀរចាកវត្ថុនោះ វិរតិនោះ របស់បុគ្គលនោះ គប្បីជ្រាបថា **ជាសម្បត្តវិរតិ** ។ ចំណែកវិរតិរបស់អ្នកទទួលសិក្ខាបទយ៉ាងនេះថា ចាប់តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំនឹងមិនសម្លាប់សត្វ

ព្រោះហេតុនៃជីវិតក្តី ខ្ញុំសូមសមាទានការវៀរចាកក្តី គប្បីជ្រាបថា **ជាសមា-ទានវិរតិ** ។ ចំណែកការវៀរចាកដែលសម្បយុត្តដោយមគ្គ របស់ព្រះអរិយសាវកទាំងឡាយ ឈ្មោះថា **សេតុឃាតវិរតិ** ។ ក្នុងវិរតិទាំង ៣ នោះ វិរតិ ២ ដំបូង ធ្វើវត្ថុ មានជីវិតិន្ទ្រិយជាដើម ដែលនឹងត្រូវល្មើសដោយការផ្តាច់បង់ជាដើមឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ វិរតិក្រោយ មានព្រះនិព្វានជាអារម្មណ៍ ។

ក៏ក្នុងវិរតិទាំងនោះ អ្នកណាទទួលសិក្ខាបទទាំង ៥ រួមគ្នា កាលសិក្ខាបទមួយដាច់ធ្លាយ សិក្ខាបទរបស់អ្នកនោះ រមែងដាច់ធ្លាយទៅទាំងអស់ ។ អ្នកណាទទួលម្តងមួយៗ អ្នកនោះកន្លងល្មើសសិក្ខាបទណា សិក្ខាបទនោះប៉ុណ្ណោះដាច់ធ្លាយ ។ ចំណែកសេតុឃាតវិរតិនេះ ដែលឈ្មោះថា ការដាច់មិនមានឡើយ ។ ព្រោះព្រះអរិយសាវកមិនសម្លាប់សត្វ សូម្បីព្រោះហេតុនៃជីវិត ទាំងមិនផឹកទឹកស្រវឹងផង ។ សូម្បីជនផ្សំសុរាជាមួយនឹងទឹកដោះហើយចាក់ចូលទៅក្នុងមាត់របស់ព្រះអរិយសាវកនោះ ទឹកដោះ នោះចូលទៅ ឯសុរាមិនចូលទៅទេ ។ ដូចអ្វី ? ដូចទឹកដោះដែលលាយដោយទឹក ទឹកដោះប៉ុណ្ណោះចូលទៅក្នុងមាត់សត្វក្រោញ ទឹកមិនចូលទៅទេ ។ សេចក្តី

នេះគប្បីជ្រាបថា សម្រេចតាមកំណើត និងគប្បីជ្រាបថា សម្រេចតាមធម្មតា ។

ក៏ក្នុងសរណគមន៍ ឈ្មោះថា ការធ្វើទិដ្ឋិឲ្យត្រង់ ជារបស់ធូន់ , តែក្នុងការសមាទានក្នុងសិក្ខាបទ ត្រឹមតែការវៀរចាកប៉ុណ្ណោះ ព្រោះដូច្នោះ ការសមាទានសិក្ខាបទនោះ ទើបប្រើទ្រព្យតិចជាង និងមានការត្រៀមតិចជាង សម្រាប់អ្នកដែលទទួលល្មមប្រមាណខ្លះ អ្នកដែលទទួលយ៉ាងល្អខ្លះ ។ ក៏ក្នុងការសមាទានសិក្ខាបទនេះ គប្បីជ្រាបថា មានផលច្រើនជាង មានអានិសង្ស ច្រើនជាង ព្រោះដែលឈ្មោះថា ទាន ដូចសីល ៥ នេះ មិនមាន សមពិត ដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ទានទាំង ៥ យ៉ាងនេះ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ដឹងថា ជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថា ជាវង្សត្រកូល ជារបស់មានមកក្នុងកាលមុន មិនមានអ្នកណាវង្វៀស មិនធ្លាប់មានអ្នកណាវង្វៀស ដែលទណោៗ មិនវង្វៀស នឹងមិនវង្វៀស គឺសមណក្តី ព្រាហ្មណ៍ក្តី ដែលបណ្ឌិតមិនតិះដៀល ទាន ៥ យ៉ាង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងធម្មវិន័យនេះ លះបង់បាណាតិបាត ជាអ្នកវៀរចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវកជាអ្នកវៀរចាក

បាណាតិបាត ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវការមិនបៀតបៀនដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យអភ័យ ឲ្យការមិនមានពៀរ ឲ្យការមិនបៀតបៀនដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែកនៃការមិនមានភ័យ នៃការមិនបៀតបៀនមានប្រមាណមិនបានវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ១ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ដឹងថា ជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថា ជាវង្សត្រកូល ជារបស់មានមកក្នុងកាលមុន មិនមាននរណារង្កៀស មិនធ្លាប់មានអ្នកណារង្កៀស ដែលនរណាៗ មិនរង្កៀស នឹងមិនរង្កៀស ពួកសមណក្តី ព្រាហ្មណ៍ក្តីជាបណ្ឌិត មិនតិះដៀលឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងប្រការដទៃនៅមានទៀត អរិយសាវក លះបង់អទិន្នាទាន ។បេ។ លះបង់កាមេសុមិច្ឆាចារ ។បេ។ លះបង់មុសាវាទ ។បេ។ លះបង់ការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។បេ។ ម្នាលភិក្ខុទាំងឡាយ ទាន ៥ ប្រការយ៉ាងនេះឯង ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ។បេ។ បណ្ឌិតរមែងដឹងបានដូច្នេះ ។

ក៏ឯសីល ៥ នេះ លោកហៅថា **យញ្ញ** ព្រោះត្រូវសមាទានដោយគិតថា យើងនឹងលះបង់ការហួងហែងក្នុងខ្លួន និងការហួងហែងក្នុងជីវិត ។ បណ្ដាសីល និងសរណគមន៍នោះ សរណគមន៍នោះ នឹងជាធំជាងសីល ៥ សូម្បីដោយពិត តែសីល ៥ នេះ លោកពោលថា មានផលច្រើនជាង ដោយអំណាចនៃសីលដែលបុគ្គលតាំងនៅក្នុងសរណៈ ហើយរក្សា ។

**[៣៧]** ព្រាហ្មណ៍បានស្ដាប់សូម្បីប្រការនេះហើយ ក៏នៅគិតថា ការរក្សាសីល ៥ ក៏នៅតែជូន់ វត្ថុអ្វីយ៉ាងដទៃទំនងនេះឯង ដែលមានការប្រើទ្រព្យសម្បត្តិតិចជាង និងមានផលច្រើនជាងសីល ៥ នេះ មានឬទេហ្ន៎ ។ លំដាប់នោះ គេកាលនឹងទូលសួរដល់ប្រការនោះ ទើបក្រាបទូលទៀតថា **បពិត្រព្រះគោតមដ៏ចម្រើន ...... មានដែរឬ** ដូច្នេះជាដើម លំដាប់នោះ ព្រះដ៏មានព្រះភាគមានព្រះបំណងនឹងសម្ដែងនូវយញ្ញ មានបឋមឈានជាដើម របស់អ្នកដែលតាំងនៅក្នុងសេចក្ដីបរិបូណ៌ដោយសីល ៣ ប្រការ ជារបស់ប្រើទ្រព្យសម្បត្តិតិចជាង និងមានផលច្រើនជាងដល់ព្រាហ្មណ៍នោះ ទ្រង់ផ្ដើមព្រះធម៌ទេសនា ចាប់ផ្ដើមតាំងពីការឧប្បត្តិឡើងរបស់ព្រះពុទ្ធ ទើបត្រាស់ព្រះតម្រាស់ថា **ម្នាលព្រាហ្មណ៍ ក្នុងលោកនេះ** ដូច្នេះជាដើម ។ ក្នុងសេចក្ដី

នោះ បុគ្គលដែលដល់ព្រមដោយគុណ តាមដែលពោលមកហើយ ក្នុងខាងដើម តាំងនៅក្នុងបឋមឈានជាដើមហើយ ធ្វើទុតិយឈានជាដើមឲ្យកើតរមែងមិនលំបាក ព្រោះដូច្នោះ ឈានទាំងនោះទើបមាន ការប្រើទ្រព្យសម្បត្តិតិច មានការត្រៀមតិច ។ ក៏ក្នុងឈានទាំងនេះ បឋមឈាន រមែងឲ្យអាយុក្នុងព្រហ្មលោក ១ កប្ប , ទុតិយឈាន ៨ កប្ប , តតិយឈាន ៦៤ កប្ប , ចតុត្ថឈាន ៥០០ កប្ប ចតុត្ថឈាននោះឯង ដែលបុគ្គលចម្រើនហើយដោយអំណាចនៃសមាបត្តិ មានអាកាសានញ្ចាយតនៈជាដើម រមែងឲ្យអាយុរហូតដល់អស់ ២០,០០០ កប្ប , ៤០,០០០ កប្ប និង ៨៤,០០០ កប្ប ព្រោះដូច្នោះ ឈានទើបមានផលច្រើនជាង និងមានអានិសង្សច្រើនជាង ។ ក៏ឈាននោះ គប្បីជ្រាបថា ជាយញ្ញ ព្រោះលះបង់ចេញបាននូវធម៌ដែលជាសត្រូវ មាននីវរណៈជាដើម ។

សូម្បីវិបស្សនាញាណ ព្រោះបុគ្គលតាំងនៅហើយក្នុងគុណទាំងឡាយមានចតុត្ថឈានជាបរិយោសាន ឲ្យកើតឡើងហើយ ក៏មិនលំបាក ព្រោះដូច្នោះទើបមានការប្រើទ្រព្យសម្បត្តិតិច មានការត្រៀមតិច ក៏វិបស្សនាញាណនេះមានផលច្រើន ព្រោះមិនមានសុខណាដែលស្មើដូចសុខដែលកើតពីវិបស្សនា

ទ្រង់ត្រាស់ថា យ័ញ្ញ ព្រោះលះបង់ចេញបាននូវកិលេសដែលជាសត្រូវ ។

សម្បីមនោមយិទ្ធិ បុគ្គលតាំងនៅក្នុងវិបស្សនាញាណ ឲ្យកើតឡើងក៏មិនលំបាក ព្រោះដូច្នោះ មនោមយិទ្ធិ ទើបមានការប្រើទ្រព្យសម្បត្តិតិច មានការត្រៀមតិច ឈ្មោះថា មានផលច្រើន ព្រោះអាចនិម្មិតដូចរូបរបស់ខ្លួនបាន ឈ្មោះថា យ័ញ្ញ ព្រោះលះបង់ចេញបាននូវកិលេសដែលជាសត្រូវរបស់ខ្លួន ។ សម្បីញាណ មានឥទ្ធិវិធញ្ញាណជាដើម បុគ្គលតាំងនៅហើយក្នុងមនោមយញ្ញាណជាដើម ឲ្យកើតឡើងហើយក៏មិនលំបាក ព្រោះដូច្នោះ ឥទ្ធិវិធញ្ញាណជាដើម ទើបមានការប្រើទ្រព្យសម្បត្តិតិច មានការត្រៀមតិច ឈ្មោះថា យ័ញ្ញ ព្រោះលះកិលេសដែលជាសត្រូវរបស់ខ្លួនចេញបាន ។

ក៏ក្នុងញាណទាំងនេះ ឥទ្ធិវិធញ្ញាណ គប្បីជ្រាបថា មានផលច្រើន ព្រោះអាចសម្តែងការធ្វើប្លែកៗ មានសភាពផ្សេងៗ ។ ទិព្វសោត គប្បីជ្រាបថាមានផលច្រើន ព្រោះអាចស្តាប់សំឡេងរបស់ទេវតា និងមនុស្សបាន ។ ចេតោបរិយញ្ញាណ គប្បីជ្រាបថា មានផលច្រើន ព្រោះអាចដឹងចិត្ត ១៦ យ៉ាង របស់អ្នកដទៃបាន ។ បុព្វេនិវាសានុស្សតិញ្ញាណ គប្បីជ្រាបថា មានផលច្រើន ព្រោះអាចតាមរលឹកដល់ស្ថានទីដែលខ្លួនប្រាថ្នា នឹងប្រាថ្នាបាន ។

ទិព្វចក្ខុ គប្បីជ្រាបថា មានផលច្រើន ព្រោះអាចមើលឃើញរូបដែលខ្លួនត្រូវការ នឹងប្រាថ្នាបាន ។ អាសវក្ខយញ្ញាណ គប្បីជ្រាបថា មានផលច្រើន ព្រោះអាចញុំាងសុខដែលកើតពីលោកុត្តរមគ្គ ដ៏ប្រណីតក្រៃលែងឲ្យសម្រេចបាន ។ ឈ្មោះថា យញ្ញយ៉ាងដទៃ ដែលប្រសើរជាងព្រះអរហត្តមិនមាន ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្តែងព្រះធម៌ទេសនាឲ្យដល់កំពូល គឺ ព្រះអរហត្ត ទើបត្រាស់ថា ព្រាហ្មណ៍ នេះឯង ដូច្នេះជាដើម ។

## ការសម្តែងខ្លួនជាឧបាសក

[៣៨] បទថា ឯវំ វុត្តេ ប្រែថា កាលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់យ៉ាងនេះហើយ កូដទន្តព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះធម៌ទេសនា មានបំណងនឹងដល់សរណៈ ទើបបានពោលពាក្យនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ ដូច្នេះ ជាដើម ។ បទថា **ចូរបក់** សេចក្តីថា សូមខ្យល់ត្រជាក់រំភើយៗ ដែលរម្ងាប់សេចក្តីខ្វល់ខ្វាយក្នុងរាងកាយបាន ចូរបក់តិចៗ មកប៉ះត្រូវកាយ ។ ក៏ឯព្រាហ្មណ៍ គ្រាពោលពាក្យនេះហើយ ទើបបញ្ជូនមនុស្សទៅ ដោយនិយាយថា នែ៎បា ! អ្នកចូរទៅ ចូលទៅកាន់រោងយ័ញ្ញហើយ ចូរដោះលែងសត្វទាំងពួងនោះពីចំណងចេញ ។ បុរសនោះទទួលពាក្យថា ល្អហើយ បានធ្វើតាមនោះហើយត្រឡប់មកប្រាប់ថា លោកដ៏ចម្រើន សត្វទាំងនោះ រួចពីចំណងអស់ហើយ ដូច្នេះ ។

[៣៩-៤០] ព្រាហ្មណ៍មិនទាន់បានឮការប្រព្រឹត្តទៅនោះ ដរាបណា ព្រះមានព្រះភាគទ្រង់មិនទាន់សម្តែងធម៌ដរាបនោះ ។ ព្រោះក្នុងចិត្តរបស់ព្រាហ្មណ៍នៅមានសេចក្តីសាំញ៉ាំ ។ តែពេលបានឮថា សត្វច្រើនណាស់ត្រាច់ទៅហ្នឹ៎ ខ្ញុំដោះលែងអស់ហើយដូច្នេះ វារចិត្តរបស់ព្រាហ្មណ៍ក៏ថ្លាផូរផង់ ។ ព្រះមាន-

ព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍មានចិត្តថ្លាផូរផង់ហើយ ទើបទ្រង់ផ្តើមព្រះធម៌ទេសនា ។ លោកសំដៅយកព្រះធម៌ទេសនានោះ ទើបពោលពាក្យថា ***លំដាប់នោះឯង ព្រះដ៏មានព្រះភាគ*** ដូច្នេះជាដើម ។ ពាក្យជាដើមថា ចិត្តសមគួរ លោកពោលសំដៅយកនីវរណៈត្រូវគ្របសង្កត់បាន ដោយអានុភាពនៃអនុបុព្វិកថា ។ ពាក្យដ៏សេសមានសេចក្តីងាយយល់ទាំងអស់ ដោយប្រការដូច្នេះឯង ។

ចប់ អដ្ឋកថា កូដទន្តសូត្រទី ៥

# មហាលិសូត្រទី ៦

## ព្រាហ្មណទូតវត្ថុ

[៤១] ឯវម្មេ សុតំ ។ល។ វេសាលិយន្តិ មហាលិសុត្តំ ។ ***ខ្ញុំបាន ស្តាប់មកយ៉ាងនេះ ។***

*ក្នុងមហាលិសូត្រនោះ មានការពណ៌នាតាមលំដាប់បទដូច្នេះ ។ បទថា វេសាលិយំ សេចក្តីថា ជិតនគរដែលបាននាមថា* ***វេសាលី*** *ព្រោះក្រុងនេះ ដល់នូវសេចក្តីវិសាលរឿយៗ ។ បទថា* មហាវនេ *សេចក្តីថា ក្នុងព្រៃធំកើត ឯង តាំងនៅតជាប់នឹងព្រៃហិមពាន្ត ខាងក្រៅនគរ ដែលហៅថា មហាវ័ន ព្រោះជាព្រៃធំនោះ ។ បទថា កូដាគារសាលាយំ សេចក្តីថា បានសាង សង្ឃារាមក្នុងដងព្រៃនោះ ។ បានសាងប្រាសាទដូចនឹងទេវវិមាន ធ្វើតាម បែបកូដាគារសាលា លើកជហ្វាលើសសរទាំងឡាយ ក្នុងសង្ឃារាមនោះ ។ សំដៅដល់ប្រាសាទនោះ សង្ឃារាមសូម្បីទាំងអស់ ទើបប្រាកដថា កូដាគារ- សាលា ។*

*ព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យនគរវេសាលីនោះ ប្រថាប់នៅក្នុង*

សង្ឃារាមនោះ ។

ដោយហេតុនោះ លោកទើបពោលថា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ដូច្នេះ ។

បទថា កោសលកា គឺ អ្នកស្រុកដែនកោសល ។ បទថា មាគធកា គឺ អ្នកស្រុកដែនមគធៈ ។ បទថា ករណីយេន សេចក្តីថា ដោយការងារដែលគប្បីធ្វើពិត ។ ក៏ការងារសូម្បីនឹងមិនធ្វើ ក៏ហៅថា កិច្ចការងារដែលគួរធ្វើពិតតែម្យ៉ាង ឈ្មោះថា **ករណីយ៍** ។

[៤២] បទថា បដិសល្លីនោ ភគវា សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ពួនសម្ងំ គឺ ទ្រង់ពួនសម្ងំពីអារម្មណ៍ផ្សេងៗ ទ្រង់អាស្រ័យនៅតែមួយព្រះអង្គឯង សោយសេចក្តីត្រេកអរក្នុងឈានក្នុងឯកគ្គតារម្មណ៍ ។ បទថា តត្ថេវ គឺ ក្នុងវិហារនោះ ។ បទថា ឯកមន្តំ សេចក្តីថា ព្រាហ្មណ៍ទូតទាំងនោះ មិនលះបង់ទីនោះ នាំគ្នាអង្គុយនៅត្រង់ម្លប់ដើមឈើនោះៗ ។

[៤៣] បទថា ឱដ្ឋទ្ធោ សេចក្តីថា ស្តេចលិច្ឆវី អ្នកមាននាមយ៉ាងនោះ ព្រោះមានបបូរមាត់សើមជោក ។ បទថា មហតិយា លិច្ឆវីបរិសាយ សេចក្តីថា ស្តេចលិច្ឆវី នាមថា **ឱដ្ឋទ្ធ** ថ្វាយទានចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ

ជាប្រធានក្នុងបុរេកត្ត អធិដ្ឋានអដ្ឋង្គឧបោសថសីលក្នុងសំណាក់របស់ព្រះដ៏-
មានព្រះភាគ ឲ្យអ្នកកាន់វត្ថុ មានគ្រឿងក្រអូប និងផ្កាឈើជាដើម ប្រកាស
ឲ្យបរិវារស្ដេចលិច្ឆវីពួកធំប្រជុំគ្នា ហើយចូលទៅព្រមនឹងបរិវារលិច្ឆវីពួកធំ
នោះ ដែលប្រដាប់ដោយសំពត់អាភរណៈ និងគ្រឿងលាបស្រឡាប មានពណ៌
ខៀវ និងលឿងជាដើម ដែលស្អាតល្អ ដូចជាទេវបរិវារជាន់តាវត្តិង្ស ។
បទថា អក្កាលោ ខោ មហាលិ សេចក្ដីថា ឱដ្ឋទ្ធៈនោះ ពីដើមឈ្មោះថា
មហាលិ ព្រះថេរៈហៅមហាលិនោះ តាមឈ្មោះពីដើមនោះ ។ បទថា ឯកមន្តំ
និសីទិ សេចក្ដីថា ឱដ្ឋទ្ធលិច្ឆវីអង្គុយសរសើរព្រះគុណរបស់ព្រះរតនត្រ័យ ព្រម
ដោយបរិវារលិច្ឆវីពួកធំ ក្នុងមូប់ឈើដ៏សមគួរ ។

[៤៤] បទថា សីហោ សមណុទ្ទេសោ សេចក្ដីថា សាមណេរ
ឈ្មោះថា សីហៈ ជាក្មួយរបស់ព្រះនាគិតៈ បួសក្នុងកាលដែលមានអាយុបាន
៧ ខួប ប្រឹងប្រែងព្យាយាមក្នុងព្រះសាសនា ។ បានឮថា សាមណេរឃើញ
ប្រជុំជនធំហើយ ទើបគិតថា ប្រជុំជនពួកធំនេះ អង្គុយពេញវិហារទាំងអស់
ថ្ងៃនេះព្រះដ៏មានព្រះភាគទ្រង់សម្ដែងព្រះធម៌ ដោយព្រះឧស្សាហ៍ធំដល់ប្រជុំជន
នេះពិត បើដូច្នោះ យើងនឹងប្រាប់ព្រះ ឧបជ្ឈាយ៍ឲ្យក្រាបទូលព្រះមានព្រះភាគ

ទ្រង់ជ្រាបដល់ប្រជុំជនពួកធំ មកប្រជុំគ្នាហើយ ទើបចូលទៅរកព្រះនាគិតៈ ។ បទថា ភន្តេ កស្សប សេចក្ដីថា សាមណេរពោលនឹងព្រះថេរៈដោយគោត្រ ។ បទថា ឯសា ជនតា សេចក្ដីថា ជំនុំជននោះ ។ បទថា តុញ្ញេវ ភាវតោ អារោចេហិ សេចក្ដីថា បានឮថា សីហសាមណេរ ជាអ្នកស្និទ្ធស្នាលនឹងព្រះមានព្រះភាគ ក៏ព្រះថេរៈនេះធាត់ ក្នុងការដែលនឹងក្រោក ឬអង្គុយជាដើម ក៏ទទើសទទែង ព្រោះព្រះថេរៈមានរាងកាយធ្ងន់ ទើបមើលហាក់បីដូចជាដើរញ័រៗ ដោយហេតុនោះ សាមណេរនេះ ទើបបានធ្វើវត្តថ្វាយព្រះដ៏មាន-ព្រះភាគគ្រប់វេលា ព្រោះហេតុនោះ ព្រះថេរៈទើបពោលនឹងសាមណេរនោះថា សូម្បីលោកក៏ជាអ្នកប្រោសប្រាណរបស់ព្រះទសពល ទើបពោលថា លោកនោះឯងទៅក្រាបទូលឲ្យទ្រង់ជ្រាប ដូច្នេះ ។

បទថា វិហារបច្ឆាយាយំ សេចក្ដីថា ក្រោមម្លប់របស់ព្រះវិហារ អធិប្បាយថា ក្នុងឱកាសនៃស្រមោលកូដាគារ ខ្នងធំជះទៅដល់ ។ បានឮថា កូដាគារសាលានោះ មានបណ្ដោយទៅផ្លូវទិសខាងត្បូង និងទិសឧត្តរ មានមុខបែរទៅទិសខាងកើត ។ ដោយហេតុនោះ ម្លប់ធំ ទើបជះទៅខាងមុខនៃកូដាគារសាលានោះ ។ សូម្បីសីហសាមណេរ បានក្រាលអាសនៈថ្វាយ

ព្រះមានព្រះភាគត្រង់ម្លប់ខាងមុខវិហារនោះ ។ លំដាប់នោះឯង ព្រះដ៏មាន-ព្រះភាគទ្រង់មានព្រះពុទ្ធរង្សី ៦ ប្រការ បញ្ចេញរស្មីចេញពីប្រហោងទ្វារ និងប្រហោងបង្អួច ស្តេចចេញចាកកូដាគារសាលា ដូចព្រះចន្ទពេញវង់ចេញ ចាកស្រទាប់ពពកដូច្នោះ ប្រថាប់គង់លើវរពុទ្ធាសនៈដែលក្រាលទុកហើយ ។ ដោយហេតុនោះ លោកទើបពោលថា **លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ស្តេចចេញចាកព្រះវិហារ ប្រថាប់គង់លើអាសនៈដែលក្រាលទុកហើយ ក្រោម ម្លប់ខាងមុខព្រះវិហារ** ។

**[៤៥]** ក្នុងបទថា បុរិមានិ ភន្តេ ទិវសានិ បុរិមតរានិ នេះ សេចក្តីថា ថ្ងៃម្សិលមិញ ឈ្មោះថាថ្ងៃមុន ថ្ងៃដទៃតពីថ្ងៃនោះ ឈ្មោះថា ម្សិលម្ង៉ៃ ក៏តាំងពីថ្ងៃនោះទាំងអស់ចាត់ជាថ្ងៃមុនៗ ។ បទថា យទគ្គេ សេចក្តីថា ខ្ញុំនៅតាំងពីថ្ងៃដំបូង ។ លោកពោលថា ខ្ញុំនៅមួយរយៈ ។ ឥឡូវនេះ សុនក្ខត្តលិច្ឆវីបុត្រ កាលនឹងសម្តែងប្រមាណនៃថ្ងៃនោះ ទើបពោលថា មិន យូរត្រឹមតែ ៣ ឆ្នាំ ។ ប្រការមួយទៀត បទថា យទគ្គេ សេចក្តីថា ខ្ញុំនៅ មួយរយៈមិនយូរ ត្រឹមតែ ៣ ឆ្នាំ ។ លោកពោលថា ខ្ញុំនៅមួយរយៈមិន យូរត្រឹមតែ ៣ ឆ្នាំប៉ុណ្ណោះ ។ បានឮថា សុនក្ខត្តលិច្ឆវីបុត្រនេះ ទទួលបាត្រ

និងចីវររបស់ព្រះដ៏មានព្រះភាគ ប្រណិបត្តិព្រះដ៏មានព្រះភាគរហូតដល់អស់ ៣ ឆ្នាំ ។ សុនក្ខត្តលិច្ឆវីបុត្រសំដៅដល់ ៣ ឆ្នាំនោះ ទើបពោលយ៉ាងនេះ ។ បទថា បិយរូបានិ បានដល់ គួរស្រឡាញ់ គឺ គួរត្រេកអរ ។ បទថា កាមូបសញ្ហិតានិ គឺ ប្រកបដោយសេចក្តីត្រេកអរក្នុងកាម ។ បទថា រជនីយានិ សេចក្តីថា ធ្វើឲ្យកើតរាគៈ ។

[៤៦] បទថា ណោ ច ខោ ទិព្វានិ សទ្ទានិ សេចក្តីថា សុនក្ខត្តៈស្តាប់សំឡេងទិព្វ ទាំងនោះមិនបាន ព្រោះហេតុអ្វី បានឮថា សុនក្ខត្តៈនោះចូលទៅគាល់ ព្រះដ៏មានព្រះភាគ ហើយទូលសូមបរិកម្មទិព្វចក្ខុ ។ ព្រះមាន-ព្រះភាគត្រាស់ប្រាប់ដល់គេ ។ គេបានបដិបត្តិតាមដែលទ្រង់ទូន្មាន ញុំាងទិព្វចក្ខុឲ្យកើតឡើង ឃើញរូបទាំងឡាយ និងទេវតាទាំងឡាយ ហើយគិតថា ក្នុងសរីរៈសណ្ឋាននេះ គប្បីមានសំឡេងពីរោះ យើងគប្បីស្តាប់សំឡេងនោះបានយ៉ាងណាហ្ន៎ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ ទូលសួរដល់ការបរិកម្មទិព្វសោត ។ ក៏ក្នុងអតីតកាល សុនក្ខត្តៈនេះវាយក្បាលត្របៀកភិក្ខុមានសីលមួយរូបធ្វើឲ្យបង់ ព្រោះដូច្នោះ សូម្បីនឹងធ្វើបរិកម្ម ក៏មិនអាចសម្រេចដល់ទិព្វសោតបាន ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបមិនត្រាស់

ប្រាប់បរិកម្ម ។ គេចងអាឃាតក្នុងព្រះដ៏មានព្រះភាគ ដោយហេតុត្រឹមតែប៉ុណ្ណេះ ទើបគិតថា ព្រះតម្រិះយ៉ាងនេះ រមែងមានដល់ព្រះសមណគោតមពិតថា សូម្បីយើងក៏ជាក្សត្រិយ៍ ឱដ្ឋទ្ធៈនេះក៏ជាក្សត្រិយ៍ បើញាណនឹងចម្រើនដល់គេ សូម្បីគេក៏នឹងជាសព្វញ្ញូ ព្រោះហេតុនោះ ទើបមិនត្រាស់ប្រាប់ដល់យើង ព្រោះសេចក្ដីឫស្យា ។ គេក៏ដល់កាពជាគ្រហស្ថដោយលំដាប់កាលនឹងប្រាប់សេចក្ដីនោះដល់មហាលិលិច្ឆវី ទើបពោលយ៉ាងនេះ ។

បទថា ឯកំសភាវិតោ សេចក្ដីថា មានសមាធិដែលបានអប់រំហើយតែម្យ៉ាង គឺ ចំណែកមួយ អធិប្បាយថា អប់រំដើម្បីត្រូវការនឹងឃើញរូបដែលជាទិព្វ ឬដើម្បីត្រូវការនឹងបានស្ដាប់សំឡេងដែលជាទិព្វ ។

**[៤៧-៤៩]** បទថា តិរិយំ សេចក្ដីថា ទិសទទឹង គឺ ទិសតូចៗ ។

**[៥០]** បទថា ឧភយំសភាវិតោ សេចក្ដីថា មានសមាធិបានអប់រំហើយទាំងពីរចំណែក គឺ កោដ្ឋាសៈទាំងពីរ ។

**[៥១]** បទថា អយំ ខោ មហាលិ ហេតុ សេចក្ដីថា សមាធិដែលសុនក្ខត្តៈអប់រំហើយចំណែកមួយ ដើម្បីឃើញរូបទាំងឡាយដែលជាទិព្វប៉ុណ្ណោះនេះជាហេតុ ។

លិច្ឆវីនោះ បានស្តាប់អត្ថនេះហើយ ទើបគិតថា ភិក្ខុស្តាប់សំឡេងនេះដោយទិព្វសោត ទិព្វសោតជារបស់ប្រសើរ ជារបស់មានប្រយោជន៍ក្នុងសាសនានេះពិត ភិក្ខុទាំងនោះប្រព្រឹត្តព្រហ្មចរិយៈ ៥០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ មិនមែនតិច ដើម្បីប្រយោជន៍ដល់ទិព្វសោតនេះឬហ្ន៎ បើដូច្នោះ យើងគប្បីទូលសួរសេចក្តីនេះចំពោះព្រះទសពល ។

**[៥២]** តអំពីនោះ កាលនឹងទូលសួរសេចក្តីនោះ ទើបក្រាបទូលថា ឯតាសំ នូន ភន្តេ ជាដើម ។ ក្នុងបទថា សមាធិភាវនានំ នេះ សមាធិនោះឯងឈ្មោះថា សមាធិភាវនា សេចក្តីថា សមាធិដែលបានអប់រំហើយទាំងពីរចំណែក ។

មួយទៀត ព្រោះសមាធិភាវនាទាំងនោះ ជារបស់ក្រៅសាសនា មិនប្រព្រឹត្តទៅក្នុងខាងក្នុង ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ទើបបដិសេធសមាធិភាវនាទាំងនោះ កាលនឹងទ្រង់សម្តែងប្រយោជន៍ ដែលភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ទើបត្រាស់ថា ន ខោ មហាលិ ជាដើម ។

## ផលដ៏ប្រសើរ ៤

*បទថា* តិណ្ណំ សំយោជនានំ *បានដល់ សញ្ញោជនៈ ជាគ្រឿងចង បីយ៉ាង មានសក្កាយទិដ្ឋិជាដើម ។ ពិតណាស់ សញ្ញោជនៈទាំងនោះ លោកហៅថា សញ្ញោជនៈ ព្រោះជាគ្រឿងចងសត្វទាំងឡាយ ទុកក្នុងវដ្ដ (គឺភព) ដែលដល់ហើយដោយវដ្ដទុក្ខ ។*

*បទថា* សោតាបន្នោ ហោតិ *សេចក្ដីថា ជាអ្នកដល់ក្រសែនៃមគ្គ ។ បទថា* អវិនិបាតធម្មោ *គឺ មានការមិនធ្លាក់ទៅក្នុងអបាយទាំង ៤ ជាធម្មតា ។*

*បទថា* និយតោ *គឺ អ្នកប្រាកដហើយដោយធម្មនិយាម ។ បទថា* សម្ពោធិបរាយនោ *សេចក្ដីថា ការត្រាស់ដឹង ពោលគឺ មគ្គខាងលើ ៣ យ៉ាង ដែលភិក្ខុនោះគប្បីសម្រេចជាទីទៅក្នុងខាងមុខ ព្រោះដូច្នោះ ភិក្ខុនោះទើបឈ្មោះថា អ្នកមានការត្រាស់ដឹងជាទីទៅក្នុងខាងមុខ ។*

**[៥៣]** *បទថា* តនុត្តា *សេចក្ដីថា ព្រោះកិលេសជាគ្រឿងរួបរឹតចិត្តមានតិច និងព្រោះការឧប្បត្តិក្នុងលោកណា ក្នុងកាលណា ជារបស់ស្រាលខ្លះ ។*

[៥៤] បទថា ឱរម្ភាគិយានំ សេចក្ដីថា សញ្ញោជនៈចំណែកខាងក្រោម ដែលជាគ្រឿងចង មិនឲ្យកើតក្នុងភូមិសុទ្ធាវាសជាន់ខ្ពស់ ។ ពាក្យថា ឱបបាតិកោ នោះ ជាពាក្យបដិសេធកំណើតដ៏សេស ។ ក្នុងបទទាំងនោះ បទថា បរិនិព្វាយី គឺ មាននិព្វានធម៌ក្នុងភពខាងមុខនោះដ៏ពិតប្រាកដ ។ បទថា អនាវត្តិធម្មោ សេចក្ដីថា មានការមិនត្រឡប់មកពីព្រហ្មលោកនោះមកកើតទៀតជាធម្មតា ។

[៥៥] បទថា ចេតោវិមុត្តិំ គឺ ចិត្តវិសុទ្ធិ ។ ពាក្យនោះ ជាឈ្មោះនៃអរហត្តផលចិត្ត ដែលរួចផុតចាកគ្រឿងចង គឺ កិលេសទាំងពួង , បញ្ញា គឺ អរហត្តផលនោះឯង ដែលរួចផុតចាកពីគ្រឿងចង គឺ កិលេសទាំងពួង គប្បីជ្រាបថា បញ្ញាវិមុត្តិ សូម្បីក្នុងបទថា បញ្ញាវិមុត្តិំ នេះ ។ បទថា ទិដ្ឋេវ ធម្មេ គឺ ក្នុងអត្តភាពនេះឯង ។ បទថា សយំ គឺ ខ្លួនឯង ។ បទថា អភិញ្ញា គឺ ដឹងយ៉ាងក្រៃលែង ។ បទថា សច្ឆិកត្វា គឺ ធ្វើឲ្យប្រចក្ស ។ មួយទៀត បទថា អភិញ្ញា សច្ឆិកត្វា សេចក្ដីថា ធ្វើឲ្យច្បាស់ដោយអភិញ្ញា គឺ ដោយញាណដែលល្អិតល្អន់យ៉ាងក្រៃលែង ដូច្នេះក៏មាន ។ បទថា ឧបសម្បជ្ជ គឺ សម្រេចហើយ បានដល់ បានទទួលហើយ ។ ស្ដេចលិច្ឆវីបានស្ដាប់អត្ថ

នេះហើយ ទើបគិតថា ធម៌ដ៏ប្រសើរដែលនរណាៗ មិនអាចនឹងសម្រេចបាន ដូចសត្វហើរខ្វះ ដូចសត្វទន្សោងលូនទៅដោយទ្រូងខ្វះ សម្រាប់កិច្ចសម្រេចព្រះធម៌នេះ នឹងគប្បីមានវត្តបដិបត្តិក្នុងចំណែកខាងដើមពិត យើងនឹងទូលសួរដល់ព្រះធម៌នោះមុន ។

# អរិយមគ្គប្រកបដោយអង្គ ៨

[៨៦] អំពីនោះ កាលនឹងទូលសួរព្រះដ៏មានព្រះភាគ ទើបទូលថា អត្ថិ បន ភន្តេ ដូច្នេះជាដើម ។ បទថា អដ្ឋង្គិកោ សេចក្ដីថា មគ្គប្រកបដោយអង្គ ៨ ដូចតន្ត្រីប្រកបដោយអង្គ ៥ និងដូចស្រុកប្រកបដោយត្រកូល ៨ ទើបឈ្មោះថា ប្រកបដោយអង្គ ៨ ធម្មតាមគ្គដទៃចាកអង្គមិនមាន ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ដូច្នេះ ។

ក្នុងមគ្គមានអង្គ ៨ នោះ សម្មាទិដ្ឋិ មានលក្ខណៈឃើញត្រូវ ។ សម្មាសង្កប្បៈ មានលក្ខណៈបង្អោនទឹកត្រូវ ។ សម្មាវាចា មានលក្ខណៈពិចារណាត្រូវ ។ សម្មាកម្មន្តៈ មានលក្ខណៈតាំងមាំត្រូវ ។ សម្មាអាជីវៈ មានលក្ខណៈឲ្យផូរផង់ត្រូវ ។ សម្មាវាយាមៈ មានលក្ខណៈព្យាយាមត្រូវ ។ សម្មាសតិ មានលក្ខណៈរឭកត្រូវ ។ សម្មាសមាធិ មានលក្ខណៈតម្កល់ចិត្តត្រូវ ។ ក្នុងមគ្គមានអង្គ ៨ ទាំងនោះ អង្គមួយៗ មានកិច្ច ៣ យ៉ាង គឺ សម្មាទិដ្ឋិរមែងលះមិច្ឆាទិដ្ឋិព្រមទាំងកិលេស ដែលជាសត្រូវដល់ខ្លួន មែង

ធ្វើនិរោធឲ្យជាអារម្មណ៍ និងឃើញច្បាស់នូវសម្បយុត្តធម៌ទាំងឡាយ ព្រោះមិនវង្វេង ដោយអំណាចកម្ចាត់មោហៈ ដែលបិទបាំងការឃើញត្រូវនោះ ។ ធម៌ទាំងឡាយ សូម្បីមានសម្មាសង្កប្បៈជាដើម រមែងលះមិច្ឆាសង្កប្បៈជាដើម និងធ្វើនិរោធឲ្យជាអារម្មណ៍ដូចគ្នានោះឯង ។ ក៏ក្នុងទីនេះ ដោយពិសេស សម្មាសង្កប្បៈ រមែងបង្អោនទឹកដល់សហជាតធម៌ទាំងឡាយ សម្មាវាចា រមែងពិគ្រោះដោយប្រពៃ , សម្មាកម្មន្តៈ រមែងឲ្យតាំងមាំដោយប្រពៃ , សម្មាអាជីវៈ រមែងធ្វើឲ្យផូរផង់ដោយប្រពៃ , សម្មាវាយាមៈ រមែងផ្គងដោយប្រពៃ , សម្មាសតិ រមែងឲ្យចូលទៅតាំងនៅដោយប្រពៃ , សម្មាសមាធិ រមែងតម្កល់ចិត្តដោយប្រពៃ ។

ម្យ៉ាងទៀត ធម្មតាសម្មាទិដ្ឋិនោះ ក្នុងចំណែកបុព្វភាគ មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា , ក្នុងខណៈនៃមគ្គ មានខណៈតែមួយ មានអារម្មណ៍តែមួយ តែដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាង មានញាណក្នុងទុក្ខជាដើម ធម៌ទាំងឡាយសូម្បីមានសម្មាសង្កប្បៈជាដើម ក្នុងចំណែកបុព្វភាគ មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា ក្នុងខណៈនៃមគ្គ មានខណៈតែមួយ មានអារម្មណ៍តែមួយ ។ ក្នុងធម៌ទាំងនោះ សម្មាសង្កប្បៈ

ដោយកិច្ច រមែងបានឈ្មោះ ៣ យ៉ាង មាននេក្ខម្មសង្កប្បៈជាដើម ។ ធម៌ ៣ យ៉ាង មានសម្មាវាចាជាដើម ជាវិរតិខ្លះ ជាចេតនាខ្លះ តែក្នុងខណៈនៃមគ្គ ជាវិរតិតែម្យ៉ាង ។ អង្គពីរសូម្បីនេះ គឺ សម្មាវាយាមៈ សម្មាសតិ ដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចសម្មប្បធាន និងសតិប្បដ្ឋាន ។ ចំណែកសម្មាសមាធិ ក្នុងខណៈបុព្វភាគក្តី ក្នុងខណៈនៃមគ្គក្តី រមែងជាសម្មាសមាធិតែម្យ៉ាង ។

ក្នុងធម៌ ៨ យ៉ាងនេះ សម្មាទិដ្ឋិ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងមុន ព្រោះសម្មាទិដ្ឋិជាធម៌មានឧបការៈច្រើនដល់ព្រះយោគីអ្នកបដិបត្តិដើម្បីសម្រេចនិព្វាន ។ ក៏បញ្ញានេះ លោកពោលថា បញ្ញាបជ្ជោតៈ និងបញ្ញាសត្ថៈ ព្រោះដូច្នោះ ព្រះយោគាវចរ ទើបកម្ចាត់សេចក្តីងងឹត គឺ អវិជ្ជា ដោយសម្មាទិដ្ឋិ ពោលគឺ វិបស្សនាញាណក្នុងបុព្វភាគនោះ សម្លាប់ចោរ គឺ កិលេស សម្រេចនិព្វានដោយខេមៈ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងសម្មាទិដ្ឋិមុន ព្រោះសម្មាទិដ្ឋិ ជាធម៌មានឧបការៈច្រើនដល់ព្រះយោគី អ្នកបដិបត្តិដើម្បីសម្រេចនិព្វាន ។

ក៏សម្មាសង្កប្បៈ មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ ព្រោះហេតុ

នោះ ព្រះដ៏មានព្រះភាគទើបត្រាស់ទុកក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ ។ ដូច ហិរញ្ញិកយកដៃត្រឡប់ទៅត្រឡប់មក សម្លឹងមើលកហាបណៈដោយភ្នែក រមែងដឹងថា កហាបណៈនេះក្លែងក្លាយ នេះពិត យ៉ាងណា សូម្បីព្រះយោ-គាវចរក៏យ៉ាងនោះ ក្នុងបុព្វភាគត្រិះរិះដោយវិតក្កៈ សម្លឹងមើលដោយវិបស្សនាបញ្ញា រមែងដឹងថា ធម៌ទាំងនេះជាកាមាវចរ ទាំងនេះជារូបាវចរជាដើម ។ ឬក៏ដូចជាងចាំង ចាំងឈើធំ ហើយចាប់ចុងត្រឡប់ទៅត្រឡប់មកដោយពូថៅ រមែងនាំទៅប្រើការងារបាន យ៉ាងណា ព្រះយោគាវចរកំណត់ធម៌ទាំងឡាយ ដែលវិតក្កត្រិះរិះឲ្យហើយ ដោយន័យថា ធម៌ទាំងនេះជាកាមាវចរ ទាំងនេះជារូបាវចរជាដើម ដោយបញ្ញា រមែងនាំទៅប្រើការងារបានដូច្នោះ ។ ដោយហេតុនោះ លោកទើបពោលថា ក៏សម្មាសង្កប្បៈមានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ទុកក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ ដូច្នេះ ។ សម្មាសង្កប្បៈនេះ ក៏មានឧបការៈសូម្បីដល់សម្មាវាចា ដូចមានឧបការៈដល់សម្មាទិដ្ឋិដូច្នោះ ។ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា គហបតិ ត្រិះរិះមុនហើយ ទើបថ្លែងវាចាក្នុងខាងក្រោយ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់សម្មាវាចាក្នុង

លំដាប់នៃសម្មាសង្កប្បៈនោះ ។

ក៏ព្រោះអ្នកទាំងឡាយត្រៀមដោយវាចាមុនថា យើងនឹងធ្វើការងារនេះ និងការងារនេះ ហើយទើបប្រកបការងារទាំងឡាយក្នុងលោក ព្រោះដូច្នោះ វាចាទើបជាឧបការៈដល់កាយកម្ម ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់សម្មាកម្មន្តៈក្នុងលំដាប់នៃសម្មាវាចា ។

ក៏អាជីវដ្ឋមកសីល រមែងបរិបូណ៌ដល់បុគ្គលដែលលះវចីទុច្ចរិត ៤ យ៉ាង និងកាយទុច្ចរិត ៣ យ៉ាង បំពេញសុចរិតទាំង ២ យ៉ាងប៉ុណ្ណោះ រកបរិបូណ៌ដល់បុគ្គលក្រៅពីនេះមិនមាន ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់សម្មាអាជីវៈក្នុងលំដាប់នៃសុចរិតទាំង ២ នោះ ។

មួយទៀត បុគ្គលមានអាជីវៈបរិសុទ្ធិយ៉ាងនេះ ធ្វើសេចក្តីត្រេកអរដោយហេតុត្រឹមប៉ុណ្ណេះថា អាជីវៈរបស់យើងបរិសុទ្ធិហើយ មិនគួរនៅដូចជាអ្នកដេកលក់ ឬអ្នកប្រមាទដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់សម្មាវាយាមៈក្នុងលំដាប់នៃសម្មាអាជីវៈនោះ ដើម្បីទ្រង់សម្តែងថា បុគ្គលគួរប្រារព្ធសេចក្តីព្យាយាមនេះក្នុងគ្រប់ឥរិយាបថ ។ តអំពីនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងសម្មាសតិក្នុងលំដាប់នៃសម្មាវាយាមៈនោះ ដើម្បីទ្រង់សម្តែងថា

សតិដែលតាំងមាំល្អហើយក្នុងវត្ថុទាំង ៤ មានកាយជាដើម សូម្បីបុគ្គលដែលប្រាថ្នាសេចក្ដីព្យាយាមហើយក៏គួរធ្វើ ។ ក៏ព្រោះសតិដែលតាំងមាំល្អហើយយ៉ាងនេះ រមែងជំនួយដល់គតិនៃធម៌ទាំងឡាយ ដែលឧបការៈដល់សមាធិគ្រប់គ្រាន់ដើម្បីចិត្តតាំងមាំក្នុងឯកគ្គតារម្មណ៍ ព្រោះដូច្នោះ គប្បីជ្រាបថាព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងសម្មាសមាធិក្នុងលំដាប់នៃសម្មាសតិ ។

បទថា ឯតេសំ ធម្មានំ សច្ឆិកិរិយាយ សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យប្រចក្សដល់ធម៌ មានសោតាបត្តិផលជាដើមទាំងនេះ ។

# រឿងបព្វជិត ២ រូប

[៨៧] បទថា ឯកមិទាហំ នេះ ព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធ ព្រោះហេតុអ្វី ។

បានឮថា ព្រះរាជានេះ មានលទ្ធិយ៉ាងនេះថា រូបជាខ្លួន ។ ដោយហេតុនោះ ចិត្តរបស់ព្រះរាជានោះ ទើបមិនបង្អោនទៅក្នុងទេសនា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ប្រារព្ធដល់សេចក្តីនេះ ដើម្បីទ្រង់នាំមកនូវហេតុការណ៍មួយ ដើម្បីទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលទ្ធិរបស់ព្រះរាជានោះ ។ ក្នុងរឿងនោះ មានសេចក្តីដោយសង្ខេបដូច្នេះ ។ សម័យមួយ តថាគតនៅក្នុងឃោសិតារាម គ្រានោះបព្វជិតពីររូបនោះ សួរតថាគតយ៉ាងនេះ ។ លំដាប់នោះ តថាគតទើបសម្តែងដល់ការកើតឡើងរបស់ព្រះពុទ្ធ ដល់បព្វជិតទាំងនោះ កាលនឹងសម្តែងតន្តិធម៌ ទើបបានត្រាស់ប្រការនេះថា អ្នកមានអាយុ កុលបុត្រអ្នកឈ្មោះថា ដល់ព្រមដោយសទ្ធាបួសក្នុងសាសនា របស់ព្រះ-សាស្តាបែបនេះ បំពេញសីល ៣ យ៉ាង សម្រេចដល់ឈាន មានបឋមឈានជាដើម តាំងនៅយ៉ាងនេះ គប្បីពោលពាក្យជាដើមថា ជីវៈនោះ ពាក្យនោះ

*សមគួរដល់កុលបុត្រនោះឬហ្ន៎ ។ លំដាប់នោះ លុះបព្វជិតទាំងពីរនាក់នោះពោលថា សមគួរ ក៏តថាគតបានជំទាស់វាទៈនោះថា អ្នកមានអាយុ សេចក្ដីនេះតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ដូច្នោះឯង តថាគតទើបមិនពោលយ៉ាងនេះ ហើយសម្ដែងព្រះឧីណាស្រេចឲ្យក្រៃលែងៗ ឡើងទៅ ប្រាប់ដល់កុលបុត្រនេះថា មិនគួរពោលយ៉ាងនេះ បព្វជិតទាំងនោះ ស្ដាប់ពាក្យនិយាយរបស់តថាគតហើយ ជាអ្នកមានចិត្តត្រេកអរ ដូច្នេះ ។ លុះព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះរាជានោះ ក៏មានចិត្តត្រេកអរ ។ ដោយហេតុនោះលោកទើបពោល ព្រះដ៏មានព្រះភាគបានត្រាស់វេយ្យាករណវចនៈនេះហើយ ឱដ្ឋទ្ធលិច្ឆវី មានចិត្តត្រេកអរ លើកសរសើរភាសិតរបស់ព្រះដ៏មានព្រះភាគ ។*

ចប់ អដ្ឋកថាមហាលិស្សូត្រទី ៦

# ជាលិយសូត្រ ទី ៧

## (អដ្ឋកថាដើមមិនចាន់ប្រែទុក)

[៥៨] *ជាលិយសូត្រថា* ***ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ ក្នុងក្រុងកោសម្ពី*** *ជាដើម ។ ក្នុងជាលិយសូត្រនោះ មានការពណ៌នាតាមលំដាប់បទដូចតទៅនេះ ៖*

*បទថា ឃោសិតារាមេ សេចក្តីថា ក្នុងអារាមដែលឃោសិតសេដ្ឋីសាងថ្វាយ ។*

*បានឮថា ក្នុងកាលមុន មាននគរមួយកន្លែងឈ្មោះ* ***ទមិឡរដ្ឋ*** *។ ចេញពីនគរនោះ បុរសក្រខ្សត់ឈ្មោះ* ***កោតូហលិក*** *ព្រមនឹងបុត្រ និងភរិយាគេចចេញទៅកាន់អវន្តីរដ្ឋ ព្រោះឆាតកភ័យ កាលមិនអាចនាំបុត្រទៅបាន ទើបចោលបុត្រនោះ ហើយធ្វើដំណើរតទៅ ។ មាតាត្រឡប់ទៅទទួលយកបុត្រនោះ ។ គេទើបនាំគ្នាទៅកាន់ស្រុកនាយគោបាលមួយកន្លែង ។ ក៏ក្នុងកាលនោះ នាយគោបាលបានត្រៀមបាយបាយាសទុកច្រើន ។ គេបានបរិភោគបាយបាយាសនោះ ។ លំដាប់នោះឯង បុរសនោះបរិភោគបាយបាយាសច្រើន*

មិនអាចនឹងឲ្យរលួយបាន ដល់ពេលយប់ក៏បានស្លាប់ទៅ ចាប់បដិសន្ធិក្នុងពោះមេសុនខ កើតជាកូនសុនខតូចក្នុងផ្ទះនាយគោបាលនោះ ។ កូនសុនខតូចនោះ ជាទីស្រឡាញ់របស់នាយគោបាល ហើយនាយគោបាលជាអ្នកទំនុកបម្រុងឧបដ្ឋាកព្រះបច្ចេកពុទ្ធ ។ ចំណែកព្រះបច្ចេកពុទ្ធ ក៏ឲ្យដុំបាយមួយដុំៗដល់កូនសុនខតូចក្នុងកាលសម្រេចភត្តកិច្ច ។ កូនសុនខតូចនោះ កើតមានសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ទើបទៅកាន់បណ្ណសាលាជាមួយនឹងនាយគោបាល ។ កាលនាយគោបាលមិនប្រើទៅ ក៏ទៅដោយខ្លួនឯង ក្នុងវេលាភត្ត គាល់នៅត្រង់ទ្វារបណ្ណសាលា ដើម្បីរង់ចាំវេលា និងសម្គាល់មើលសត្វសាហាវក្នុងចន្លោះផ្លូវ ធ្វើឲ្យសត្វសាហាវគេចចេញទៅ ។ សុនខតូចនោះស្លាប់ទៅកើត ក្នុងទេវលោកដោយចិត្តបង្អោនក្នុងព្រះបច្ចេកពុទ្ធ ។ ក្នុងទេវលោកនោះ គេទើបមានឈ្មោះថា ឃោសកទេវបុត្រ ។ ឃោសកទេវ-បុត្រនោះ ចុតិចាកទេវលោកនោះ ហើយទៅកើតក្នុងផ្ទះស្រ្តីកុលមួយក្នុងក្រុងកោសម្ពី ។ សេដ្ឋីមិនមានបុត្រ បានឲ្យទ្រព្យដល់បិតាមាតារបស់ទារកនោះ ។ ទទួលគេជាបុត្រ ។ តមក ពេលបុត្ររបស់ខ្លួនកើត សេដ្ឋីក៏ព្យាយាមឲ្យសម្លាប់គេអស់ ៧ ដង ។ គេក៏មិនដល់សេចក្តីស្លាប់ក្នុងទីទាំង ៧ កន្លែង

ព្រោះតម្លៃដែលខ្លួនជាអ្នកមានបុណ្យ ក្នុងទីបំផុតក៏បានជីវិតរួចមក ព្រោះការជួយជ្រោមជ្រែងរបស់សេដ្ឋីធីតាម្នាក់ ។ ក្នុងកាលតមក កាលបិតាស្លាប់ទៅ គេទើបបានទទួលតំណែងសេដ្ឋី ឈ្មោះថា ឃោសិតសេដ្ឋី ។

ក៏ក្នុងក្រុងកោសម្ពីនៅមានសេដ្ឋីពីរនាក់ទៀត គឺ កុក្កុដសេដ្ឋី និងបាវារិកសេដ្ឋី រួមជា ៣ អ្នក នឹងឃោសិតសេដ្ឋីនេះ ។ ក៏ដោយសម័យនោះតាបស ៥០០ ដែលមកពីព្រៃហិមពាន្ត នាំគ្នាទៅកាន់ក្រុងកោសម្ពី ដើម្បីហាលអាកាសអប់កំដៅ ។ សេដ្ឋីបីអ្នកនោះ បានសាងបណ្ណកុដិក្នុងឧទ្យានរៀងៗ ខ្លួន ធ្វើការទំនុកបម្រុងដល់តាបសទាំងនោះ ។ នៅថ្ងៃមួយ តាបសទាំងនោះមកពីព្រៃហិមពាន្ត បានទទួលភាពត្រជាក់ព្រោះលំបាកក្នុងផ្លូវកន្តារច្រើន ដល់ដើមជ្រៃធំមួយដើម នាំគ្នាអង្គុយចាំទទួលការសង្គ្រោះពីសំណាក់របស់ទេវតាដែលស្ថិតនៅនឹងដើមជ្រៃនោះ ។ ទេវតាបានបពេញដៃដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ឲ្យវត្ថុ មានទឹកផឹក ទឹកប្រើជាដើម ដល់តាបសទាំងនោះបន្ទោបង់សេចក្ដីលំបាក ។ តាបសទាំងនោះរីករាយដោយអានុភាពនៃទេវតា ទើបសួរថា បពិត្រទេវៈ លោកធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ ។ ទេវតាពោលថា ព្រះដ៏មានព្រះភាគ ព្រះនាមថា **ពុទ្ធៈ** បាន

កើតហើយក្នុងលោក ឥឡូវនេះ ព្រះអង្គប្រថាប់នៅក្នុងក្រុងសាវត្ថី អនាថ-បិណ្ឌិកគហបតីទំនុកបម្រុងព្រះដ៏មានព្រះភាគអង្គនោះ ក្នុងថ្ងៃឧបោសថទាំងឡាយ លោកអនាថបិណ្ឌិកៈឲ្យកត្ត និងតម្លៃឈ្នួលតាមប្រក្រតីដល់កូនឈ្នួលរបស់ខ្លួន ហើយឲ្យរក្សាឧបោសថសីល នៅថ្ងៃមួយក្នុងវេលាថ្ងៃត្រង់ ខ្ញុំមកដើម្បីប្រយោជន៍ដល់អាហារព្រឹក បានឃើញអនាថបិណ្ឌិកៈមិនធ្វើការងារជាប់ទាក់ទងនឹងកូនឈ្នួលអ្វីឡើយ ទើបសួរថា ក្នុងថ្ងៃនេះមនុស្សទាំងឡាយមិនធ្វើការងារព្រោះហេតុអ្វី គេទាំងនោះបានប្រាប់សេចក្តីនោះដល់ខ្ញុំ លំដាប់នោះ ខ្ញុំទើបពោលពាក្យនេះថា ឥឡូវនេះបានកន្លងទៅកន្លះថ្ងៃហើយ ខ្ញុំអាចរក្សាឧបោសថកន្លះថ្ងៃបានឬហ្ន៎ លោកសេដ្ឋីសប្បាយចិត្ត ហើយនិយាយថាអាចរក្សាបាន ខ្ញុំនោះទើបបានសមាទានឧបោសថក្នុងកន្លះថ្ងៃ បានធ្វើកាលកិរិយាក្នុងថ្ងៃនោះ ទើបបានទទួលសម្បត្តិនេះ ។

លំដាប់នោះ តាបសទាំងនោះកើតបីតិបាមោជ្ជថា បានឮថា ព្រះពុទ្ធកើតឡើងហើយ ប្រាថ្នានឹងទៅកាន់ក្រុងសាវត្ថី ហើយក៏នាំគ្នាទៅកាន់ក្រុងកោសម្ពីដោយគិតថា សេដ្ឋីអ្នកទំនុកបម្រុងមានឧបការៈច្រើនដល់ពួកយើង ពួកយើងនឹងប្រាប់សេចក្តីនេះ ដល់សេដ្ឋីសូម្បីទាំងនោះ អ្នកដែលសេដ្ឋីទាំង

ឡាយធ្វើសក្ការៈច្រើនណាស់ ទើបពោលថា ពួកយើងនឹងទៅក្នុងវេលានោះ ។ អ្នកដែលសេដ្ឋីទាំងឡាយពោលថា លោកប្រញាប់អ្វីម្ល៉េះក្នុង កាលមុនពួកលោកនឹងនៅរហូតដល់អស់បួនខែទើបទៅ ក៏បានប្រាប់ប្រវត្តិនោះ ។ កាលសេដ្ឋីទាំងឡាយពោលថា បពិត្រលោកម្ចាស់ បើយ៉ាងនោះពួកយើងនឹងទៅព្រមគ្នា ទើបពោលថា ពួកយើងនឹងទៅ សូមឲ្យពួកលោកតាមក្រោយមក ហើយទៅកាន់ក្រុងសាវត្ថី បួសក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ ក៏បានសម្រេចព្រះអរហត្ត ។ ចំណែកសេដ្ឋីទាំងនោះ មានរទេះម្នាក់ៗ ៥០០ ជាបរិវារ ទៅកាន់ក្រុងសាវត្ថី បានធ្វើកិច្ចមានទានជាដើម ទូលសូមព្រះ-មានព្រះភាគ ដើម្បីប្រយោជន៍ស្តេចយាងមកកាន់ក្រុងកោសម្ពី ហើយត្រឡប់មកសាងវត្តបីកន្លែង ។ ក្នុងសេដ្ឋីទាំងនោះ កុក្កុដសេដ្ឋីសាងវត្ត ឈ្មោះ **កុក្កុដារាម** , បាវារិកសេដ្ឋីសាងវត្ត ឈ្មោះ **បាវារិកម្ពវ័ន** , ឃោសិតសេដ្ឋីសាងវត្ត ឈ្មោះ **ឃោសិតារាម** ។ លោកសំដៅដល់ឃោសិតារាមនោះ ទើបពោលថា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ដូច្នេះ ។

បទថា មណ្ឌិយ នេះ ជាឈ្មោះរបស់បព្វជិតនោះ ។ បទថា ជាលិយោ នេះ ជាឈ្មោះរបស់បព្វជិតមួយរូបទៀតដូចគ្នា ។ ក៏ព្រោះព្រះ

ឧបជ្ឈាយ៍របស់ជាលិយៈនោះ ត្រាច់បិណ្ឌបាតដោយបាត្រ ធ្វើអំពីឈើ ព្រោះដូច្នោះ ទើបហៅថា **ទារុបត្តិកន្តេវាសី** ។ បទថា ឯតទវោចុំ សេចក្តីថា បព្វជិតទាំងពីរប្រាថ្នា នឹងក្រាបទូលប្រាប់វាទៈដោយប្រាថ្នានឹងឆ្លើយឆ្លង ទើបក្រាបទូលសេចក្តីនោះ ។ បានឮថា បព្វជិតពីររូបនោះ មានការគិតយ៉ាងនេះថា បើព្រះសមណគោតមត្រាស់ថា ជីវៈនោះ សរីរៈនោះ លំដាប់នោះពួកយើងក៏នឹងលើកវាទៈនោះ របស់ព្រះសមណគោតមនោះថា បពិត្រព្រះគោតមដ៏ចម្រើន តាមលទ្ធិរបស់លោក សត្វក្នុងលោកនេះនឹងដាច់សូន្យ ដោយហេតុនោះ វាទៈរបស់ព្រះអង្គ រមែងជាឧច្ឆេទវាទៈ តែបើត្រាស់ថា ជីវៈដទៃ សរីរៈដទៃ លំដាប់នោះពួកយើងនឹងលើកវាទៈ របស់ព្រះសមណ-គោតមនោះថា ក្នុងវាទៈរបស់លោក រូបរមែងដាច់សូន្យ សត្វរមែងមិនដាច់សូន្យ ព្រោះហេតុនោះ វាទៈរបស់ព្រះអង្គ សត្វក៏នឹងទៀង ដូច្នេះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា បព្វជិតទាំងនេះ រមែងសួរបញ្ហាដើម្បីប្រយោជន៍ដល់ការលើកវាទៈ តែបព្វជិតទាំងនេះ មិនពឹងទីបំផុតពីរយ៉ាងក្នុងសាសនារបស់តថាគត ទើបមិនដឹងថា មជ្ឈិមាបដិបទាមាន ណ្ហើយចុះ តថាគតនឹងមិនដោះស្រាយបញ្ហារបស់បព្វជិតទាំងនោះ នឹង

សម្តែងធម៌ដើម្បីការជាក់ច្បាស់នៃបដិបទានោះ ទើបត្រាស់ថា តេនហាវុសោ ដូច្នេះជាដើម ។

[៥៩-៦១] ក្នុងបទទាំងនោះ បទថា កល្លំ នុ ខោ តស្សេតំ វចនាយ សេចក្តីថា បព្វជិតអ្នកបួសដោយសទ្ធា បំពេញសីល ៣ យ៉ាង សម្រេចបឋមឈាននោះ សមគួរពោលពាក្យនោះឬហ្ន៎ អធិប្បាយថា ពាក្យនោះគួរដើម្បីពោលដោយពាក្យនិយាយ ។ បរិព្វាជកទាំងឡាយបានស្តាប់ព្រះពុទ្ធ-វចននោះហើយ សម្គាល់ថា ធម្មតាបុថុជ្ជន រមែងមិនអស់សេចក្តីសង្ស័យ ព្រោះដូច្នោះ ទើបពោលយ៉ាងនោះក្នុងពេលខ្លះ ទើបពោលថា កល្លំ តស្សេតំ វចនាយ ដូច្នេះ ។ បទថា អថ ច បនាហំ ន វទាមិ សេចក្តីថា តថាគត តាំងសញ្ញាថា សេចក្តីនោះតថាគតដឹងយ៉ាងនេះ ទើបមិនពោលយ៉ាងនោះ កាលភិក្ខុធ្វើកសិណបរិកម្មចម្រើនហើយ មហគ្គតចិត្តនោះ ក៏កើតឡើងដោយកម្លាំងបញ្ញា ។ បទថា ន កល្លំ តស្សេតំ សេចក្តីថា បរិព្វាជកទាំងនោះសម្គាល់សេចក្តីនេះ ពោលថា ព្រះខីណាស្រពប្រាសចាកសេចក្តីល្ងង់ ប្រាសចាកសេចក្តីសង្ស័យ ព្រោះហេតុណា ព្រោះហេតុនោះ ព្រះខីណាស្រពនោះ ទើបមិនគួរពោលសេចក្តីនោះ ។ បទដ៏សេសក្នុងជាលិយសូត្រនោះ មាន

*សេចក្តីផាយទាំងអស់ ។*

" ចប់ អដ្ឋកថា ផាលិយសូត្រទី ៧ "

# មហាសីហនាទសូត្រទី ៨

## ពោលអំពីអចេលកស្សប

[៦២] *មហាសីហនាទសូត្រថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ។ល។ ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងក្រុងឧរុញ្ញា ជាដើម ។ ក្នុងមហាសីហនាទសូត្រនោះ មានការពណ៌នាតាមលំដាប់បទដូចតទៅនេះ ៖*

*បទថា* ឧរុញ្ញាយំ *សេចក្តីថា ពាក្យថា* **ឧរុញ្ញា** *នេះ ជាឈ្មោះរបស់ដែនខ្លះ របស់ក្រុងខ្លះ ។ ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់នៅអាស្រ័យនៅក្រុងឧរុញ្ញា ។*

*បទថា* **ក្នុងសួនម្រឹគឈ្មោះ កណ្ណកថលៈ** *គឺ ភូមិភាគដែលគួររីករាយមួយកន្លែង ឈ្មោះ កណ្ណកថលៈ មាននៅក្នុងទីមិនឆ្ងាយនៃក្រុងនោះ ។ ភូមិភាគនោះ ហៅថា សួនសត្វប្រើស ព្រោះព្រះរាជទានអភ័យដល់សត្វប្រើស ក្នុងសួនសត្វប្រើស ឈ្មោះ កណ្ណកថលៈនោះ ។*

*បទថា* **អាក្រាត** *គឺ អ្នកបួសអាក្រាត ។ បទថា* **កស្សប** *ជាឈ្មោះរបស់អ្នកបួសនោះ ។ បទថា* **អ្នកមានតបៈ** *គឺ អ្នកអាស្រ័យតបៈ ។*

បទថា **អ្នកមានការចិញ្ចឹមជីវិតសៅហ្មង** គឺ ការចិញ្ចឹមជីវិតរបស់អ្នកបួសនោះ សៅហ្មងដោយអំណាចនៃការអាក្រាត និងមានការប្រព្រឹត្តវិនាសជាដើម ហេតុនោះទើបឈ្មោះថា មានការចិញ្ចឹមជីវិតសៅហ្មង ។ អ្នកមានការចិញ្ចឹមជីវិតសៅហ្មង ។ បទថា **រមែងតិះដៀល** គឺ រមែងតិះដៀល ។ បទថា **ប្រទូសរ៉ាយ** គឺ រមែងចំអកឡកឡឺយ រមែងបន្ទាប់ ។ បទថា **រមែងព្យាករណ៍ធម៌ដ៏សមគួរដល់ធម៌** គឺ រមែងពោលហេតុសមគួរដល់ហេតុ ដែលព្រះគោតមដ៏ចម្រើនត្រាស់ហើយ ។ បទថា **វាទ និងអនុវាទ ប្រព្រឹត្តទៅប្រកបដោយធម៌** គឺ វាទៈ និងអនុវាទៈរបស់លោក មានហេតុដោយហេតុដែលអ្នកដទៃ ពោលហើយ គឺ ហេតុដែលបណ្ឌិតគប្បីតិះដៀលថា នរណាៗ សូម្បីមិនប្រមាទ ក៏មិនមកឬ ។ ពាក្យនេះ លោកពោលទុកថា ហេតុដែលគួរតិះដៀល ព្រោះវាទៈរបស់លោកមិនមានឬ ។ ពាក្យថា **មិនការពោលមើលងាយ** គឺ មិនត្រូវការនិយាយពាក្យមិនពិត ។

ក្នុងពាក្យថា **អ្នកមានតបៈ** បុគ្គលខ្លះមានតបៈ ហើយមានការចិញ្ចឹមជីវិតសៅហ្មងជាដើម គប្បីជ្រាបដូច្នេះ ។ បុគ្គលក្នុងលោក អ្នកខ្លះមានតបៈ ព្រោះអាស្រ័យតបៈមានការបួសជាអចេលក៍ជាដើម គិតថា យើងនឹងចិញ្ចឹម

ជីវិតដោយរបស់សៅហ្មង ទើបធ្វើខ្លួនឲ្យលំបាកដោយប្រការផ្សេងៗ មានស៊ីស្មៅ និងអាចម៍គោជាដើម និងមិនបានញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ ព្រោះមានបុណ្យតិច ។ គេបំពេញទុច្ចរិត ៣ ហើយកើតក្នុងនរក ។

បុគ្គលមួយទៀត អាស្រ័យតបៈដូច្នោះ ជាអ្នកមានបុណ្យ រមែងបានលាភសក្ការៈ ។ គេយល់ថា ឥឡូវនេះ បុគ្គលដូចជាយើងមិនមាន ហើយលើកតម្កើងខ្លួនទុកនៅក្នុងឋានៈខ្ពស់ គិតថា នឹងញ៉ាំងលាភឲ្យកើតក្រៃលែងឡើងៗ និងបំពេញទុច្ចរិត ៣ ដោយអំណាចនៃអនេសនា ហើយនឹងកើតក្នុងនរក ន័យដើមពោលសំដៅដល់បព្វជិតទាំងពីរនេះ ។

បុគ្គលមួយទៀត ចិញ្ចឹមជីវិតសៅហ្មង សូម្បីអាស្រ័យតបៈ ជាអ្នកមានបុណ្យតិច រមែងមិនអាចញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខបាន ។ គេគិតថា ការរស់នៅសប្បាយ រមែងមិនកើតឡើងដល់យើង ព្រោះមិនបានធ្វើបុណ្យទុកក្នុងកាលមុន ណ្ហើយចុះ ឥឡូវនេះ យើងនឹងធ្វើបុណ្យ ដូច្នេះ ហើយបំពេញសុចរិត ៣ នឹងកើតក្នុងសួគ៌ ។

បុគ្គលមួយទៀត ចិញ្ចឹមជីវិតសៅហ្មង ជាអ្នកមានបុណ្យ រមែង

ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ គេគិតថា ការរស់នៅសប្បាយ រមែងកើតដល់យើង ព្រោះជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន លះអនេសនាហើយ បំពេញសុចរិត ៣ នឹងកើតក្នុងសួគ៌ ។ ន័យទី ២ ពោលសំដៅដល់បព្វជិតទាំងពីរនេះ ។

ចំណែកអ្នកបំពេញតបៈម្នាក់ មានទុក្ខតិច ប្រកបដោយការប្រព្រឹត្តខាងក្រៅ ជាតាបស ឬជាបរិព្វាជកដែលបិទបាំង រមែងមិនបានបច្ច័យដែលពេញចិត្ត ព្រោះមានបុណ្យតិច ។ គេបំពេញទុច្ចរិត ៣ ដោយអំណាចនៃអនេសនា តាំងខ្លួនទុកក្នុងសេចក្តីសុខ នឹងកើតក្នុងនរក ។ មួយរូបទៀតមានបុណ្យ កើតមានះឡើងថា ឥឡូវនេះ បុគ្គលដូចយើងមិនមាន ក៏ញ៉ាំងលាភសក្ការៈឲ្យកើតឡើងដោយអំណាចអនេសនា ។ គិតរឿយៗ ដោយអំណាចមិច្ឆាទិដ្ឋិថា សម្ផស្សនៃបរិព្វាជិកាក្រមុំ ដែលមានរោមទន់ល្មើនេះជាសេចក្តីសុខ ឬដល់ការជ្រមុជជ្រមុលក្នុងកាម បំពេញទុច្ចរិត ៣ នឹងធ្លាក់នរក ។ ន័យទី ៣ ពោលដល់បព្វជិតទាំងពីរ ។

ចំណែកមួយរូបទៀត មានទុក្ខតិច មានបុណ្យតិច ។ គេគិតថា យើងមិនមានជីវិតដោយសេចក្តីសុខ ព្រោះមិនបានធ្វើបុណ្យទុកក្នុងកាលមុន

ដូច្នេះហើយបំពេញសុចរិត ៣ ទើបកើតក្នុងសួគ៌ ។ មួយរូបទៀត មានបុណ្យ ។ គេគិតថា យើងបានសេចក្តីសុខ ព្រោះធ្វើបុណ្យទុកក្នុងកាលមុន សូម្បីឥឡូវនេះ ក៏នឹងធ្វើបុណ្យដូចគ្នា ទើបបំពេញសុចរិត ៣ នឹងកើតក្នុងសួគ៌ ។ ន័យទី ៤ ពោលដល់បញ្ជិតពីររូបនេះ ។ ការធ្វើនេះមកដោយអំណាចនៃតិរ្ថិយ មិនមានសូម្បីក្នុងសាសនា ។

អ្នកបួសខ្លះ ជាអ្នកមានការរស់នៅសៅហ្មង ដោយអំណាចនៃការសមាទានធុតង្គ ឬត្រាច់ទៅកាន់ស្រុក ក៏មិនបានអាហារពេញពោះ ព្រោះមានបុណ្យតិច ។ គេគិតថា នឹងញុំាងបច្ច័យឲ្យកើតឡើង ទើបធ្វើអនេសនាដោយអំណាចវេជ្ជកម្មជាដើម អួតអាងព្រះអរហត្ត ឬសេពសោយរឿងកុហក ៣ ប្រការ រមែងកើតក្នុងនរក ។ មួយរូបទៀត ជាអ្នកមានបុណ្យដូច្នោះដែរ ។ គេញុំាងមានះឲ្យកើតឡើង ព្រោះបុណ្យសម្បត្តិនោះ ប្រាថ្នានឹងធ្វើលាភដែលកើតឡើងហើយឲ្យរឹងមាំ ទើបបំពេញទុច្ចរិត ៣ ដោយអំណាចអនេសនា រមែងកើតក្នុងនរក ។ មួយរូបទៀត សមាទានធុតង្គ ជាអ្នកមានបុណ្យតិច រមែងមិនបានញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ ។ គេគិតថា យើងមិនបានអ្វី ៗ ព្រោះមិនបានធ្វើបុណ្យទុកក្នុងកាលមុន ឥឡូវនេះ

*បើនឹងធ្វើអនេសនាហើយ សូម្បីតទៅ ក៏នឹងបានសេចក្ដីសុខដោយលំបាក ដូច្នេះ ក៏បំពេញសុចរិត ៣ កាលមិនអាចសម្រេចព្រះអរហត្ត ក៏នឹងកើតក្នុងសួគ៌ ។ មួយរូបទៀត ជាអ្នកមានបុណ្យ ។ គេគិតថា ឥឡូវនេះយើងមានសេចក្ដីសុខ ព្រោះធ្វើបុណ្យទុកក្នុងកាលមុន សូម្បីឥឡូវនេះក៏នឹងធ្វើបុណ្យ ដូច្នេះហើយ លះអនេសនា បំពេញសុចរិត ៣ កាលមិនអាចសម្រេចព្រះអរហត្ត ក៏នឹង កើតក្នុងសួគ៌ ។*

*ពាក្យថា* ***ដែលមកផង*** *គឺ អ្នកទាំងនេះមកពីទីឯណោះ ដូច្នោះ ទើបឈ្មោះថា ដែលមកយ៉ាងនេះ ។ បទថា គតិញ្ច សេចក្ដីថា ស្ថានទីនឹងគប្បីទៅក្នុងឥឡូវនេះ ។ ពាក្យថា* ***ដែលមិនចុតិផង*** *គឺ ឃ្លាតចាកទីនោះផង ។ ពាក្យថា* ***ដែលកើតផង*** *គឺ ការកើតទៀត របស់អ្នកចុតិពីទីនោះ ពាក្យថា* ***តថាគតនឹងតិះដៀលតបៈទាំងពួងដូចម្ដេច*** *គឺ តថាគតនឹងតិះដៀលដោយហេតុណា ។ ដោយសេចក្ដីថា តថាគតរមែងតិះដៀលវត្ថុដែលគួរតិះដៀល សរសើរវត្ថុដែលគួរសរសើរ ។ ពិតហើយ គេក៏ដូចជាអ្នកជ្រលក់សំពត់ធ្វើការដណ្ដប់សំពត់ មិនសម្ដែងថា យើងនឹងធ្វើសំពត់ដែលជ្រលក់ហើយ និងមិនទាន់បានជ្រលក់ ទុកដណ្ដប់ជាមួយគ្នា ។ ឥឡូវនេះ កាលព្រះអង្គ*

នឹងប្រកាសសេចក្តីនោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សបៈ សមណ-ព្រាហ្មណ៍ពួកមួយ ។

[៦៣] ពាក្យថា **គេទាំងនោះ (ពោល) អ្វីខ្លះ** គឺ សីល ៥ ។ ក៏មិនមានអ្នកណាក្នុងលោក ពោលសីល ៥ នោះថា មិនល្អ ។ ពាក្យថា **គេនោះ (ពោល) ដល់វត្ថុខ្លះទៀត** គឺ វេរ ៥ ។ មិនមាននរណាៗ ពោលដល់វេរនោះថាល្អ ។ ពាក្យថា **គេ (ពោល) អ្វីខ្លះទៀត** គឺ ការមិនសង្រួមក្នុងទ្វារទាំង ៥ ។ បានឮថា គេពោលថា ដែលឈ្មោះថា ចក្ខុមិនត្រូវបិទ ក៏នឹងគប្បីឃើញរូបដែលគួរពេញចិត្តដោយចក្ខុ ។ ន័យនេះ រមែងមានក្នុងទ្វារដទៃ មានសោតៈជាដើម ។ ពាក្យថា **គេ (ពោល) នូវអ្វីខ្លះ** គឺ ការសង្រួមក្នុងទ្វារទាំង ៥ ។ កាលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងសេចក្តីស្មើ និងមិនស្មើនៃវាទៈរបស់ព្រះអង្គ នឹងវាទៈរបស់អ្នកដទៃយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់នឹងសម្តែងសេចក្តីស្មើ និងមិនស្មើនៃវាទៈរបស់អ្នកដទៃ និងវាទៈរបស់ព្រះអង្គ ទើបត្រាស់ពាក្យ ជាដើមថា **តថាគត**........ **ណា** ។

## ការសាកសួរ

សូម្បីក្នុងសេចក្តីនោះ ក៏គប្បីជ្រាបសេចក្តីដោយអំណាចសីល មានសីល ៥ ជាដើម ។ ពាក្យថា សមនុយុញ្ជន្តិ គឺ ចូរសាកសួរ ។ ក៏ឯក្នុងទីនេះ កាលសួរដល់ការឃើញ ឈ្មោះថា **រមែងសាកសួរ** ។ កាលសួរដល់ហេតុ ឈ្មោះថា **ដេញដោល** ។ កាលសួររកទាំងពីរយ៉ាង ឈ្មោះថា **សួរស្ទាក់** ។ ពាក្យថា **សាស្តា និងសាស្តា** គឺ ប្រៀបធៀបសាស្តាជាមួយនឹងសាស្តាថា សាស្តារបស់លោកលះបង់ធម៌ទាំងនោះ ដោយប្រការទាំងពួងយ៉ាងណា ឬថា ព្រះសមណគោតម ។ សូម្បីក្នុងបទទី ២ ក៏ដូចគ្នា ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែងប្រកបសេចក្តីនោះ ទើបត្រាស់ពាក្យជាដើមថា បុគ្គលណា........... នៃអ្នកដ៏ចម្រើនទាំងនេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ដែលជាអកុសល ដែលរាប់ថា ជាអកុសល** អធិប្បាយថា ដែលជាអកុសលផង ដែលរាប់ថា ដែលដឹងថា ជាអកុសលផង ឬថា ដែលតាំងទុកជាចំណែក ។ ន័យក្នុងបទទាំងពួងក៏យ៉ាងនេះ ។ មួយទៀត ក្នុងបទទាំងនេះ បទថា **មានទោស** គឺ ប្រព្រឹត្តទៅដោយទោស ។

ពាក្យថា **មិនប្រសើរ** គឺ មិនមែនជាធម៌ដ៏ប្រសើរ ដោយអត្ថថា មិនមានទោស ។

[៦៤-៦៦] ពាក្យថា **កាលវិញ្ញូជនសាកសួរយ៉ាងណា** គឺ កាលបណ្ឌិតសួរតថាគត និងអ្នកដទៃ ដោយប្រការណា គប្បីពោលយ៉ាងនេះ ឋានៈនោះមានហើយ សេចក្ដីថា មានហេតុនោះ ។ ពាក្យថា **ឬពួកគណាចារ្យដទៃ ..... យ៉ាងណា** ។ គឺ ក៏គណាចារ្យដទៃលះហេតុដែលមានប្រមាណតិចនោះ តាមមានតាមបាន ប្រព្រឹត្តទៅ ។

ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យនេះថា **គប្បីសរសើរតថាគតដោយច្រើន ក្នុងសេចក្ដីនោះដូច្នេះ** ទាំងក្នុងការសាកសួរសាស្ដានិងសាស្ដា ទាំងក្នុងការសាកសួរសង្ឃនិងសង្ឃ ព្រោះហេតុណា ។ ព្រោះសូម្បីការសរសើរព្រះសង្ឃ ក៏ជាការសរសើរព្រះសាស្ដាដូចគ្នា ។ ពិតហើយ សូម្បីកាលបណ្ឌិតជ្រះថ្លា ក៏រមែងជ្រះថ្លាក្នុងសង្ឃព្រមដោយព្រះពុទ្ធ និងរមែងជ្រះថ្លាក្នុងព្រះពុទ្ធព្រមដោយសង្ឃ ។ ពិតយ៉ាងនោះ បណ្ឌិតឃើញសេចក្ដីសម្រេចនៃព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ ឬស្ដាប់ព្រះធម៌ទេសនាហើយ ពោលថា ម្នាលអ្នកដ៏ចម្រើន ជាលាភរបស់ព្រះសាវក អ្នកត្រាច់ទៅក្នុងសម្នាក់របស់

សាស្តាបែបនេះហ្ន៎ ឈ្មោះថា រមែងជ្រះថ្លាក្នុងព្រះសង្ឃ ព្រមទាំងព្រះពុទ្ធ-សម្បត្តិយ៉ាងនេះ ក៏បណ្ឌិតទាំងឡាយ ឃើញអាចារគោចរៈ និងឥរិយាបថមានការឈានទៅ ថយត្រឡប់ជាដើម របស់ភិក្ខុទាំងឡាយ ជាអ្នកពោលថា ម្នាលលោកដ៏ចម្រើន នេះជាឥរិយាបថរបស់ព្រះសាវកអ្នកត្រាច់ទៅក្នុងសម្នាក់ក៏ឯគុណ គឺ សេចក្តីស្ងប់នេះ របស់ព្រះសាស្តានឹងមានត្រឹមណា ឈ្មោះថា រមែងជ្រះថ្លាក្នុងព្រះពុទ្ធព្រមទាំងព្រះសង្ឃ ដូច្នោះ ការសរសើរព្រះសាស្តាក៏ជាការសរសើរព្រះសង្ឃ សូម្បីការសរសើរព្រះសង្ឃ ក៏ស្មើនឹងការសរសើរព្រះសាស្តាដូចគ្នា ព្រះដ៏មានព្រះភាគត្រាស់ថា **គប្បីសរសើរតថាគតដោយច្រើនក្នុងធម៌ទាំងនោះ** ក្នុងន័យសូម្បីទាំង ២ ព្រោះសូម្បីសរសើរព្រះសង្ឃក៏ជាការសរសើរព្រះសាស្តាដូចគ្នា ។ ព្រះសមណគោតមលះបង់ធម៌ទាំងនេះមិនឲ្យសេសសល់ ប្រព្រឹត្តទៅ ។ នេះជាសេចក្តីបំណងក្នុងសេចក្តីនេះ សូម្បីក្នុងពាក្យជាដើមថា ក៏ឬថា គណាចារ្យដ៏ចម្រើនដទៃណា ។

ក៏ឯវិរតិមាន ៣ ដោយអំណាចនៃ សម្បត្តវិរតិ សមាទានវិរតិ និងសេតុឃាតវិរតិ ក្នុងវិរតិទាំងនោះ ត្រឹមតែសម្បត្តវិរតិ និងសមាទានវិរតិរមែងមានដល់អ្នកដទៃ ចំណែកសេតុឃាតិវិរតិមិនមានឡើយ ដោយប្រការ

ទាំងពួង ។ ក៏ក្នុងតទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិប-ស្សទ្ធិប្បហាន និងនិស្សរណប្បហាន , ៥ យ៉ាង ត្រឹមតែតទង្គប្បហាន និង វិក្ខម្ភនប្បហាន រមែងមានដល់អ្នកដទៃ ដោយអំណាចនៃសមាបត្តិ ៨ និង ដោយអំណាចនៃវិបស្សនា , បហាន ៣ ក្រៅពីនេះមិនមានឡើយ ដោយ ប្រការទាំងពួង ។ ពិតយ៉ាងនោះ សំវរៈ ៥ គឺ សីលសំវរៈ ខន្តិសំវរៈ ញាណសំវរៈ សតិសំវរៈ វីរិយសំវរៈ ក្នុងសំវរៈទាំងនោះ ត្រឹមតែសីល ៥ និងត្រឹមតែអធិវាសនខន្តិ រមែងមានដល់អ្នកដទៃ , ដ៏សេសរមែងមិនមាន ឡើយដោយប្រការទាំងពួង ។ ក៏ឧទ្ទេសនៃឧបោសថនេះមាន ៥ យ៉ាង ក្នុង ឧទ្ទេសនៃឧបោសថទាំងនោះ ត្រឹមតែសីល ៥ ប៉ុណ្ណោះ រមែងមានដល់អ្នក ដទៃ , បាតិមោក្ខសំវរសីល រមែងមិនមានឡើយដោយប្រការទាំងពួង ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាប ទើបបន្លឺសីហនាទថា ក្នុងវិរតិ ៣ ក្នុងបហានៈ ៥ ក្នុងសំវរៈ ៥ ក្នុងឧទ្ទេស ៥ ក្នុងការលះអកុសល និងក្នុងការសមាទាន កុសល តថាគតផង សង្ឃសាវករបស់តថាគតផង រមែងប្រាកដក្នុងលោក ។ ពិតណាស់ ឈ្មោះថា សាស្តាដូចតថាគត និងឈ្មោះថា សង្ឃដូចជាសង្ឃ សាវករបស់តថាគត រមែងមិនមាន ។

# មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ

**[៦៧]** លុះព្រះដ៏មានព្រះភាគ ទ្រង់បន្លឺសីហនាទយ៉ាងនេះហើយ ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សបៈ មគ្គ រមែងមានដើម្បីដឹងសេចក្តីមិនវិបរិតនៃសីហនាទនោះ ។

បណ្តាពាក្យទាំងនោះពាក្យថា **មគ្គ** គឺ លោកុត្តរមគ្គ ។ ពាក្យថា **បដិបទា** គឺ បដិបទាខាងដើម ។ ពាក្យថា **និយាយត្រូវតាមកាល** ជាដើម ពណ៌នាទុកហើយក្នុងព្រហ្មជាលសូត្រ ។ ឥឡូវនេះ កាលទឹងសម្តែងមគ្គ និងបដិបទា ទាំងពីរយ៉ាងដូចគ្នា ទើបត្រាស់ពាក្យជាដើមថា ( មគ្គប្រកបដោយអង្គ ៨ ) ដ៏ប្រសើរនេះ ។

ក៏ឯអចេលក៍ បានស្តាប់ពាក្យនេះហើយ ទើបគិតថា ព្រះសមណគោតម សម្គាល់ថា មគ្គ និងបដិបទា មានដល់យើងប៉ុណ្ណោះ មិនមានដល់អ្នកដទៃ ទើបសម្គាល់ថា ណ្ហើយចុះ យើងនឹងពោលមគ្គរបស់យើងទាំងឡាយចំពោះព្រះសមណគោតមនោះ ។ លំដាប់នោះ ទើបពោលដល់បដិបទារបស់អចេលក៍ ។ កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ

អចេលកស្សបៈ ទើបក្រាបទូលចំពោះព្រះដ៏មានព្រះភាគថា សូម្បីការបំពេញតបៈទាំងនេះឯង ។ល។ ប្រកបដោយការខ្វល់ខ្វាយ ក្នុងការចុះងូតទឹក ។

## ការធ្វើមនូវតបៈរបស់អចេលកស្សប

[៦៨] ក្នុងពាក្យទាំងនោះ ពាក្យថា **ការបំពេញនូវតបៈ** សេចក្ដីថា ប្រារព្ធតបៈ ធ្វើតបៈ ។ ពាក្យថា **រាប់ថាជាសមណៈ** គឺ រាប់ថា ការងាររបស់សមណៈ ។ ពាក្យថា **រាប់ថាជាព្រាហ្មណ៍** គឺ រាប់ថា ការងាររបស់ព្រាហ្មណ៍ ។ គឺ អចេលក សេចក្ដីថា មិនមានសំពត់ស្លៀកដណ្ដប់ អធិប្បាយថា ជាអ្នកអាក្រាត ។ ពាក្យថា គ្មានមារយាទ គឺ លះបង់មារយាទ ។ ក្នុងមារយាទទាំងឡាយ មានការបន្ទោបង់ឧច្ចារៈជាដើម គេវៀរចាកមារយាទរបស់កុលបុត្រអ្នកស្រុក ឈរបន្ទោបង់ឧច្ចារបស្សាវៈ ទំពារនិងស៊ី ។

ពាក្យថា **លិទ្ធដៃ** គឺ កាលដុំបាយក្នុងដៃអស់ហើយ ក៏លិទ្ធដៃដោយអណ្ដាត ។ ឬបន្ទោបង់ឧច្ចារៈ ក៏យកដៃជូតគូថជំនួសឈើ ។ គេពោលថា លោកម្ចាស់និមន្តមកទទួលភិក្ខា ក៏មិនមក ដូច្នោះ ទើបឈ្មោះថា លោកម្ចាស់

មិនមក ។ សូម្បីគេពោលថា លោកម្ចាស់ ចូរឈប់ ក៏មិនឈប់ ដូច្នោះទើបឈ្មោះថា លោកម្ចាស់មិនឈប់ ។ បានឮថា គេគិតថា ពាក្យរបស់អ្នកនេះក៏ជាការធ្វើហើយ ទើបមិនធ្វើទាំង ២ យ៉ាង ។

ពាក្យថា **មិនទទួលភិក្ខាដែលគេចែកទុកមុន** គឺ មិនទទួលភិក្ខាដែលគេឧទ្ទិសឲ្យ (មិន) ទទួលភិក្ខាដែលគេលើកមកថ្វាយ ដោយពោលយ៉ាងនេះថា (ចូរទទួលភិក្ខា) ដែលពួកយើងធ្វើចំពោះលោកទាំងឡាយនេះ ។ ពាក្យថា **មិនទទួលនិមន្ត** គឺ មិនត្រេកអរ មិនកាន់យកភិក្ខាដែលគេនិមន្តថាសូមលោកទាំងឡាយ គប្បីចូលទៅកាន់ត្រកូល ឬថ្នល់ ឬពួកស្រុកឯណោះ ។

ពាក្យថា **មិនទទួលអំពីមាត់ឆ្នាំង** គឺ មិនទទួលយកភិក្ខាដែលគេដួសពីឆ្នាំងថ្វាយ ។ ពាក្យថា **មិនទទួលភិក្ខាអំពីមាត់កញ្ជើ** គឺ ពាក្យថាកឡោបិ បានដល់ កញ្ជើ ឬបំពង់ មិនទទួល (ភិក្ខា) អំពីកញ្ជើ ឬបំពង់នោះ ។ ព្រោះហេតុអ្វី ។ ឆ្នាំង និងកញ្ជើអាស្រ័យយើង ទើបត្រូវប្រហារដោយវែក ។

ពាក្យថា **មិន (ទទួល) ដែលគេឈរត្រង់ទ្វារឲ្យ** គឺ មិនទទួលភិក្ខាដែលគេធ្វើត្រង់ខ្លាងទ្វារឲ្យនៅក្នុងចន្លោះប្រគល់ឲ្យ ។ ព្រោះហេតុណា ។

អ្នកនេះអាស្រ័យយើង ទើបបានការធ្វើក្នុងចន្លោះ សូម្បីក្នុងកំណាត់ឈើនិងអង្រែ ក៏មានន័យដូចគ្នា ។

ពាក្យថា **មិន (ទទួលភិក្ខា) របស់មនុស្សពីរនាក់ (ដែលកំពុងបរិភោគ)** គឺ ក្នុងកាលមនុស្សពីរនាក់កំពុងបរិភោគ កាលម្នាក់ក្រោកឡើងឲ្យ ក៏មិនទទួល ។ ព្រោះហេតុណា ។ ព្រោះអន្តរាយដែលលេបពំនូតបាយ រមែងមានដល់ម្នាក់ទៀត ។ ក៏ក្នុងពាក្យថា **មិន (ទទួលភិក្ខា) របស់ស្ត្រីមានគភ៌** ជាដើម សេចក្ដីថា គេគិតថា ក្មេងក្នុងផ្ទៃរបស់ស្ត្រីមានគភ៌ រមែងលំបាក កាលស្ត្រីកំពុងឲ្យកូនផឹកទឹកដោះ អន្តរាយក្នុងការផឹកទឹកដោះ រមែងមានដល់ក្មេង អន្តរាយនៃសេចក្ដីត្រេកអរ រមែងមានដល់ស្ត្រីដែលនៅក្នុងចន្លោះបុរស ។ ពាក្យថា **កន្លែងដែលគេត្រៀមទុក** គឺ ក្នុងកត្តដែលគេត្រៀមទុក ។ បានឮថា ក្នុងគ្រាដែលខ្សត់បាយ មានតម្លៃខ្ពស់ សាវក របស់អចេលប្រមូលអង្ករជាដើម ពីទីនោះៗ ដាំបាយដើម្បីប្រយោជន៍ដល់អចេលទាំងឡាយ ។ អចេលអ្នកតឹងរឹងបំផុត មិនទទួលសូម្បី ពីទីនោះ ។

ពាក្យថា **មិន (ទទួលភិក្ខា) ក្នុងទីដែលមានឆ្កែ** គឺ ក្នុងទីណាមានឆ្កែដែលគេចិញ្ចឹមទុក វាគិតថា យើងនឹងបានដុំបាយ រមែងមិនទទួល (ភិក្ខា)

ដែលគេមិនឲ្យវាក្នុងទីនោះ នាំមក ។ ព្រោះហេតុណា ។ ព្រោះអន្តរាយក្នុងដុំបាយ រមែងមានដល់ខ្មែនោះ ។ ពាក្យថា **រុយរោម** គឺ ចោមរោមជាហ្វូងៗ បើពួកមនុស្សឃើញ អចេលហើយគិតថា យើងនឹងឲ្យភិក្ខាដល់អចេលនោះ ចូលទៅកាន់រោងបាយ ក៏កាលពួកគេចូលទៅ រុយលាក់ខ្លួននៅត្រង់មាត់ឆ្នាំង បាយជាដើម ហើរព្រោងព្រាតជាហ្វូងៗ ក៏មិនកាន់យកភិក្ខាដែលនាំមកពីទីនោះ ព្រោះហេតុណា ។ ព្រោះគេគិតថា អន្តរាយនៃការត្រាច់រកស៊ីរបស់រុយ កើត ព្រោះអាស្រ័យយើង ។

ពាក្យថា **ទឹកត្រាំថ្នាំ** គឺ ទឹកត្រាំដែលធ្វើដោយគ្រឿងផ្សំទាំងពួង ។ ក៏ក្នុងទីនេះ ការផឹកទឹកត្រាំ រមែងមានទោស ចំណែកអ្នកនេះ សម្គាល់ថា មានទោស សូម្បីក្នុងទឹកស្រវឹងទាំងពួង ។ ពាក្យថា **រក្សាភិក្ខាក្នុងផ្ទះតែម៉្យាង** គឺ បានភិក្ខាក្នុងផ្ទះតែមួយប៉ុណ្ណោះក៏ត្រឡប់ ។ ពាក្យថា **ទំពាស៊ីមួយដុំ** គឺ ញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយអាហារតែមួយពំនូត ។ សូម្បីក្នុងការទទួល កត្តពីរផ្ទះ ក៏មានន័យដូចគ្នា ។ ពាក្យថា **ក្នុងភាជន៍មួយ** គឺ ក្នុងថាសមួយ ។

ដែលឈ្មោះថា ហត្ថិ បានដល់ ថាសតូចៗ មួយប្រភេទដែលសម្រាប់ ដាក់ពំនូតភិក្ខាទុក ។ ពាក្យថា **ទុករំលងមួយថ្ងៃ** គឺ នៅក្នុងចន្លោះមួយថ្ងៃ ។

ពាក្យថា រំលងកន្លះខែ គឺ នៅក្នុងចន្លោះកន្លះខែ ។ ពាក្យថា **បរិភោគភត្ត ដោយបរិយាយ** គឺ ស៊ីភត្តតាមវារៈ បានដល់ ស៊ីភត្តដែលមកតាមវារៈនៃថ្ងៃ យ៉ាងនេះ គឺ តាមវារៈមួយថ្ងៃ តាមវារៈ ២ ថ្ងៃ តាមវារៈកន្លះខែ ។

ពាក្យថា មានបន្លែស្រស់ជាអាហារ គឺ មានបន្លែអន្ទក់ស្រស់ៗ ជាអាហារ ។ ពាក្យថា **មានស្រងែជាអាហារ** គឺ មានបាយស្រូវស្រងែជាអាហារ ។ ក្នុងស្កួយជាដើម ស្រូវដែលកើតឯងក្នុងព្រៃ ឈ្មោះថា ស្កួយ ។ ពាក្យថា **កាកបាយ** គឺ កម្ទេច ដែលជាងឆ្នាំង ដុសឆ្នាំងចោល ។ ពាក្យថា ហតំ សំដៅដល់ ជ័រខ្លះ សារាយខ្លះ ។ ពាក្យថា កណាំ គឺ កន្ទក់ ។ ពាក្យថា **បាយក្ដាំង** គឺ បាយខ្លោចដែលជាប់នៅក្នុងឆ្នាំងបាយ ។ គេកាន់យកបាយក្ដាំងទាំងនោះពីទីដែលគេចោលមកស៊ី ។ គេហៅថា បាយចុងអង្ករក៏មាន ។ ពាក្យថា **មេជ្ឈា** ជាដើម ច្បាស់លាស់ហើយ ។ ពាក្យថា **បរិភោគផ្លែឈើ ហើយប្រព្រឹត្តទៅ** គឺ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ ។

ពាក្យថា **សំបកធ្មៃ** គឺ សំពត់សំបកធ្មៃ ។ ពាក្យថា **សំពត់ផ្សំគ្នា** គឺ សំពត់លាយគ្នា ។ ពាក្យថា **សំពត់រុំសាកសព** គឺ សំពត់ដែលគេទុកចោល អំពីរាងកាយអ្នកស្លាប់ ឬសំពត់ស្លៀកដែលគេ គ្រងដោយស្លឹកគ្រៃ និងស្មៅ

ជាដើមធ្វើទុក ។ ពាក្យថា **សំពត់បង្សុកូល** គឺ សំពត់ប្រលាក់ ដែលគេទុកចោលលើដី ។ ពាក្យថា **សំបកឈើ** គឺ សំពត់សំបកឈើ ។ ពាក្យថា **ស្បែកខ្លា** គឺ សំពត់ស្បែកខ្លា ។ ពាក្យថា អជិនក្ខិបំ គឺ ស្បែកខ្លានោះឯង ត្រូវពុះចំពាក់កណ្ដាល ។ ពាក្យថា កុសចីរំ **ស្បូវក្រាំងក្រង** គឺ សំពត់ដែលគេក្រងដោយស្បូវ ។ សូម្បីសំបកក្រចៅ និងចំរៀកបន្ទះក្ដារ ក៏ន័យនេះឯង ។ ពាក្យថា **សំពត់កម្ពលដែលធ្វើដោយសក់** គឺ សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស ។ ពាក្យដែលព្រះដ៏មានព្រះភាគសំដៅយក ត្រាស់ទុកថា **សូម្បីយ៉ាងណាក្ដី** ម្នាលភិក្ខុទាំងឡាយ សំពត់ដែលត្បាញហើយណាមួយបណ្ដាសំពត់ទាំងនោះ សំពត់កម្ពលដែលគេត្បាញដោយសក់ រាប់ថា អាក្រក់បំផុត ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់ ត្រជាក់ក្នុងពេលត្រជាក់ ក្ដៅក្នុងពេលក្ដៅ មានតម្លៃថោក មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ ។ ពាក្យថា **សំពត់កម្ពលធ្វើដោយកន្ទុយសត្វ** គឺ សំពត់កម្ពលដែលត្បាញដោយកន្ទុយសេះ ។ ពាក្យថា សំពត់ដែលធ្វើដោយស្លាបសត្វមៀម គឺ សំពត់ស្លៀកដែលចងស្លាបសត្វមៀមធ្វើទុក ។

ពាក្យថា **ប្រកបសេចក្តីព្យាយាមប្រហោង** គឺ ប្រកបការផ្គងឡើងនូវការអង្គុយប្រហោង សូម្បីដើរទៅក៏នៅប្រហោង ដើរលោតផ្លោតៗ ។ ពាក្យថា **ដេកលើបន្លា** គឺ ចាក់បន្លាដែក ឬបន្លាធម្មតាទុកលើផែនដី ក្រាលស្បែកទុកក្នុងទីនោះហើយ ធ្វើជាទីឈរ និងទីចង្រ្កមជាដើម ។ ពាក្យថា **ដេក** គឺ សូម្បីកាលដេក ក៏ដេកក្នុងទីនោះឯង ។ ពាក្យថា ទីដេកត្រង់ផែនក្តារ គឺ ទីដេកធ្វើដោយបន្ទះឈើ ។ ពាក្យថា **ទីដេកទួល** គឺ ទីដេកលើផ្ទៃដីទួលខ្ពស់ៗ ។ ពាក្យថា **ដេកផ្អៀងម្ខាង** គឺ ដេកដោយការផ្អៀងតែមួយចំហៀងប៉ុណ្ណោះ ។ ពាក្យថា **ប្រឡាក់ធូលី** គឺ លាបរាងកាយដោយប្រេងហើយឈរក្នុងទីដែលមានធូលីហុយ លំដាប់នោះ ធូលីនឹងជាប់រាងកាយរបស់គេ ឲ្យធូលីនោះតោងជាប់ ។ ពាក្យថា **អង្គុយលើអាសនៈតាមដែលក្រាលទុក** គឺ មិនញុំាងអាសនៈឲ្យកម្រើក បានអាសនៈយ៉ាងណា ក៏អង្គុយក្នុងអាសនៈយ៉ាងនោះជាប្រក្រតី ។

ពាក្យថា **បរិភោគតែលាមក** គឺ ស៊ីអាចម៍ជាប្រក្រតី ។ **គូថ** គេហៅថា អាចម៍ ។ ពាក្យថា **មិនផឹកទឹកត្រជាក់** គឺ ហាមផឹកទឹកត្រជាក់ ។ ពាក្យថា **ត្រាំទឹក ១ ថ្ងៃ ៣ ដង ក្នុងវេលាត្រជាក់** គឺ វេលាល្ងាចជាលើកទី

*៣ ។ អចេលគិតថា យើងនឹងបណ្តួតបាបមួយថ្ងៃ ៣ ដង គឺ ព្រឹក ថ្ងៃត្រង់ល្ងាច* ***ទើបប្រកបការខ្វល់ខ្វាយ ចុះងូតទឹក*** *។*

## ការព្យាយាមបំពេញតបៈ

[៦៩] លំដាប់នោះ កាលព្រះដ៏មានព្រះភាគទ្រង់សម្តែងសេចក្តីនៃការព្យាយាមបំពេញតបៈនោះ វៀរចាកសីលសម្បទាជាដើម ជាការធ្វើគ្មានប្រយោជន៍ ទើបត្រាស់ឡើងជាដើមថា ម្នាលកស្សបៈ សូម្បីបើអចេលដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ធ្លាយ** គឺ ក្នុងទីធ្លាយ ។ ពាក្យថា **មិនមានពៀរ** គឺ វៀរចាកពៀរវេរាដែលឲ្យកើតទោស ។ ពាក្យថា **មិនបៀតបៀន** គឺ វៀរចាកការបៀតបៀនដែលកើតពីទោមនស្ស ។

[៧០] ពាក្យថា **បពិត្រព្រះគោតមដ៏ចម្រើន (ភាពជសមណៈ និងភាពជាព្រាហ្មណ៍ ធ្វើបានលំបាក** កស្សបៈពោលថា កាលមុនពួកខ្ញុំព្រះអង្គយល់ថា ភាពជាសមណៈ និងជាព្រាហ្មណ៍ មានត្រឹមតែប៉ុណ្ណេះ តែព្រះអង្គត្រាស់ភាពជាសមណៈ និងជាព្រាហ្មណ៍ជាយ៉ាងដទៃ ។

ពាក្យថា **ពាក្យនេះជាប្រក្រតី** គឺ ពាក្យនេះ ជាសំដីប្រក្រតី ។ ពាក្យថា **ម្នាលកស្សបៈ ( ភាពជាសមណៈ ឬព្រាហ្មណ៍ ធ្វើបានលំបាក )**

ប្រមាណប៉ុណ្ណេះ គឺថា ម្នាលកស្សបៈ ប្រសិនបើថា ភាពជាសមណៈ ឬភាពជាព្រាហ្មណ៍ដោយប្រមាណនេះ បានដល់ ដោយវត្តបដិបត្តិបន្តិចបន្តួចយ៉ាងនេះ នឹងឈ្មោះថា ធ្វើបានដោយលំបាក បានដល់ ធ្វើបានលំបាកក្រៃលែងហើយអំពីនោះ សេចក្តីនេះនឹងមិនគួរពោលថា ភាពជាសមណៈធ្វើបានលំបាក ភាពជាព្រាហ្មណ៍ធ្វើបានលំបាក ដូច្នេះ នេះជាអត្ថាធិប្បាយ និងដោយការភ្ជាប់បទក្នុងសេចក្តីនេះ ។ ការភ្ជាប់បទក្នុងទីទាំងពួង គប្បីជ្រាបដោយន័យនេះ ។

[៧១] ពាក្យថា **ដឹងបានដោយក្រ** នេះ អចេលកស្សបៈនោះ ពោលសំដៅយកពាក្យនេះថា កាលមុនពួកខ្ញុំព្រះអង្គយល់ថា ជាសមណៈ ឬជាព្រាហ្មណ៍ដោយហេតុប៉ុណ្ណេះ តែព្រះអង្គត្រាស់ដោយប្រការដទៃ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បដិសេធពាក្យជំទាស់នោះ របស់កស្សបៈនោះហើយ ទ្រង់បើកបង្ហាញនូវភាពជាអ្នកដឹងបានដោយក្រតាមសភាពពិត ហើយត្រាស់ពាក្យមានជាដើមថា **ជាប្រក្រតី** ទៀត ។ គប្បីភ្ជាប់បទហើយជ្រាបសេចក្តី ដោយន័យដែលបានពោលហើយសូម្បីក្នុងសេចក្តីនោះ ។

## សម្បទា ៣ យ៉ាង

[៧២] ព្រោះហេតុណា អចេលកស្សបៈទើបសួរថា **បពិត្រព្រះគោតមដ៏ចម្រើន សីលសម្បទាតើដូចម្តេច** ជាដើម ។ បានឮថា អចេលកស្សបៈនេះជាអ្នកឆ្លាត កាលព្រះដ៏មានព្រះភាគត្រាស់ហើយ ទើបសិក្សាពាក្យខាងក្រោយដឹងការបដិបត្តិរបស់ខ្លួនថា មិនជាប្រយោជន៍ ទើបគិតថា ព្រះសមណគោតមត្រាស់ពាក្យជាដើមថា ក៏សីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទានេះ ដែលគេមិនបានអប់រំហើយ មិនបានធ្វើឲ្យច្បាស់ហើយ គេឆ្ងាយចាកភាពជាសមណៈដោយពិត ដូច្នេះ ណ្ហើយចុះ ឥឡូវនេះយើងនឹងសួរដល់សម្បត្តិទាំងនោះចំពោះព្រះដ៏មានព្រះភាគ ទើបទូលសួរដើម្បីដឹងច្បាស់សីលសម្បទាជាដើម ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សម្តែងការកើតឡើងនៃព្រះពុទ្ធ កាលនឹងត្រាស់ដល់បែបផែន ដើម្បីសម្តែងដល់ភាពដល់ព្រមទាំងនោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សបៈ (តថាគតកើតឡើងក្នុងលោក) នេះ ។ ពាក្យថា **ម្នាលកស្សបៈ** (សីលសម្បទាដទៃ ដែលក្រៃលែងជាង ប្រណីតជាង) សីលសម្បទា (មិនមាន) ទ្រង់ត្រាស់សំដៅដល់ព្រះអរហត្តផល ។ ពិតណាស់

សាសនារបស់ព្រះដ៏មានព្រះភាគ មានព្រះអរហត្តផលជាទីបំផុត ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា ការដល់ព្រមដោយសីលជាដើមដទៃ ដែលក្រៃលែងជាង ឬប្រណីតជាង ការដល់ព្រមដោយសីល ចិត្ត និងបញ្ញា ដែលប្រកបដោយព្រះអរហត្តផលមិនមាន ក៏កាលត្រាស់យ៉ាងនេះហើយ ។

## សីហនាទក្នុងបរិសទ្យ

[៧៣] ឥឡូវនេះ កាលទឹងទ្រង់បន្លឺសីហនាទដែលក្រៃលែង ទើបត្រាស់ពាក្យឡើងជាដើមថា ម្នាលកស្សបៈ មានសមណព្រាហ្មណ៍នៅពួកមួយ ៗ

ក្នុងពាក្យទាំងនោះ ពាក្យថា **ប្រសើរ** គឺ ប្រាសចាកឧបក្កិលេស បរិសុទ្ធិយ៉ាងក្រៃលែង ។ ពាក្យថា **ដ៏ក្រៃលែង** គឺ ខ្ពស់បំផុត ។ ក៏សីលរាប់អំពីសីល ៥ ជាដើម រហូតដល់ បាតិមោក្ខសំវរសីល ឈ្មោះថា សីលដូចគ្នា ចំណែកសីលដែលប្រកបដោយលោកុត្តរមគ្គ និងផល ឈ្មោះ បរមសីល ។ ពាក្យថា **ក៏តថាគត (មិនឃើញ) ក្នុងសីលនោះ** មានអត្ថថា តថាគតមិនឃើញបុគ្គលដែលស្មើៗ របស់ខ្លួន បានដល់ បុគ្គលដែលស្មើនឹងតថាគតដោយសីល ដែលស្មើដោយសីលរបស់តថាគត សូម្បីក្នុងសីល សូម្បីក្នុងបរមសីលនោះ ។ ពាក្យថា **តថាគតហ្នឹងឯង ជាអ្នកក្រៃលែងក្នុងសីលនោះ** គឺ តថាគតប៉ុណ្ណោះ ជាអ្នកខ្ពស់បំផុតក្នុងសីលនោះ ។ សួរថា ត្រាស់ទុកក្នុងទីណា ។

ឆ្លើយថា ក្នុងអធិសីល ។

ពាក្យថា **អធិសីល** អធិប្បាយថា អធិសីលនេះ ជាឧត្តមសីល ។ ព្រះដ៏មានព្រះភាគទ្រង់បន្លឺសីហនាទនេះ ជាគ្រាដំបូង ដូច្នេះ ។

ពាក្យថា **ជាអ្នកពោលខ្ពើមដោយតបះ** គឺ បុគ្គលដែលតិះដៀលតបះ ។

ក្នុងពាក្យនោះ សេចក្តីព្យាយាមណា រមែងដុត (កិលេស) ដូច្នោះ សេចក្តីព្យាយាមនោះ ឈ្មោះថា **តប** នោះ ជាឈ្មោះរបស់សេចក្តីព្យាយាម ដែលដុតកិលេស ។ តបៈនោះ រមែងខ្ពើមកិលេសទាំងនោះ ហេតុនោះ តបៈនោះ ឈ្មោះថា ការខ្ពើម ។

ក្នុងបទថា **អរិយៈដ៏ក្រៃលែង** នេះ សេចក្តីថា ឈ្មោះថា **អរិយ** ព្រោះប្រាសចាកទោស ការខ្ពើមដោយតបៈ ពោលគឺ សេចក្តីព្យាយាមដោយវិបស្សនា កើតឡើងដោយអំណាចនៃវត្ថុ មានអារម្មណ៍ ៨ ប្រការ ឈ្មោះថា ការខ្ពើមដោយតបៈនោះឯង ។ បញ្ញាដែលសម្បយុត្តដោយមគ្គ និងផល ឈ្មោះថា **កំពូល** ។ ការខ្ពើមក្នុងបទនេះថា **អធិជេគុច្ឆំ** ជាការខ្ពើម ការខ្ពើមយ៉ាងក្រៃលែង ឈ្មោះថា **អធិជេគុច្ឆំ** ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទនោះ យ៉ាងនេះថា គឺ **អធិជេគុច្ឆ** តថាគតតែមួយអង្គ ជាបុគ្គលក្រៃលែងក្នុងអធិជេគុច្ឆៈនោះ ។ មានអធិប្បាយសូម្បីក្នុងបញ្ញាធិការ ។ កម្មស្សក-

តាបញ្ញា និងវិបស្សនាបញ្ញា ឈ្មោះថា **បញ្ញា** ។ បញ្ញាដែលសម្បយុត្តដោយមគ្គ និងផល ឈ្មោះថា **បរមបញ្ញា** ។ ក្នុងពាក្យថា អធិប្បញ្ញំ នេះ គប្បីជ្រាបថា ជាលិង្គវិបល្លាស អត្ថក្នុងបទនោះមានយ៉ាងនេះ គឺ ឈ្មោះថា អធិប្បញ្ញានេះណា តថាគតតែមួយអង្គ ជាបុគ្គលក្រៃលែងក្នុងអធិប្បញ្ញានោះ ។

ក្នុងវិមុត្តាធិការមានអត្ថដូច្នេះ ។ តទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ឈ្មោះថា **វិមុត្តិ** ។ ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ គប្បីជ្រាបថាជា **បរមវិមុត្តិ** ។ ក៏ក្នុងបទនេះថា យទិទំ អធិវិមុត្តិ មានអត្ថថា អធិវិមុត្តិនេះណា តថាគតតែមួយអង្គ ជាបុគ្គលក្រៃលែងក្នុងអធិវិមុត្តិនោះ ។

[៧៤] បទថា សុញ្ញាគារេ អធិប្បាយថា អង្គុយម្នាក់ឯងក្នុងផ្ទះស្ងាត់ ។ បទថា បរិសាសុ ច សេចក្តីថា ក្នុងបរិស័ទ ៨ ។ សមពិតដូចព្រះពុទ្ធ-តម្រាស់ដែលត្រាស់ថា ម្នាលសារីបុត្រ វេសារជ្ជញាណ ៤ នេះ ដែលតថាគតដល់ព្រមហើយ ទើបប្តេជ្ញាអាសភស្ថាន បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយដូច្នេះ ។ ព្រះសូត្រគប្បីឲ្យពិស្តារ ។ បទថា បញ្ហញ្ច នំ បុច្ឆន្តិ សេចក្តីថា ទេវតា និងមនុស្សទាំងឡាយដែលជាបណ្ឌិត រួបរួមបញ្ហាហើយ រមែងទូលសួរ ។ បទថា ព្យាករោតិ សេចក្តីថា ទ្រង់ដោះស្រាយក្នុងខណៈនោះភ្លាម ។

បទថា ចិត្តំ អារាធេតិ សេចក្តីថា ទ្រង់ញុំាងចិត្តរបស់មហាជនឲ្យត្រេកអរ ដោយការដោះស្រាយបញ្ហា ។ បទថា នោ ច ខោ សោតព្វំ មញ្ញន្តិ សេចក្តីថា សូម្បីកាលព្រះអង្គត្រាស់ធ្វើចិត្តឲ្យត្រេកអរ ពួកអ្នកដទៃក៏មិនទាស់ចិត្តក្នុងការស្តាប់ អធិប្បាយថា គប្បីពោលយ៉ាងនោះ ។ បទថា សោតព្វញ្ញស្ស មញ្ញន្តិ សេចក្តីថា ទេវតាក្តី មនុស្សក្តី រមែងពេញចិត្តស្តាប់ដោយសេចក្តីឧស្សាហ៍ធំ ។ បទថា បសីទន្តិ សេចក្តីថា ជាអ្នកជ្រះថ្លាល្អហើយ មានចិត្តទន់ ។ បទថា បសន្នាការំ ករោន្តិ សេចក្តីថា មិនមែនជាអ្នកល្ងង់ហើយជ្រះថ្លា កាលបរិច្ចាគវត្ថុ មានចីវរជាដើម ដែលប្រណីត និងមហាវិហារ មានវេឡុវ័នវិហារជាដើម ឈ្មោះថា ធ្វើអាការនៃអ្នកជ្រះថ្លា ។ បទថា តថត្តាយ សេចក្តីថា ព្រះដ៏មានព្រះភាគនោះ ទ្រង់សម្តែងធម៌ណា រមែងបដិបត្តិដើម្បីមាននៃធម៌ដោយប្រការនោះ គឺ ដើម្បីប្រយោជន៍ដល់ការបដិបត្តិធម៌សមគួរដល់ធម៌ ។ បទថា តកាថត្តាយ ច បដិបជ្ជន្តិ សេចក្តីថា រមែងបដិបត្តិដើម្បីមានយ៉ាងនោះ ។ ពិតហើយ ទេវតា និងមនុស្សស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគអង្គនោះហើយ ពួកខ្លះតាំងនៅក្នុងសរណៈ ពួកខ្លះតាំងនៅក្នុងសីល ៥ ពួកខ្លះចេញបួស ។ បទថា បដិបន្នា ច អារាធេន្តិ

សេចក្តីថា ក៏អ្នកបដិបត្តិបដិបទានោះ រមែងញុំាងឲ្យបរិបូណ៌ តែឲ្យបរិបូណ៌ ដោយអាការទាំងពួង គប្បីពោលថា រមែងញុំាងចិត្តរបស់ព្រះគោតមដ៏ចម្រើន នោះឲ្យត្រេកអរ ដោយការបំពេញការបដិបត្តិ ។ ក៏បណ្ឌិតតាំងនៅក្នុងឱកាស នេះហើយ គប្បីប្រមូលសីហនាទទាំងឡាយ ។

ក៏សីហនាទមួយរបស់ព្រះដ៏មានព្រះភាគថា តថាគតបានឃើញអ្នក បំពេញតបៈខ្លះកើតក្នុងនរក ។ សីហនាទមួយថា តថាគតបានឃើញអ្នកខ្លះ កើតក្នុងសួគ៌ ។ សីហនាទមួយថា តថាគតតែម្នាក់ ជាអ្នកប្រសើរបំផុត ក្នុង ការលះអកុសលធម៌ ។ សីហនាទមួយថា តថាគតតែម្នាក់ ជាអ្នកប្រសើរ ទីបំផុត សូម្បីក្នុងការសមាទានកុសលធម៌ ។ សីហនាទមួយថា សង្ឃសាវក របស់តថាគតប៉ុណ្ណោះ ជាអ្នកប្រសើរបំផុតក្នុងការលះអកុសលធម៌ ។ សីហ-នាទមួយថា សង្ឃសាវកតថាគតប៉ុណ្ណោះ ជាអ្នកប្រសើរបំផុត សូម្បីក្នុងការ សមាទានកុសលធម៌ ។ សីហនាទមួយថា មិនមានអ្នកណាដូចតថាគតដោយ សីល ។ សីហនាទមួយថា មិនមានអ្នកណាដូចតថាគតដោយវីរិយៈ ។ សីហនាទមួយថា មិនមានអ្នកណាដូចតថាគត ដោយបញ្ញា ។ សីហនាទ មួយថា មិនមានអ្នកណាដូចតថាគតដោយវិមុត្តិ ។ សីហនាទមួយថា យើង

បន្លឺសីហនាទ ក៏អង្គុយត្រង់កណ្តាលបរិស័ទបន្លឺ ។ សីហនាទមួយថា តថាគតជាអ្នកអង់អាចក្នុងការបន្លឺ ។ សីហនាទមួយថា ទេវតា និងមនុស្សរមែងសួរបញ្ហាចំពោះតថាគត ។ សីហនាទមួយថា តថាគតនឹងដោះស្រាយបញ្ហា ។ សីហនាទមួយថា តថាគតនឹងញ៉ាំងចិត្ត របស់អ្នកដទៃឲ្យត្រេកអរដោយការដោះស្រាយ ។ សីហនាទមួយថា ស្តាប់ហើយ រមែងពេញចិត្តនឹងស្តាប់ ។ សីហនាទមួយថា ស្តាប់ហើយ រមែងជ្រះថ្លាក្នុងតថាគត ។ សីហនាទមួយថា ជ្រះថ្លាហើយ រមែងធ្វើអាការរបស់អ្នកជ្រះថ្លា ។ សីហនាទមួយថា តថាគតសម្តែងការបដិបត្តិណា ទេវតា និងមនុស្ស រមែងបដិបត្តិដើម្បីសភាពជាយ៉ាងនោះ ។ សីហនាទមួយថា នឹងរមែងឲ្យតថាគតត្រេកអរដោយការបដិបត្តិ ។ សីហនាទទាំងឡាយជាដើមថា បន្លឺក្នុងបរិស័ទទាំងឡាយនៃបរិស័ទមុនតែមួយយ៉ាងៗ ១០ ជាដើម រួមជាបរិវារតែមួយយ៉ាងៗ ១០ ដោយប្រការដូច្នេះ ។ សីហនាទមានមួយរយ គឺ សីហនាទ ១០ ទាំងនោះរួមជា ១០០ ដោយអំណាចនៃបរិវាររបស់សីហនាទ ១០ និងសីហនាទ ១០ មុន ។ ក៏ក្នុងព្រះសូត្រដទៃពីព្រះសូត្រនេះ សីហនាទមានប្រមាណត្រឹមប៉ុណ្ណោះ មិនជាការលំបាក ព្រោះហេតុនោះ សូត្រនេះទើបហៅថា **មហាសីហនាទសូត្រ** ។

ព្រះដ៏មានព្រះភាគ ទ្រង់បដិសេធវាទ: និងអនុវាទ: យ៉ាងនេះថា ព្រះសមណគោតម រមែងបន្លឺសីហនា តែបន្លឺក្នុងផ្ទះទទេ ឥឡូវនេះកាល នឹងទ្រង់សម្តែងសីហនាទ ដែលធ្លាប់បន្លឺហើយក្នុងបរិស័ទទៀត ទើបត្រាស់ ពាក្យមានជាអាទិថា ឯកមិទាហំ ដោយប្រការដូច្នេះ ។

## តិត្ថិយបរិវាស

ក្នុងបទទាំងនោះ បទថា តត្រ មំ អញ្ញតរោ តេ សព្រហ្មចារី សេចក្តីថា ដើម្បីព្រហ្មចារីរបស់លោកម្នាក់ ឈ្មោះនិគ្រោធបរិព្វាជក (បានសួរបញ្ហា) ចំពោះតថាគតនៅត្រង់ភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះនោះ ។ បទថា អធិជិគុច្ឆេ សេចក្តីថា សួរបញ្ហាក្នុងរឿងខ្ពើមបាប ដោយវីរិយៈ ។ ព្រះមានព្រះភាគប្រថាប់គង់ក្នុងមហាវិហារខាងភ្នំគិជ្ឈកូដ ទ្រង់ស្តាប់ពាក្យសន្ទនារបស់និគ្រោធបរិព្វាជក និងសន្ធានឧបាសក ដែលអង្គុយក្នុងឧទ្យានរបស់ព្រះនាងឧទុម្ពរិកាទេវី ដោយទិព្វសោតធាតុ ស្តេចក៏ពុទ្ធដំណើរតាមអាកាស មកប្រថាប់គង់លើអាសនៈដែលបានក្រាលទុក ក្នុងសំណាក់របស់អ្នកទាំងពីរនោះ ហើយទ្រង់បានដោះស្រាយបញ្ហា ដែលនិគ្រោធបរិព្វាជកទូលសួរក្នុងរឿងខ្ពើមយ៉ាងក្រៃលែងនេះឯណា លោកពោលសំដៅដល់បញ្ហានោះ ។ បទថា បរំ វិយ មត្តាយ សេចក្តីថា ដោយប្រមាណយ៉ាងក្រៃលែង គឺ ដោយប្រមាណធំ ។

**[៧៥]** បទថា កោ ហិ ភន្តេ សេចក្តីថា អ្នកដទៃដែលមានជាតិបណ្ឌិត វៀរអន្ធពាលអ្នកមានទិដ្ឋិណាហ្ន៎ ដែលស្តាប់ព្រះធម៌របស់ព្រះមាន-

ព្រះភាគហើយ ពោលថា មិនគប្បីសប្បាយចិត្ត ។ គេគិតថា យើងប្រកបខ្លួន ក្នុងចំណែកដែលមិននាំចេញចាកទុក្ខ បានទទួលសេចក្តីលំបាកអស់កាលយូរ ហ្ន៎ យើងផ្លូតទឹកក្នុងត្រើយទន្លេរីងស្ងួត យើងដូចប្រមៀលត្រឡប់ទៅត្រឡប់មក ដូចពោយអង្កាម ក៏មិនញុំាងប្រយោជន៍អ្វីឲ្យសម្រេចបាន ណ្ហើយចុះ យើងនឹងប្រកបខ្លួនទុកក្នុងសេចក្តីព្យាយាម ទើបទូលថា ខ្ញុំព្រះអង្គគប្បីបាន ដូច្នេះ ។

មួយទៀត តិត្ថិយបរិវាសណា ដែលព្រះអង្គទ្រង់បញ្ញត្តិទុកក្នុងខន្ធកៈ ដែលអ្នកធ្លាប់ជាអន្យតិត្ថិយតាំងនៅក្នុងសាមណេរភូមិ នឹងត្រូវសមាទាននៅបរិវាសដោយន័យជាដើមថា បពិត្រលោកដ៏ចម្រើន ខ្ញុំធ្លាប់ជាអន្យតិត្ថិយ ឈ្មោះនេះ ប្រាថ្នាឧបសម្បទក្នុងព្រះធម៌វិន័យនេះ ខ្ញុំនោះ សូមសង្ឃនៅបរិវាសរហូតដល់អស់បួនខែ ដូច្នេះ ព្រះដ៏មានព្រះភាគទ្រង់សំដៅដល់តិត្ថិយ-បរិវាសនោះ ទើបត្រាស់ថា ម្នាលកស្សបៈអ្នកធ្លាប់ជាអន្យតិត្ថិយ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា បព្វជ្ជំ លោកពោលដោយអំណាចសេចក្តីស្អាតរៀបរយនៃវចនៈប៉ុណ្ណោះ ។ ព្រោះមិននៅបរិវាសឡើយ រមែងបាន

បព្វជ្ជា ។ តែអ្នកត្រូវការឧបសម្បទគប្បីនៅបរិវាស បំពេញវត្ត ៨ ប្រការ ជាដើមថា ការចូលស្រុកតាមកាលពិសេស ។

[៧៦] បទថា អារទ្ធចិត្តា សេចក្តីថា មានចិត្តត្រេកអរដោយការបំពេញវត្ត ៨ ។ សេចក្តីសង្ខេបក្នុងបទនោះ ដូច្នេះ ។ ចំណែកតិត្ថិយបរិវាសនោះ គប្បីពោលឲ្យពិស្តារ ដោយន័យដែលពោលទុកក្នុងបព្វជ្ជាខន្ធកវណ្ណនាក្នុងវិនយដ្ឋកថា ឈ្មោះសមន្តបាសាទិកានោះចុះ ។

បទថា អបិ មេត្ថ តែថាយើងដឹង (ការផ្សេងគ្នានៃបុគ្គល) ក្នុងសេចក្តីនេះ ។ បទថា បុគ្គលវេមត្តតា វិទិតា សេចក្តីថា តថាគតដឹងសេចក្តីផ្សេងៗ នៃបុគ្គល ។ ព្រះដ៏មានព្រះភាគទ្រង់ដឹងថា បុគ្គលនេះគួរនៅបរិវាស នេះមិនគួរនៅបរិវាស ទើបទ្រង់សម្តែងថា ប្រការនេះប្រាកដដល់តថាគត ។ លំដាប់នោះ កស្សបៈគិតថា ឱហ្ន៎ ព្រះពុទ្ធសាសនាជារបស់អស្ចារ្យ ដែលបុគ្គលទាំងឡាយប្រកាសហើយ សម្តែងចេញហើយយ៉ាងនេះ រមែងកាន់យកវត្ថុដែលគួរប៉ុណ្ណោះ លះបោលវត្ថុដែលមិនគួរ មានសេចក្តីឧស្សាហ៍កើតឡើងព្រមក្នុងបព្វជ្ជាដ៏ក្រៃលែងជាងនោះ ទើបទូលថា សចេ ភន្តេ ដូច្នេះជាដើម ។

លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ដឹងសេចក្តីដែលកស្សបៈនោះ ជាអ្នកមានឆន្ទៈខ្លាំងក្លាថា កស្សបៈមិនគួរនៅបរិវាស ទើបត្រាស់ហៅភិក្ខុដទៃមកថា ម្នាលភិក្ខុ អ្នកចូរទៅនាំកស្សបៈនោះងូតទឹក ហើយឲ្យបព្វជ្ជា ។ ភិក្ខុនោះ បានធ្វើតាមព្រះតម្រាស់យ៉ាងនោះ ឲ្យកស្សបៈបួសហើយ នាំគ្នាទៅកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ឲ្យកស្សបៈនោះ អង្គុយត្រង់កណ្តាលគណៈ ហើយទ្រង់ឲ្យឧបសម្បទ ។ ដោយហេតុនោះលោកទើបពោលថា អចេលកស្សបៈបានបព្វជ្ជា បានឧបសម្បទ ក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ ។

បទថា អចិរូបសម្បន្នោ សេចក្តីថា ជាអ្នកឧបសម្បទាហើយមិនយូរ ។ បទថា វូបកដ្ឋោ សេចក្តីថា ជាអ្នកមានកាយ និងចិត្តស្ងប់ចាកវត្ថុកាម និងកិលេសកាមទាំងឡាយ ។ បទថា អប្បមត្តោ សេចក្តីថា មិនលះបង់សតិក្នុងកម្មដ្ឋាន ។ បទថា អាតាបិ សេចក្តីថា ដុត មានការដុតដោយវីរិយៈ ពោលគឺ សេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។

បទថា បហិតត្តោ សេចក្តីថា មានចិត្តបញ្ជូនហើយ គឺ មានអត្តភាពលះបង់ហើយ ព្រោះភាពជាអ្នកមិនមានសេចក្តីហួងហែងក្នុងកាយ និងជីវិត ។

បទថា យស្សត្ថាយ សេចក្ដីថា ដើម្បីផលឯណា ។ បទថា កុលបុត្តា បានដល់ កុលបុត្រអ្នកមានមារយាទ ។ បទថា សម្មទេវ សេចក្ដីថា ដោយហេតុនោះឯង ដោយការណ៍នោះឯង ។ បទថា តទនុត្តរំ សេចក្ដីថា ប្រយោជន៍ដ៏ប្រសើរនោះ ។ បទថា ព្រហ្មចរិយបរិយោសានំ សេចក្ដីថា ព្រះអរហត្តផលដែលជាទីបំផុតដោយជុំវិញនៃមគ្គព្រហ្មចរិយៈ ។ ក៏កុលបុត្រទាំងឡាយ រមែងបួសដើម្បីផលយ៉ាងនោះ ។ បទថា ទិដ្ឋេវ ធម្មេ សេចក្ដីថា ក្នុងអត្តភាពនេះឯង ។

បទថា សយំ អភិញ្ញា សច្ឆិកត្វា សេចក្ដីថា ធ្វើឲ្យប្រចក្សដោយបញ្ញាដោយខ្លួនឯង គឺ ដឹងដោយមិនមានអ្នកដទៃជាបច្ច័យ ។ បទថា ឧបសម្បជ្ជ វិហរតិ សេចក្ដីថា សម្រេចហើយ ឲ្យដល់ព្រមហើយ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងភូមិនៃបច្ចវេក្ខណៈរបស់កស្សបៈនោះយ៉ាងនេះថា ភិក្ខុកាលរស់នៅយ៉ាងនេះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ ។ល។ ញុាំងទេសនាឲ្យចប់ស្រេចដោយធម៌ដ៏ប្រសើរ គឺ ព្រះអរហត្ត ទើបត្រាស់ថា បណ្ដាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា អញ្ញតរោ សេចក្ដីថា

មួយអង្គ ។ បទថា អរហន្តំ សេចក្តីថា នៃព្រះអរហន្តទាំងឡាយ ។ ក្នុងបទនោះ មានអធិប្បាយយ៉ាងនេះថា ជាព្រះអរហន្តមួយអង្គ ក្នុងចំណោមព្រះអរហន្តសាវករបស់ព្រះដ៏មានព្រះភាគ ។ ក៏បទណាៗ មិនបានពោលទុកតាមលំដាប់បទនោះៗ ប្រាកដហើយ ព្រោះបានពោលហើយក្នុងទីនោះៗ ដូច្នេះឯង ។

" ចប់ មហាសីហនាទសូត្រ ទី ៨ "

# ចោដ្ឋចានសូត្រ ទី ៩

## រឿងចោដ្ឋចានបរិព្វាជក

**[៧៧]** ឯវម្មេ សុតំ ។បេ។ សាវត្ថិយន្តិ ចោដ្ឋចាន សុត្តំ ។

*ក្នុងបោដ្ឋបាទសូត្រនោះ មានពាក្យពណ៌នាតាមលំដាប់បទដូចតទៅនេះ ៖*

*បទថា* សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ *សេចក្តីថា ប្រថាប់នៅក្នុងវត្តជេតវនារាម ដែលអនាថបិណ្ឌិកសេដ្ឋីសាងក្នុងសួនរបស់រាជកុមារព្រះនាមថា* ***ជេត*** *ជិតក្រុងសាវត្ថី ។*

*បទថា* ចោដ្ឋចានោ បរិព្វាជកោ *សេចក្តីថា ឆន្នបរិព្វាជក ឈ្មោះ* ***បោដ្ឋបាទ*** *។ បានឮថា ក្នុងកាលជាគ្រហស្ថ គេជាព្រាហ្មណ៍មហាសាល ឃើញទោសក្នុងកាមទាំងឡាយ ហើយលះបង់កោគទ្រព្យចំនួនសែសិបកោដិ បួសជាគណាចារ្យរបស់តិរ្ថិយទាំងឡាយ ។ ព្រាហ្មណ៍ និងបព្វជិតទាំងឡាយ រមែងជជែកគ្នាអំពីលទ្ធិក្នុងស្ថានទីនោះ ព្រោះដូច្នោះ ស្ថានទីនោះ ទើបឈ្មោះថា* ***សមយប្បវាទកំ*** *ជាទីសម្រាប់ជជែកគ្នាពីលទ្ធិ ។ ន័យថា ព្រាហ្មណ៍ទាំងឡាយ*

មានចង្កីព្រាហ្មណ៍ រុក្ខព្រាហ្មណ៍ និងបោក្ខរសាតិព្រាហ្មណ៍ជាដើម និងបព្វជិតទាំងឡាយ មាននិគណ្ឋបរិព្វាជក និងអចេលបរិព្វាជកជាដើម ប្រជុំគ្នាក្នុងស្ថានទីនោះ ហើយជជែកឆ្លើយឆ្លង ពោលសម្ដែងលទ្ធិរៀងៗ ខ្លួន ក្នុងស្ថានទីនោះ ព្រោះដូច្នោះ អារាមនោះ ទើបហៅថា **សមយប្បវាទកោ** ។ អារាមនោះឯង ឈ្មោះថា **មានជួរនៃដើមទន្លាប់ព័ទ្ធជុំវិញ** ព្រោះជាអារាម ដែលមានជួរដើមទន្លាប់ គឺ ជួរដើមទន្លាប់ហោមព័ទ្ធជុំវិញ ។ ក៏ព្រោះក្នុងអារាមនោះក្នុងថ្នាក់ដំបូង មានសាលាត្រឹមតែមួយខ្នងប៉ុណ្ណោះ ក្រោយមកជនទាំងឡាយអាស្រ័យបរិព្វាជកអ្នកមានបុណ្យច្រើន សាងសាលាច្រើនខ្នង ព្រោះដូច្នោះ អារាមនោះ ទើបហៅថា **ឯកសាលកោ** ដោយអំណាចនៃឈ្មោះដែលបានមក ព្រោះអាស្រ័យសាលាមួយខ្នងនោះឯង ។ ក៏អារាមនោះសម្បូរណ៍ដោយផ្កា និងផ្លែ ជាសួនព្រះនាងមល្លិកាពជទេវីរបស់ព្រះបាទបសេនទិកោសលសាងថ្វាយ ទើបហៅថា **មល្លិកាយារាម** ។ ក្នុងស្ថានទីសម្រាប់ជជែកឆ្លើយឆ្លងលទ្ធិ ជួរព្រៃឈើទន្លាប់ មានសាលាសម្រាប់សម្រាកមួយខ្នង ជាអារាមរបស់ព្រះនាងមល្លិកានោះ ។ បទថា បដិវសតិ សេចក្ដីថា ទីសម្រាក ព្រោះជាទីនៅសុខស្រួល ។

តមកថ្ងៃមួយក្នុងបច្ចូសសម័យ ព្រះដ៏មានព្រះភាគ ទ្រង់ផ្សាយព្រះសព្វ-ញ្ញុតញ្ញាណ ទ្រង់ពិចារណាមើលលោក ទ្រង់ឃើញបរិព្វាជកចូលមកខាងក្នុងសំណាញ់ គឺ ព្រះញាណ ទ្រង់ពិចារណាថា បោដ្ឋបាទៈនេះ រមែងប្រាកដក្នុងសំណាញ់ គឺ ញាណរបស់តថាគត នឹងមានដែរឬ ដូច្នេះ ទ្រង់ឃើញថាក្នុងថ្ងៃនេះ តថាគតនឹងទៅក្នុងអារាមនោះ លំដាប់នោះបោដ្ឋបាទៈ នឹងសួរតថាគតដល់និរោធ និងការចេញចាកនិរោធ តថាគតនឹងប្រៀបធៀបដោយញាណរបស់ព្រះពុទ្ធទាំងពួង សម្ដែងទាំងពីរយ៉ាងនោះ ដល់បោដ្ឋបាទៈនោះលុះកន្លងទៅ ២-៣ ថ្ងៃ គេនឹងនាំចិត្តៈ ដែលជាបុត្រទ្រមាក់ដំរីមកកាន់សម្នាក់របស់តថាគត តថាគតនឹងសម្ដែងធម៌ដល់គេទាំងពីរនាក់នោះ ក្នុងទីបំផុតទេសនា បោដ្ឋបាទៈនឹងដល់តថាគតជាសរណៈ ចិត្តៈបុត្រទ្រមាក់ដំរី បួសក្នុងសម្នាក់របស់តថាគតនឹងសម្រេចព្រះអរហត្ត ដូច្នេះ ។ តពីនោះ ព្រះដ៏មាន-ព្រះភាគទ្រង់ធ្វើការបដិបត្តិព្រះសរីរៈពីព្រឹកព្រលឹម ទ្រង់ប្រដាប់អន្តរវាសកៈពីរជាន់ដែលជ្រលក់ល្អហើយ ទ្រង់ក្រវាត់ព្រះវត្ថពន្ធចង្កេះ ដូចជាផ្ទេកបន្ទោរទ្រង់ដណ្ដប់សំពត់បង្សុកូលពណ៌មេឃ ប្រដូចជាមហាមេឃលោមព័ទ្ធជុំវិញភ្នំយុគន្ធរ ដូច្នោះ ទ្រង់ប្រដាប់បាត្រសិលាដែលមានតម្លៃច្រើន ដោយព្រះអង្សៈ

ម្ខាង ទ្រង់ព្រះតម្រិះថា តថាគតនឹងចូលទៅក្នុងក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ស្តេចលីលាចេញចាកព្រះវិហារ ដូចរាជសីហ៍ចេញចាកជើងភ្នំហិមពាន្តដូច្នោះ ។ លោកសំដៅដល់អត្ថនេះ ទើបពោលថា អថខោ ភគវា ជាដើម ។

បទថា ឯតទហោសិ សេចក្តីថា ព្រះដ៏មានព្រះភាគ ស្តេចយាងជិតទ្វារព្រះនគរហើយ ទ្រង់សម្លឹងមើលព្រះអាទិត្យ ដោយការព្រះទ័យរបស់ព្រះអង្គ ទ្រង់ឃើញថា វេលានៅព្រឹក ទើបមានព្រះតម្រិះនោះ ។ បទថា យន្នូនាហំ សេចក្តីថា ជានិបាត ដូចសម្តែងសេចក្តីសង្ស័យ ។ ក៏ព្រះពុទ្ធទាំងឡាយមិនមានសេចក្តីសង្ស័យ ។ តែនោះ ជាចំណែកខាងដើមរបស់ព្រះបរិវិតក្កៈយ៉ាងនេះថា តថាគតនឹងធ្វើកិច្ចនេះ នឹងមិនធ្វើកិច្ចនេះ តថាគតនឹងសម្តែងធម៌ដល់អ្នកនេះ នឹងមិនសម្តែងធម៌ដល់អ្នកនេះ រមែងមានដល់ព្រះពុទ្ធទាំងឡាយ ។ ដោយហេតុនោះ ទើបត្រាស់ថា យន្នូនាហំ សេចក្តីថា ក៏ឯតថាគត ។

**[៧៨]** បទថា ឧន្នាទិនិយា សេចក្តីថា ដែលបន្លឺលាន់ឮខ្លាំង ។ ក៏សំឡេងនោះ ដែលបន្លឺយ៉ាងនេះ ឈ្មោះថា លើ ដោយអំណាចទៅក្នុងចំណែកខាងលើ ឈ្មោះថា សំឡេងខ្លាំង ដោយអំណាចខ្ចរខ្ចាយទៅកាន់ទិសទាំងឡាយ

ព្រោះដូច្នោះ ទើបឈ្មោះថា **ដោយសំឡេងឮខ្លាំង កងរំពង** ។ ពិតហើយ ចេតិយវត្ត ពោធិវត្ត អាចរិយវត្ត ឧបជ្ឈាយវត្ត ឬយោនិសោមនសិការ ដែលឈ្មោះថា គួរក្រោកឡើងធ្វើពីព្រឹក រមែងមិនមានដល់បរិព្វាជកទាំង នោះ ។ ព្រោះហេតុនោះ បរិព្វាជកទាំងនោះ ក្រោកឡើងពីព្រឹកព្រលឹម ហើយ អង្គុយក្នុងទីមានកំដៅថ្ងៃខ្សោយ ប្រារព្ធដល់អវយវៈ មានដៃ និងជើង ជាដើម របស់គ្នានិងគ្នាយ៉ាងនេះថា ដៃរបស់អ្នកនេះល្អ ជើងរបស់អ្នកនេះល្អ ឬប្រារព្ធដល់ពណ៌សម្បុររបស់ស្រី ប្រុស ក្មេងប្រុស និងក្មេងស្រីទាំងឡាយ ឬប្រារព្ធដល់វត្ថុដទៃដែលញុំាងសេចក្ដីត្រេកអរក្នុងកាម និងសេចក្ដីត្រេកអរ ក្នុងភពជាដើម តាំងពាក្យឡើងហើយ ពោលតិរច្ឆានកថាផ្សេងៗ មាននិយាយ ដល់ព្រះរាជាផែនដីជាដើម ដោយលំដាប់ ។ ដោយហេតុនោះ លោកទើប ពោលថា ពោលតិរច្ឆានកថាផ្សេងៗ ដោយសំឡេងដែលលាន់ឮដូច្នេះ ។

តអំពីនោះ បោដ្ឋបាទបរិព្វាជកសម្លឹងមើលបរិព្វាជកទាំងនោះ គិត ថា បរិព្វាជកទាំងនេះ មិនគោរពចំពោះគ្នានិងគ្នាឡើយ និងពួកយើងក៏នឹង ដូចជាអំពិលអំពែកកាលព្រះអាទិត្យរះឡើង ចាប់ផ្ដើមតាំងពីព្រះសមណ- គោតមស្ដេចប្រាកដឡើង សូម្បីលាភសក្ការរបស់ពួកយើងក៏សាបសូន្យទៅ

ក៏បើសមណគោតម សាវករបស់ព្រះគោតម ឬគ្រហស្ថអ្នកទំនុកបម្រុងព្រះ-សមណគោតមនោះ នឹងគប្បីមកកាន់ស្ថានទីនេះសោត ក៏នឹងមានសេចក្តីគួរខ្មាសហួសប្រមាណ មួយវិញទៀត ទោសរបស់បរិស័ទនឹងធ្លាក់ទៅលើប្រធានបរិស័ទប៉ុណ្ណោះ ដូច្នេះ ក្រឡេកមើលជុំវិញ ក៏ឃើញព្រះដ៏មានព្រះភាគ ។ ដោយហេតុនោះ លោកទើបពោលថា បោដ្ឋបាទបរិព្វាជក បានឃើញហើយ ។បេ។ បរិព្វាជកទាំងនោះបាននាំគ្នាស្ងៀម ។

ក្នុងបទទាំងនោះ បទថា សណ្ឋបេសិ អធិប្បាយថា ឲ្យសញ្ជឹងគិតដល់ទោសនៃសំឡេងនោះ គឺ មិនឲ្យមានសំឡេង បញ្ឈប់សំឡេងនោះដោយប្រការដែលសំឡេងនឹងត្រូវស្ងៀមយ៉ាងល្អ ។ ដើម្បីបិទបាំងទោសរបស់សំឡេងនោះ ដូចជាបុរសចូលមកកាន់កណ្តាលបរិស័ទ រមែងស្លៀកសំពត់រៀបរយ ដណ្តប់សំពត់រៀបរយ ជូតទីដែលស្មោកគ្រោកដោយធូលី ដើម្បីបិទបាំងទោស ដូច្នោះ ។ បទថា អប្បសទ្ទា ភោន្តោ សេចក្តីថា កាលឲ្យសញ្ជឹងគិត ក៏ឲ្យស្ងៀមសំឡេងនោះ ដោយប្រការដែលសំឡេងនឹងស្ងៀមយ៉ាងល្អ ។ បទថា អប្បសទ្ទកាមោ សេចក្តីថា មេត្តាធ្វើសំឡេងឲ្យតិចៗម្នាក់អង្គុយ ម្នាក់ឈរ រមែងមិនឲ្យប្រព្រឹត្តទៅដោយការច្របូកច្របល់ដោយ

ពួក ។ បទថា ឧបសង្កមិតព្វំ មញ្ញេយ្យ សេចក្តីថា សម្គាល់ថា ស្តេចនឹងចូល មកក្នុងទីនេះ ។ សួរថា ក៏ព្រោះហេតុអ្វី បោដ្ឋបាទបរិព្វាជកនោះ ទើប ប្រាថ្នាឲ្យព្រះមានព្រះភាគស្តេចយាងចូលមក ។ ឆ្លើយថា ព្រោះប្រាថ្នាសេចក្តី ចម្រើនដល់ខ្លួន ។

បានឮថា បរិព្វាជកទាំងឡាយ គ្រាព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ មកកាន់សម្នាក់របស់ខ្លួនហើយ រមែងលើកខ្លួនឡើងក្នុងសម្នាក់របស់អ្នក ទំនុកបម្រុងទាំងឡាយរបស់ខ្លួន រមែងតាំងខ្លួនទុកក្នុងទីខ្ពស់ថា ក្នុងថ្ងៃនេះ សមណគោតម ស្តេចយាងមកកាន់សម្នាក់របស់ពួកយើង ព្រះសារីបុត្រក៏មក លោកមិនទៅកាន់សម្នាក់របស់អ្នកណាឡើយ អ្នកទាំងឡាយគប្បីមើលភាព ជាធំក្រៃលែងរបស់ពួកយើង ដូច្នេះ ។ រមែងព្យាយាមដើម្បីសេពគប់ឧបដ្ឋាក ទាំងឡាយរបស់ព្រះដ៏មានព្រះភាគផង ។ បានឮថា បរិព្វាជកទាំងនោះ ឃើញ ឧបដ្ឋាកទាំងឡាយរបស់ព្រះដ៏មានព្រះភាគហើយ ពោលយ៉ាងនេះថា គ្រូរបស់ ពួកលោកនឹងជាព្រះគោតមក៏ដោយ នឹងជាសាវករបស់ព្រះគោតមក៏ដោយ រមែងមកកាន់សម្នាក់របស់ពួកយើង ពួកយើងព្រមព្រៀងគ្នា តែលោកទាំង ឡាយ មិនចង់សម្លឹងមើលពួកយើងឡើយ មិនធ្វើសាមីចិកម្ម ពួកយើងធ្វើ

សេចក្ដីខុសអ្វីដល់ពួកលោកហ្ន៎ ។ មួយទៀត មនុស្សពួកខ្លះគិតថា សូម្បីព្រះពុទ្ធទាំងឡាយ រមែងទៅកាន់សម្នាក់របស់បរិព្វាជកទាំងនោះបាន ក៏នឹងទៅកាន់សម្នាក់របស់ពួកយើងបាន មិនមែនឬ ចាប់តាំងពីនោះ គ្រាឃើញព្រះពុទ្ធទាំងឡាយហើយ ក៏មិនប្រមាទ ។

បទថា តុណ្ហី អហេសុំ សេចក្ដីថា ពួកបរិព្វាជកទាំងនោះ អង្គុយជុំវិញពោដ្ឋបាទហើយ ក៏នៅស្ងៀម ។

[៧៩] បទថា ស្វាគតំ ភន្តេ សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន ការយាងមករបស់ព្រះដ៏មានព្រះភាគ ជាការល្អ ។ លោកសម្ដែងទុកថា ក៏គ្រាព្រះដ៏មានព្រះភាគស្ដេចមក ក៏មានសេចក្ដីត្រេកអរ គ្រាស្ដេចទៅក៏សោកសៅ ។ សួរថា ព្រោះហេតុអ្វីពោដ្ឋបាទ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អស់វេលាយូរ សូម្បីក្នុងកាលមុន ព្រះដ៏មានព្រះភាគស្ដេចធ្លាប់ទៅក្នុងទីនោះឬ ។ ឆ្លើយថា ស្ដេចមិនធ្លាប់ទៅ ។ ក៏មនុស្សទាំងឡាយ រមែងពាក់ទាក់ដោយពាក្យគួរស្រឡាញ់ជាដើម យ៉ាងនេះថា លោកទៅណាមកណា លោកវង្វេងផ្លូវឬ លោកមកយូរហើយឬ ដូច្នេះ ព្រោះហេតុនោះ ពោដ្ឋបាទ ទើបទូលយ៉ាងនោះ ។ ក៏គ្រាទូលយ៉ាងនេះហើយ ជាអ្នកមិនរឹងប៉ឹងដោយមានះ

អគ្គិយ តែក្រោកចាកអាសនៈ ហើយធ្វើការទទួលព្រះដ៏មានព្រះភាគ ។ សេចក្តីថា ឃើញព្រះដ៏មានព្រះភាគស្តេចយាងចូលទៅហើយ មិនអញ្ជើញ ដោយអាសនៈ ឬមិនធ្វើការឱនលំទោន ជាការក្រែ ។ ព្រោះហេតុអ្វី ។ ព្រោះជាអ្នកមានត្រកូលខ្ពស់ ។ បរិព្វាជកសូមម្បីនេះ ទះអាសនៈដែលខ្លួន អង្គុយហើយ កាលទូលអញ្ជើញព្រះដ៏មានព្រះភាគដោយអាសនៈ បានទូល ថា សូមព្រះដ៏មានព្រះភាគប្រថាប់គង់ចុះព្រះអង្គ នេះអាសនៈបានរៀបទុក ហើយ ដូច្នេះ ។

បទថា អន្តរាកថា វិប្បកតា សេចក្តីថា ទ្រង់សម្តែងដោយព្រះសព្វញ្ញូ ថា តាំងពីពួកអ្នកអង្គុយមក ដរាបដល់តថាគតមកដល់ សន្ទនាគ្នារឿងអ្វី ដែលបញ្ឈប់ក្នុងចន្លោះនោះ គឺ ពាក្យអ្វីដែលនៅមិនទាន់ចប់ ព្រោះហេតុ តថាគតមកដល់ អ្នកទាំងឡាយចូរប្រាប់ចុះ តថាគតនឹងនាំពាក្យនោះសម្តែង ឲ្យចប់ ។ លំដាប់នោះ បរិព្វាជកពោលថា កថានោះ ជាកថាគ្មានប្រយោជន៍ មិនមានសារៈ អាស្រ័យវដ្តៈ មិនគួរនាំមកពោលចំពោះព្រះភក្ត្ររបស់ព្រះអង្គ ទើបទូលពាក្យជាដើមថា កថានោះចូរវៀរចេញចុះ ព្រះអង្គ ។

# អភិសញ្ញានិរោធ

[៨០] បទថា តិដ្ឋតេសា ភន្តេ សេចក្ដីថា បរិព្វាជកពោលថា បើព្រះដ៏មានព្រះភាគប្រាថ្នានឹងស្ដាប់សោត កថានោះ ទុកនឹងស្ដាប់ខាងក្រោយ ក៏បានមិនលំបាក ក៏ប្រយោជន៍ដោយកថានេះ មិនមានដល់ពួកខ្ញុំព្រះអង្គ តែពួកខ្ញុំព្រះអង្គ បានការយាងមករបស់ព្រះដ៏មានព្រះភាគហើយ នឹងទូលសួរដល់ហេតុការណ៍ល្អយ៉ាងដទៃវិញ ។ តអំពីនោះ កាលនឹងទូលសួរហេតុ-ការណ៍នោះ ទើបទូលពាក្យជាដើមថា បុរិមានិ ភន្តេ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា កោតូហលសាលាយំ សេចក្ដីថា សាលាតែមួយខ្នង ឈ្មោះថា សាលាអ៊ូរអរមិនមាន តែសមណៈ និងព្រាហ្មណ៍ទាំងឡាយអ្នកកាន់លទ្ធិផ្សេងៗ ពោលពាក្យប្រភេទផ្សេងៗ ឲ្យប្រព្រឹត្តទៅក្នុងសាលាណា សាលានោះហៅថា **កោតូហលសាលា** ព្រោះជាទីកន្លែងកើតភាពអ៊ូរអរ ប្របូកប្របល់ដល់ជនជាច្រើនថា អ្នកនេះពោលអ្វី អ្នកនេះពោលអ្វី ។ ពាក្យថា អភិ ក្នុងបទថា អភិសញ្ញានិរោធេ នោះ ត្រឹមតែឧបសគ្គ ។

បទថា សញ្ញានិរោធេ សេចក្ដីថា កថាកើតឡើងហើយក្នុងចិត្តនិរោធ គឺ

ខណិកនិរោធ ។ ក៏ពាក្យថា **ក្នុងសញ្ញានិរោធោ** នេះ ជាហេតុការណ៍កើតឡើងនៃកថានោះ បានឮថា ក្នុងកាលណាព្រះដ៏មានព្រះភាគសម្តែងជាតក ឬទ្រង់បញ្ញត្តិសិក្ខាបទ ក្នុងកាលនោះ សំឡេងសរសើរកិត្តិគុណរបស់ព្រះដ៏-មានព្រះភាគ ក៏ផ្សាយខ្ចរខ្ចាយទៅទូទាំងជម្ពូទ្វីប ។ ពួកតិត្ថិយបានស្តាប់កិត្តិគុណនោះហើយ ក៏ធ្វើកិរិយាផ្ទុយនឹងព្រះដ៏មានព្រះភាគ ន័យថា ព្រះគោតមដ៏ចម្រើន ទ្រង់សម្តែងបុព្វចរិយា ពួកយើងមិនអាចដើម្បីពោលបុព្វចរិយាយ៉ាងដូច្នេះខ្លះ ដូច្នោះខ្លះឬ ពោលលទ្ធិចន្លោះភពមួយ បញ្ញត្តិសិក្ខាបទយ៉ាងណាមួយដល់សាវករបស់ខ្លួនថា ព្រះគោតមដ៏ចម្រើនបានបញ្ញត្តិសិក្ខាបទហើយ ពួកយើងនឹងមិនអាចបញ្ញត្តិឬ ។ ក៏ក្នុងកាលនោះ ព្រះដ៏មានព្រះភាគប្រថាប់គង់ត្រង់កណ្តាលបរិស័ទទាំង ៨ ទ្រង់សម្តែងនិរោធកថា ។

ពួកតិត្ថិយបានស្តាប់និរោធកថានោះហើយ នាំគ្នាប្រជុំពោលថា ន័យថា ព្រះគោតមដ៏ចម្រើនទ្រង់សម្តែងកថា ឈ្មោះនិរោធ សូម្បីពួកយើងក៏នឹងសម្តែង ។ ដោយហេតុនោះ លោកទើបពោលថា កថាបានកើតហើយក្នុងអភិសញ្ញានិរោធ ដូច្នេះ ។

បទថា តត្រេកច្ចេ សេចក្តីថា ក្នុងបណ្តាសមណព្រាហ្មណ៍ទាំងនោះ

ពួកខ្លះ ។

ក៏ក្នុងរឿងនេះ បព្វជិតក្នុងលទ្ធិតិរ្ថិយខាងក្រៅ អ្នកជំបូងណាមួយ ឃើញទោសក្នុងការប្រព្រឹត្តទៅរបស់ចិត្ត ចម្រើនសមាបត្តិថា ការមិនមានចិត្តស្ងប់ហើយ ចុតិចាកពីលោកនេះ ទៅនៅក្នុងអសញ្ញីភពអស់ ៥០០ កប្ប ក៏មកកើតក្នុងលោកនេះទៀត កាលមិនឃើញការកើតឡើងរបស់សញ្ញា និងហេតុក្នុងការរលត់របស់បុគ្គលនោះ ទើបពោលថា មិនមានហេតុ មិនមានបច្ច័យ ។

អ្នកទីពីរបដិសេធពាក្យពោលនោះ កាន់យកសេចក្តីដែលមិគសិង្គិ-តាបស មិនមានសញ្ញា ទើបពោលថា មកកាន់ខ្លះ ទៅប្រាសខ្លះ ។ ន័យថា មិគសិង្គិតាបសមានតបៈក្តៅ មានតបៈខ្លាំងក្លា មានឥន្ទ្រិយតាំងមាំយ៉ាងក្រៃលែង ។ ដោយតេជៈនៃសីលរបស់តាបសនោះ ធ្វើឲ្យវិមានរបស់ស្តេចសក្កៈក្តៅបាន ។ ស្តេចសក្កទេវរាជ ទ្រង់គិតថា តាបសត្រូវការតំណែងស្តេចសក្កៈហ្ន៎ ទើបបញ្ជូនទេវកញ្ញា នាមថា **អលម្ពុសា** ដោយទេវបញ្ជាថា នាងចូរទៅទម្លាយតបៈរបស់តាបស ។ ទេវកញ្ញានោះ ទៅហើយក្នុងទីនោះ ។ តាបសឃើញទេវកញ្ញាក្នុងថ្ងៃជំបូង ក៏ចៀសទៅកាន់បណ្ណសាលា ។

ក្នុងថ្ងៃទីពីរ តាបសត្រូវនីវរណៈ គឺ កាមឆន្ទៈរួបរឹត ទើបចាប់ដៃទៅកញ្ញានោះ ។ តាបសនោះត្រូវទិព្វសម្បត្តិនោះ ក៏អស់សញ្ញា រយៈកាលកន្លងទៅបីឆ្នាំ ទើបត្រឡប់បានសញ្ញា ។ គេឃើញមិគសិង្គីតាបសនោះហើយ ឃើញសេចក្ដីតម្កល់មាំ សម្គាល់ថា ចេញចាកនិរោធដោយកន្លងទៅបីឆ្នាំ ទើបពោលយ៉ាងនោះ ។

អ្នកទីបីបដិសេធពាក្យពោលរបស់អ្នកទីពីរនោះ ប្រាថ្នាដល់ការប្រកបអាថ៌នទើបពោលថា ដាក់ខ្វះ ប្រាសចេញខ្វះ ដូច្នេះ ។ បានឮថា ពួកអាថ៌នប្រកបអាថ៌ន សម្ដែងសត្វឲ្យដូចដាច់សីសៈ ដាច់ដៃ និងដូចស្លាប់ហើយ ។ គេឃើញសត្វនោះជាប្រក្រតីទៀត ទើបឃើញដោយត្រង់ថា សត្វនេះចេញចាកនិរោធ ទើបពោលយ៉ាងនោះ ។

អ្នកទីបួនជំទាស់អ្នកទីបី ប្រាថ្នាដល់ការស្រវឹង និងការដេកលក់របស់នាងយក្ខទាសីទាំងឡាយ ទើបពោលពាក្យជាដើមថា ម្នាលអ្នកដ៏ចម្រើនក៏ទេវតាទាំងឡាយមាន ដូច្នេះ ។

បានឮថា ពួកនាងយក្ខទាសី ធ្វើការទំនុកបម្រុងទេវតារហូតដល់អស់នៃរាត្រី របាំ រាំ ច្រៀង ក្នុងថ្ងៃអរុណរះ ក៏ផឹកសុរា ស្រវឹងរមៀលទៅមក

ហើយភ្លាក់កណ្តាលថ្ងៃ ។ គេឃើញហេតុការណ៍នោះ ក៏មានឃើញដោយត្រង់ សម្គាល់ថា ក្នុងវេលាដេកលក់ប្រកបដោយនិរោធ ក្នុងវេលាភ្ញាក់ក៏ចេញពីនិរោធ ដូច្នេះ ទើបពោលយ៉ាងនោះ ។

ក៏ពោដ្ឋបាទបរិព្វាជកនេះ មានជាតិជាបណ្ឌិត ដោយហេតុនោះ គេមានសេចក្តីក្តៅក្រហាយ ព្រោះស្តាប់កថានេះ កថាទាំងនោះ ដូចជាពាក្យរបស់ពពែគ រមែងដល់និរោធបួននោះ និងធម្មតានិរោធនេះ គប្បីមានតែម្យ៉ាង មិនគប្បីមានច្រើន សូម្បីនិរោធនោះ គប្បីជាយ៉ាងដទៃតែម្យ៉ាងប៉ុណ្ណោះ ក៏គេដែលអ្នកដទៃមិនអាចនឹងឲ្យដឹងបាន ក្រៅពីព្រះសព្វញ្ញូ ទើបរលឹកដល់ព្រះទសពលប៉ុណ្ណោះថា បើព្រះដ៏មានព្រះភាគនឹងមានក្នុងទីនេះ ក៏នឹងធ្វើនិរោធឲ្យប្រាកដក្នុងថ្ងៃនេះតែម្តង ដូចដើមប្រទីបទាំងពាន់ដួង ឲ្យភ្លឺស្វាងរុងរឿងថា នេះនិរោធ នេះមិនមែននិរោធ ព្រោះដូច្នោះ ទើបទូលពាក្យជាដើមថា សតិរបស់ខ្ញុំព្រះអង្គនោះ ព្រះអង្គ ។

ក្នុងបទទាំងនោះ ពាក្យថា អហោ នូន ទាំងពីរជានិបាតចុះក្នុងអត្ថថារលឹកដល់ ។ ដោយហេតុនោះ គេកាលរលឹកដល់ព្រះដ៏មានព្រះភាគ ទើបមានសតិយ៉ាងនេះថា គួរជ្រះថ្លាពិតហ្ន៎ ព្រះដ៏មានព្រះភាគ គួរជ្រះថ្លាពិតហ្ន៎

ព្រះសុគត ក្នុងបទថា យោ នេមេសំ មានអធិប្បាយយ៉ាងនេះថា ព្រះដ៏មាន-ព្រះភាគអង្គណាទ្រង់ឈ្វាសរៀនវៃ គឺ ឈ្វាសដោយល្អ វាងវៃ ឆ្លៀវឆ្លាត ក្នុងនិរោធធម៌ទាំងនោះ ឱហ្ន៎ព្រះដ៏មានព្រះភាគអង្គនោះ គប្បីត្រាស់ ឱហ្ន៎ ព្រះសុគតព្រះអង្គនោះ គប្បីត្រាស់ បទថា បកតញ្ញូ សេចក្តីថា ព្រះដ៏មាន-ព្រះភាគជឿថា ទ្រង់ដឹងប្រក្រតី គឺ ព្រោះព្រះអង្គទ្រង់ឈ្វាសជាប់ជានិច្ច ព្រោះដូច្នោះ ព្រះអង្គទើបព្រះនាមថា **បកតញ្ញូ** ។ បរិព្វាជក កាលនឹងទូលសូមថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹង ព្រះអង្គទ្រង់ដឹង មេត្តាត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គចុះ ទើបពោលពាក្យនេះថា ក៏អភិសញ្ញានិរោធដូចម្តេចហ្ន៎ ? ព្រះអង្គ ។

# អហេតុកសញ្ញុប្បាទនិរោធ

[៨១-៨៧] កាលព្រះដ៏មានព្រះភាគទ្រង់សម្តែង ទើបត្រាស់ថា តត្រ ពោដ្ឋបាទ ជាដើម ។

ក្នុងបទទាំងនោះ បទថា តត្រ សេចក្តីថា ក្នុងសមណព្រាហ្មណ៍ទាំងនោះ ។

បទថា អាទិតោ វ តេសំ អបរទ្ធំ សេចក្តីថា ការឃើញរបស់សមណព្រាហ្មណ៍ទាំងនោះ ខុសតាំងពីដើមតែម្តង ។ លោកសម្តែងថា ខុសផ្ទាត់ត្រង់ទីកណ្តាលផ្ទះតែម្តង ។ ហេតុក្តី បច្ច័យក្តី ក្នុងបទនេះថា សហេតុ សប្បច្ចយា ជាឈ្មោះរបស់ហេតុការណ៍នោះឯង ។ សេចក្តីថា មានការណ៍ ។ ក៏កាលនឹងទ្រង់សម្តែងការណ៍នោះ ទើបត្រាស់ថា សិក្ខា ឯកា ។ ក្នុងបទទាំងនោះបទថា សិក្ខា ឯកា សញ្ញា ឧប្បជ្ជន្តិ សេចក្តីថា សញ្ញាខ្លះ រមែងកើតឡើងព្រោះសិក្សា ។ បទថា កា ច សិក្ខាតិ ភគវា អវោច សេចក្តីថា ក៏សិក្ខានោះយ៉ាងណា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់ដោយអំណាចការសួរ ព្រោះមានព្រះបំណងនឹងឲ្យសិក្ខានោះពិស្តារ ។

មួយទៀត ព្រោះសិក្ខាមានបីប្រការ គឺ អធិសីលសិក្ខា អធិចិត្ត-

សិក្ខា អធិប្បញ្ញាសិក្ខា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្តែងសិក្ខាទាំងនោះ ទើបទ្រង់ផ្តើមតន្តិធម៌ ចាប់ផ្តើមតាំងពីពេលឧប្បត្តិរបស់ព្រះពុទ្ធ ដើម្បីទ្រង់សម្តែងនិរោធកើតឡើង ដោយមានហេតុព្រោះសញ្ញា ទើបត្រាស់ថា ម្នាលបោដ្ឋបាទ ព្រះតថាគតឧប្បត្តិឡើងក្នុងលោកនេះជាដើម ។ បណ្តាសិក្ខាទាំងបីនោះ សិក្ខាពីរយ៉ាងនេះ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខាប៉ុណ្ណោះ មកដោយសង្ខេប ចំណែកសិក្ខាទីបី គប្បីជ្រាបថា មកហើយ ព្រោះជាសិក្ខាដែលជាប់ទាក់ទងដោយអំណាចនៃសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ក្នុងព្រះបាលីនេះថា ម្នាលបោដ្ឋបាទ ធម៌ដោយចំណែកតែមួយ ដែលតថាគតសម្តែងហើយថា នេះទុក្ខនិរោធគាមិនីបដិបទា ដូច្នេះឯង ។

បទថា កាមសញ្ញា បានដល់ រាគៈដែលលាយដោយកាមគុណប្រាំខ្លះ កាមរាគៈដែលកើតឡើងមិនស្មើខ្លះ ។ ក្នុងទាំងពីរយ៉ាងនោះ រាគៈដែលលាយដោយកាមគុណប្រាំ រមែងកម្ចាត់ដោយអនាគាមិមគ្គ ចំណែកកាមរាគៈដែលកើតឡើងមិនស្មើ រមែងប្រព្រឹត្តទៅក្នុងឋានៈនេះ ព្រោះដូច្នោះ បទថា តស្ស យា បុរិមា កាមសញ្ញា ទើបមានអត្ថថា សញ្ញាណា របស់ភិក្ខុនោះ អ្នកប្រកបព្រមដោយបឋមជ្ឈាន គប្បីហៅថា សញ្ញានោះរមែងរលត់ និងដែល

មិនទាន់កើត ក៏រមែងមិនកើត ។ បទថា វិវេកជបីតិសុខសុខុមសច្ចសញ្ញា តស្មិំ សមយេ ហោតិ សេចក្តីថា សញ្ញាដែលល្អិតល្អន់ ពោលគឺ មានបីតិ និងសុខដែលកើតពីវិវេក ក្នុងសម័យបឋមជ្ឈាននោះជាសច្ចៈ គឺ មានពិត ។ ម្យ៉ាងទៀត សញ្ញានោះ ដែលល្អិតល្អន់ដោយអំណាចលះបង់អង្គដែលគ្រោតគ្រាត មានកាមឆន្ទៈជាដើម និងឈ្មោះថា ជាសច្ចៈ ព្រោះជារបស់មានពិត ព្រោះដូច្នោះ សញ្ញានោះ ទើបជាសញ្ញាក្នុងសច្ចៈដែលល្អិតល្អន់ សញ្ញាក្នុងសច្ចៈដែលល្អិតល្អន់ដែលសម្បយុត្តដោយបីតិ និងសុខដែលកើតពីវិវេក ព្រោះដូច្នោះ ទើបឈ្មោះថា វិវេកបីតិសុខសុខុមសច្ចសញ្ញា សញ្ញានោះរបស់ភិក្ខុមានហើយ ព្រោះដូច្នោះ ភិក្ខុនោះ ទើបឈ្មោះថា មានសញ្ញាក្នុងសច្ចៈដែលល្អិតល្អន់ មានបីតិ និងសុខដែលកើតពីវិវេក គប្បីឃើញអត្ថក្នុងបទនោះត្រឹមតែប៉ុណ្ណេះ ។

ក្នុងបទទាំងពួងក៏មានន័យដូច្នោះ ។

ក្នុងបទថា ឯវំ បិ សិក្ខា នោះ សេចក្តីថា ព្រោះភិក្ខុចូលដល់ និងអធិដ្ឋានបឋមជ្ឈានសិក្សា ព្រោះដូច្នោះ បឋមជ្ឈាននោះហៅថា សិក្ខា ព្រោះជាកិច្ចដែលគួរសិក្សាយ៉ាងនេះ សញ្ញាក្នុងសច្ចៈដែលល្អិតល្អន់ មានបីតិ និង

សុខដែលកើតពីវិវេកខ្វះ រមែងកើតឡើងយ៉ាងនេះ ដោយបឋមជ្ឈាន ពោលគឺ សិក្ខាសូម្បីនោះ កាមសញ្ញាខ្វះ រមែងរលត់យ៉ាងនេះ ។ បទថា អយំ សិក្ខាតិ ភគវា អវោច សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់ថា នេះក៏ជា សិក្ខាមួយ៉ាង គឺ បឋមជ្ឈាន ។ គប្បីឃើញសេចក្តីក្នុងទាំងពួង ដោយទំនង នោះ ។

[៨៨] ក៏ព្រោះការពិចារណាដោយអង្គនៃសមាបត្តិទី ៨ រមែងមាន ដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ រមែងមិនមានដល់សាវកទាំងឡាយ សូម្បី ព្រះសារីបុត្រ តែការពិចារណាដោយរួមក្រុមប៉ុណ្ណោះ រមែងមានដល់សាវក ទាំងឡាយ និងការពិចារណាដោយអង្គយ៉ាងនេះថា សញ្ញា សញ្ញា នេះបាន លើកឡើងហើយ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា ម្នាលពោដ្ឋបាទ ភិក្ខុ ។ល។ ដល់នូវសញ្ញាជាកំពូល ដូច្នេះ ដើម្បីទ្រង់សម្តែងអាកិញ្ចញ្ញាយ-តនសញ្ញាដ៏កំពូល ហើយសម្តែងសញ្ញានោះទៀតថា កំពូលសញ្ញា ។

ក្នុងបទទាំងនោះ បទថា យតោ ខោ ពោដ្ឋបាទ ភិក្ខុ សេចក្តីថា ម្នាលពោដ្ឋបាទ ភិក្ខុឈ្មោះណា ។ បទថា ឥធ សកសញ្ញី ហោតិ សេចក្តីថា ភិក្ខុក្នុងសាសនានេះ មានសកសញ្ញា ។ មួយទៀត បាលីក៏ជាយ៉ាងនេះ

សេចក្ដីថា ភិក្ខុមានសញ្ញាដោយសញ្ញា ក្នុងបឋមជ្ឈានរបស់ខ្លួន ។ បទថា សោ តតោ អមុត្រ តតោ អមុត្រ សេចក្ដីថា ភិក្ខុនោះ មានសកសញ្ញាដោយឈានសញ្ញានោះៗ យ៉ាងនេះគឺ ចេញចាកបឋមជ្ឈាននោះហើយ មានសញ្ញាក្នុងទុតិយជ្ឈានឯណោះ ចេញចាកទុតិយជ្ឈាននោះហើយ មានសញ្ញាក្នុងតតិយជ្ឈានឯណោះ ដោយលំដាប់ទៅដល់កំពូលសញ្ញា ។ អាកិញ្ចញ្ញាយតនៈ ហៅថា **សញ្ញគ្គ** កំពូលសញ្ញា ។ ព្រោះហេតុណា ។ ព្រោះជាអង្គទីបំផុតនៃសមាបត្តិ ដែលមាននាទីធ្វើកិច្ចជាលោកិយ៍ ។ ក៏ភិក្ខុតាំងនៅក្នុងអាកិញ្ចញ្ញាយតនសមាបត្តិហើយ រមែងចូលដល់សញ្ញានាសញ្ញាយតនសមាបត្តិខ្លះ និរោធសមាបត្តិខ្លះ ។ អាកិញ្ចញ្ញាយតនសញ្ញានោះ ហៅថា កំពូលសញ្ញា ព្រោះជាអង្គក្នុងទីបំផុតនៃសមាបត្តិ ដែលមាននាទីធ្វើកិច្ចជាលោកិយ៍ ដោយប្រការដូច្នេះ ។ សេចក្ដីថា ភិក្ខុដល់ គឺ សម្រេចកំពូលសញ្ញានោះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្ដែងអភិសញ្ញានិរោធ ទើបត្រាស់ថា កាលបើភិក្ខុនោះ ឋិតនៅក្នុងសញ្ញាជាកំពូលជាដើម ។ ក្នុងបទទាំងនោះ សេចក្ដីថា ភិក្ខុចូលដល់ឈាន ក្នុងពីរបទថា **យើងគប្បីបំណង យើងគប្បីសម្លឹង** ឈ្មោះថា

រមែងគិត គឺ ឲ្យសម្រេចរឿយៗ ។ ភិក្ខុធ្វើសេចក្តីប្រាថ្នាដើម្បីប្រយោជន៍ដល់សមាបត្តិជាន់ខ្ពស់ឡើងទៅ ឈ្មោះថា **គប្បីសង្ឃឹម** ។ បទថា ឥមា ច មេ សញ្ញា និរុជ្ឈេយ្យុំ សេចក្តីថា អាកិញ្ចញ្ញាយតនសញ្ញានេះ គប្បីរលត់ ។

បទថា អញ្ញា ច ឱឡារិកា សេចក្តីថា និងភវង្គសញ្ញាដែលគ្រោតគ្រាតយ៉ាងដទៃគប្បីកើតឡើង ។ ក្នុងបទនេះថា **អ្នកទើបមិនបំណងផង ទាំងមិនសង្ឃឹមផង** ភិក្ខុនោះកាលបំណង ឈ្មោះថា មិនមានបំណង កាលសង្ឃឹម ឈ្មោះថា មិនសង្ឃឹមមែនពិត ការពិចារណាដោយធ្វើទុកក្នុងចិត្តថា យើងចេញចាកអាកិញ្ចញ្ញាយតនៈហើយ ចូលដល់នេវសញ្ញានាសញ្ញាយតនៈ តាំងនៅក្នុងវារៈចិត្តមួយ ឬពីរ រមែងមិនមានដល់ភិក្ខុនេះ តែរមែងមានដើម្បីប្រយោជន៍ដល់និរោធសមាបត្តិជាន់ខ្ពស់ប៉ុណ្ណោះ ។ សេចក្តីនេះ គប្បីសម្តែងដោយការសម្លឹងមើលផ្ទះរបស់បុត្រ ។

បានឮថា ព្រះថេរៈសួរភិក្ខុដែលទៅដល់កណ្តាលផ្ទះរបស់បិតា ហើយនាំយកភោជនដ៏ប្រណីតពីផ្ទះរបស់បុត្រក្នុងខាងក្រោយ មកកាន់អាសនសាលាថា បិណ្ឌបាតដែលគួរពេញចិត្ត ដែលលោកនាំមកពីទីណា ។ លោកទើបប្រាប់ផ្ទះដែលបានភោជនថា មកអំពីផ្ទះអ្នកឯណោះ ។ ក៏លោកទៅ ហើយក្តី

មកហើយក្តី ដល់កណ្តាលផ្ទះបិតាណា សូម្បីការចងចិត្តរបស់លោកត្រង់កណ្តាលផ្ទះនោះ រមែងមិនមាន ។ ក្នុងរឿងនោះ គប្បីឃើញអាកិញ្ចញ្ញាយតនសមាបត្តិ ដូចជាអាសនសាលា ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិដូចជាផ្ទះរបស់បិតា និរោធសមាបត្តិដូចផ្ទះរបស់បុត្រ ការមិនពិចារណាដោយឧបាយនៃប្រាជ្ញាថា ឃើងចេញចាកអាកិញ្ចញ្ញាយតនៈហើយ ចូលដល់នេវសញ្ញានាសញ្ញាយតន ទឹងតាំងនៅក្នុងវារៈចិត្តមួយ-ពីរ ហើយមនសិការដើម្បីប្រយោជន៍ដល់និរោធសមាបត្តិជាន់ខ្ពស់ប៉ុណ្ណោះ ប្រៀបដូចការឈរក្នុងអាសនសាលា មិនផ្ចង់ចិត្តដល់ផ្ទះរបស់បិតា ហើយប្រាប់ផ្ទះរបស់បុត្រដូច្នោះ ។ ភិក្ខុនោះ កាលបំណង ក៏ឈ្មោះថា រមែងមិនបំណង កាលសង្ខឹម ក៏ឈ្មោះថា រមែងមិនសង្ខឹម ដោយប្រការដូច្នេះ ។

បទថា តា ចេវ សញ្ញា សេចក្តីថា ឈានសញ្ញានោះ រមែងរលត់ ។ បទថា អញ្ញា ច សេចក្តីថា ទាំងករង្គសញ្ញាយ៉ាងគ្រោតគ្រាតដទៃ រមែងមិនកើតឡើង ។ បទថា សោ និរោធំ ផុសតិ សេចក្តីថា ភិក្ខុនោះបដិបត្តិយ៉ាងនេះ រមែងដល់ គឺ រមែងបាន រមែងបានទទួលសញ្ញាវេទយិតនិរោធ ។ ពាក្យថា អភិ ក្នុងបទថា អនុបុព្វាភិសញ្ញានិរោធសម្បជានសមាបត្តិ នោះ

ត្រឹមតែឧបសគ្គ ។ បទថា សម្បជាន បានពោលទុកក្នុងចន្លោះនិរោធបទ ។ ក៏ក្នុងបទថា សម្បជានសញ្ញានិរោធសមាបត្តិ នោះ មានសេចក្ដីតាមលំដាប់ ដូច្នេះ ។ សូម្បីក្នុងបទនោះ បទថា សម្បជានសញ្ញានិរោធសមាបត្តិ មាន អត្ថពិសេសយ៉ាងនេះថា សញ្ញានិរោធសមាបត្តិក្នុងទីបំផុត រមែងមានដល់ ភិក្ខុដែលដឹងខ្លួន ឬដល់ភិក្ខុអ្នកជាបណ្ឌិតដែលដឹងខ្លួន ។ ឥឡូវនេះ អ្នក ដែលនៅក្នុងទីនេះ គប្បីសម្ដែងនិរោធសមាបត្តិកថា ។ ក៏និរោធសមាបត្តិ- កថានេះ បានសម្ដែងទុកហើយ ក្នុងប្រការពោលអំពីអានិសង្សនៃការចម្រើន បញ្ញា ក្នុងវិសុទ្ធិមគ្គដោយអាការទាំងពួង ។ ព្រោះដូច្នោះ គប្បីកាន់យកពី ទីដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះចុះ ។

ព្រះដ៏មានព្រះភាគ ត្រាស់និរោធកថា ដល់ពោដ្ឋបាទបរិព្វាជកយ៉ាង នេះហើយ តមក ដើម្បីឲ្យពោដ្ឋបាទបរិព្វាជកនោះ ទទួលដឹងដល់កថានោះ មិនមានក្នុងទីដទៃ ទើបត្រាស់ថា អ្នកសម្គាល់ហេតុនោះដូចម្ដេច ជាដើម ។ ចំណែកបរិព្វាជក កាលនឹងទូលសេចក្ដីដឹងថា បពិត្រ ព្រះដ៏មានព្រះភាគ ក្នុងថ្ងៃនេះ ក្រៅពីកថារបស់ព្រះអង្គហើយ ខ្ញុំព្រះអង្គ មិនធ្លាប់បានស្ដាប់ កថាបែបនេះឡើយ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីនេះ ខ្ញុំ

ព្រះអង្គមិនធ្លាប់បានឮទេ កាលនឹងសម្ដែងដល់សេចក្ដីនៃកថារបស់ព្រះមាន-ព្រះភាគ ដែលខ្លួនបានរៀនដោយគោរពទៀត ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទើបតែនឹងដឹងនូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងដោយអាការយ៉ាងនេះឯង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់អនុញ្ញាតដល់បរិព្វាជកនោះថា អ្នកចូរទទួលទុកដោយល្អចុះ ទើបត្រាស់ថា ម្នាលបោដ្ឋបាទ យ៉ាងនេះ ។

[៨៩] គ្រានោះ បរិព្វាជកគិតថា អាកិញ្ចញ្ញាយតនៈដែលព្រះដ៏-មានព្រះភាគត្រាស់ថា កំពូលសញ្ញា អាកិញ្ចញ្ញាយតនៈប៉ុណ្ណោះហ្ន៎ ជាកំពូលសញ្ញា ឬថា នៅមានកំពូលសញ្ញាសូម្បីក្នុងសមាបត្តិដ៏សេសទៀត កាលនឹងទូលសួរអត្ថនោះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បញ្ញត្តិនូវសញ្ញាដ៏កំពូលតែម្យ៉ាងប៉ុណ្ណោះទេ ឬបញ្ញត្តិនូវសញ្ញាដ៏កំពូលដ៏សេសទៀត ។ ចំណែកព្រះដ៏មានព្រះភាគ ទ្រង់ដោះស្រាយពាក្យសួររបស់បរិព្វាជកនោះហើយ ។ បណ្ដាបទទាំងនោះ បទថា បុថូបិ បានដល់ ច្រើនក៏មាន ។ បទថា យថា យថា ខោ ផោដ្ឋបាទ និរោធំ ផុសតិ សេចក្ដីថា ដោយកសិណណាៗ ក្នុងបណ្ដាកសិណទាំងឡាយ មានបឋវីកសិណជាដើម

ឬដោយឈានណាៗ បណ្តាឈានទាំងឡាយ មានបឋមជ្ឈានជាដើម ។ លោកពោលយ៉ាងនេះថា ក៏បើភិក្ខុចូលដល់បឋវីកសិណសមាបត្តិ ដោយបឋវីកសិណជាហេតុត្រឹមតែមួយដង រមែងដល់សញ្ញានិរោធ មុនកំពូលសញ្ញាក៏មាន បើចូលដល់ពីរដង បីដង រយដង ពាន់ដង ឬសែនដង ក៏រមែងដល់សញ្ញា-និរោធដែលមុន កំពូលសញ្ញាក៏មានដល់សែន ។ ក្នុងកសិណដ៏សេសទាំងឡាយក៏មានន័យដូចគ្នា ។ សូម្បីក្នុងឈានទាំងឡាយ ក៏ចូលដល់សញ្ញានិរោធមុនដោយបឋមជ្ឈានជាហេតុត្រឹមតែតែមួយដង កំពូលសញ្ញា ក៏មានតែមួយដង បើចូលដល់សញ្ញានិរោធមុនពីរដង បីដង រយដង ពាន់ដង ឬសែនដង កំពូលសញ្ញាក៏នឹងមានដល់សែនដង ។ ក្នុងឈានសមាបត្តិដ៏សេសទាំងឡាយក៏ន័យនេះ ។ កំពូលសញ្ញា រមែងមានមួយដង ដោយអំណាចការចូលដល់ត្រឹមតែមួយដង ឬព្រោះសង្គ្រោះវារៈសូម្បីទាំងពួង ដោយលក្ខណៈនៃការដឹង ។ កំពូលសញ្ញា រមែងមានច្រើន ដោយអំណាចការចូលដល់រឿយៗ ។

**[៩០]** បទថា សញ្ញា នុ ខោ ភន្តេ សេចក្តីថា បរិព្វាជកទូលសួរថា សញ្ញារបស់ភិក្ខុដែលចូលដល់និរោធ រមែងកើតឡើងមុន ឬព្រះអង្គ ។ ព្រះ-មានព្រះភាគ ទ្រង់ព្យាករណ៍ដល់បរិព្វាជកនោះថា សញ្ញានោះឯងកើតមុន

បោដ្ឋបាទៈ ។ បណ្តាបទទាំងនោះ បទថា សញ្ញា បានដល់ ឈានសញ្ញា ។ បទថា ញាណំ បានដល់ វិបស្សនាញាណ ។ ន័យមួយទៀត បទថា សញ្ញា បានដល់ វិបស្សនា ។ បទថា ញាណំ បានដល់ មគ្គសញ្ញា ។ ន័យមួយទៀត បទថា សញ្ញា បានដល់ មគ្គសញ្ញា ។ បទថា ញាណំ បានដល់ ផលញ្ញាណ ។ ក៏ព្រះមហាសិវត្ថេរៈ ដែលទ្រទ្រង់ត្រៃបិដកពោលថា ភិក្ខុទាំងនេះនិយាយអ្វី បោដ្ឋបាទ បានទូលសួរនិរោធចំពោះព្រះដ៏មានព្រះភាគមកហើយ ឥឡូវនេះ កាលនឹងទូលសួរដល់ការចេញចាកនិរោធ ទើបទូលថា បពិត្រព្រះដ៏មាន-ព្រះភាគ កាលភិក្ខុចេញចាកនិរោធ អរហត្តផលសញ្ញាកើតមុន ឬថា បច្ច-វេក្ខណញ្ញាណកើតមុន លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ដល់បរិព្វាជកនោះថា ផលសញ្ញាកើតមុន បច្ចវេក្ខណញ្ញាណកើតពេលក្រោយ ព្រោះដូច្នោះ សញ្ញានោះឯងកើតមុន បោដ្ឋបាទ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា សញ្ញុប្បាទា សេចក្តីថា ការកើតឡើងនៃបច្ចវេក្ខណញ្ញាណ រមែងមានយ៉ាងនេះថា ព្រោះអរហត្តផលសញ្ញាកើតឡើង អរហត្តផលនេះ ទើបកើតពេលក្រោយ ។

បទថា ឥទប្បច្ចយា កិរ មេ សេចក្តីថា ន័យថា បច្ចវេក្ខណញ្ញាណ

បានកើតឡើងហើយដល់យើង ព្រោះផលសមាធិសញ្ញាជាបច្ច័យ ។

## សញ្ញាអត្ត

[៩១] ឥឡូវនេះ ជ្រូកស្រុកត្រូវឲ្យងូតទឹកក្រអូប លាបស្រឡាប ដោយគ្រឿងក្រអូប ប្រដាប់ដោយកម្រងមាលា សូម្បីលើកឲ្យដេកលើទីដេក ដែលជាសិរី ក៏មិនបានសេចក្ដីសុខ រមែងស្ទុះទៅកាន់ទីស្មោកគ្រោកដោយ រហ័ស នឹងបានសេចក្ដីសុខអំពីណា បរិព្វាជកក៏យ៉ាងនោះដែរ ត្រូវព្រះមាន-ព្រះភាគឲ្យងូត លាបស្រឡាប ប្រដាប់ដោយទេសនាដែលប្រកបដោយត្រៃ-លក្ខណ៍ដ៏ល្អិតល្អន់សុខុមខ្ទះ លើកឡើងកាន់ទីដេកដែលជាសិរី គឺ និរោធកថា កាលមិនបានសេចក្ដីសុខក្នុងនិរោធកថានោះ កាន់យកលទ្ធិរបស់ខ្លួនដូចគ្នា នឹងទីស្មោកគ្រោក កាលនឹងទូលអត្ថនោះឯង ទើបទូលថា បពិត្រព្រះអង្គ ដ៏ចម្រើន **សញ្ញា** ឈ្មោះថា **ខ្លួន** របស់បុរសដូច្នេះជាដើម លំដាប់នោះព្រះ មានព្រះភាគ ទ្រង់កាន់មតិបន្តិចបន្តួចរបស់បរិព្វាជកនោះ មានព្រះបំណងនឹង ព្យាករណ៍ ទើបត្រាស់ថា អ្នកជឿថា ខ្លួនដូចម្ដេច ជាដើម ។

ដោយបរិព្វាជកនោះ ជាអ្នកមានលទ្ធិយ៉ាងនេះថា ខ្លួនមិនមានរូប ទើបគិតថា ព្រះដ៏មានព្រះភាគ ទ្រង់ឈ្លាសល្អក្នុងការសម្ដែង ព្រះអង្គគង់មិន

កម្មាត់លទ្ធិរបស់យើងតាំងអំពីខាងដើម កាលនឹងនាំលទ្ធិរបស់ខ្លួន ទើបទូល ថា ដែលគ្រោតគ្រាតជាដើម ។ លុះព្រះដ៏មានព្រះភាគ ទ្រង់សម្តែងទោស ក្នុងលទ្ធិនោះ ដល់បរិព្វាជកនោះ ទើបត្រាស់ពាក្យជាដើមថា ក៏ខ្លួនរបស់អ្នក គ្រោតគ្រាត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ឯវំ សន្តំ សេចក្តីថា កាលបើហេតុយ៉ាង នេះមាន ។

ពិតហើយ ពាក្យនោះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ម្យ៉ាងទៀត ក្នុងបទនេះថា កាលបើដូច្នោះ កាលអ្នកប្រាថ្នាខ្លួន មានអត្ថ ដូច្នេះ ។ លោកពោលថា ក៏ព្រោះខន្ធទី ៤ កើតព្រមគ្នា រលត់ព្រមគ្នា សញ្ញាណាកើត សញ្ញានោះរលត់ ក៏ព្រោះអាស្រ័យគ្នានិងគ្នា សញ្ញាដទៃ កើត និងសញ្ញាដទៃរលត់ ។

**[៩២]** ឥឡូវនេះ បរិព្វាជកកាលនឹងសម្តែងលទ្ធិដទៃ ទើបពោល ពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នា ខ្លួនដែលសម្រេចដោយ ចិត្ត ដូច្នេះជាដើម ។

**[៩៣]** សូម្បីក្នុងលទ្ធិនោះ ឲ្យទោសហើយ កាន់លទ្ធិដទៃ លះលទ្ធិ

ដទៃ កាលនឹងពោលលទ្ធិរបស់ខ្លួនក្នុងកាលឥឡូវនេះ ទើបទូលថា ខ្លួនមិនមានរូបដោយពិតដូច្នេះជាដើម ដូចមនុស្សឆ្កួតកាន់សញ្ញាដទៃ លះបង់សញ្ញាដទៃ ដរាបដល់សញ្ញារបស់គេមិនតាំងមាំ តែនឹងពោលពាក្យដែលគួរពោលក្នុងកាលដែលមានសញ្ញាតាំងមាំ ។ ក្នុងលទ្ធិសូម្បីនោះ ព្រោះគេប្រាថ្នាការកើត និងការរលត់នៃសញ្ញា តែសម្គាល់ខ្លួនថា ទៀង ព្រោះដូច្នោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងទោសដល់បរិព្វាជកយ៉ាងនោះ ទើបត្រាស់ថា **កាលបើមានយ៉ាងនោះ** ជាដើម ។

[៩៤] លំដាប់នោះបរិព្វាជកមិនដឹងខ្លួនផ្សេងៗ នោះ សូម្បីព្រះដ៏មានព្រះភាគត្រាស់ ព្រោះខ្លួនត្រូវសេចក្តីឃើញខុសគ្របសង្កត់ ទើបទូលថា **ខ្ញុំព្រះអង្គអាចជ្រាបបាន ឬមិនបាន សញ្ញាជាខ្លួនរបស់បុរសដូច្នេះខ្លះ សញ្ញាក៏ដទៃ ខ្លួនក៏ដទៃ ដូច្នេះខ្លះ** ដូច្នេះជាដើម ។

លំដាប់នោះ ព្រោះបរិព្វាជកនោះ សូម្បីឃើញការកើត និងការរលត់នៃសញ្ញា ទើបសម្គាល់ខ្លួន ដែលសម្រេចដោយសញ្ញាជារបស់ទៀងតែម្យ៉ាង ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគត្រាស់ពាក្យថា **ដឹងបានលំបាក** ជាដើម ដល់បរិព្វាជកនោះ ។

ក្នុងបទនោះ សេចក្តីដោយសង្ខេបដូច្នេះ លោកមានទិដ្ឋិជាយ៉ាងដទៃ មានខន្តិជាយ៉ាងដទៃ មានសេចក្តីពេញចិត្តជាយ៉ាងដទៃ មានទស្សនៈប្រព្រឹត្តទៅដោយប្រការដទៃ និងទស្សនៈយ៉ាងដទៃ គួរដល់លោក និងពេញចិត្តដល់លោក មានសេចក្តីព្យាយាមក្នុងលទ្ធិដទៃ មានអាចារ្យក្នុងលទ្ធិដទៃ ព្រោះការដែលប្រកបសេចក្តីខ្វល់ខ្វាយបដិបត្តិយ៉ាងដទៃ គឺ ភាពជាអាចារ្យក្នុងលទ្ធិតិរ្ថិយយ៉ាងដទៃ ដោយហេតុនោះ ប្រការដែលថា **សញ្ញាជាខ្លួនរបស់បុរស ឬសញ្ញាក៏ដទៃ ខ្លួនក៏ដទៃ ដូច្នេះខ្លះ** ដូច្នោះនោះ ព្រោះលោកអ្នកមានទិដ្ឋិយ៉ាងដទៃ មានខន្តិជាយ៉ាងដទៃ មានសេចក្តីពេញចិត្តយ៉ាងដទៃ មានសេចក្តីព្យាយាមក្នុងលទ្ធិដទៃ មានអាចារ្យក្នុងលទ្ធិដទៃ ដឹងបានយ៉ាងលំបាក ។

លំដាប់នោះ បរិព្វាជកគិតថា សញ្ញាជាខ្លួនរបស់បុរស ឬថា សញ្ញាជាយ៉ាងដទៃ យើងនឹងទូលសួរដល់ន័យដែលថាខ្លួននោះ ជារបស់ទៀងជាដើមនោះ ទើបទូលទៀតថា គឺ បន ភន្តេ ជាដើម ។ បណ្តាបទទាំងនោះ បទថា លោកោ សេចក្តីថា បរិព្វាជកពោលសំដៅដល់ខ្លួន ។ បទថា ន ហេតំ ពោដ្ឋបាទ អត្ថសញ្ញហិតំ សេចក្តីថា ម្នាលពោដ្ឋបាទ ក្នុងលោកនេះ ឬក្នុងលោកដទៃ មិនប្រកបដោយប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ។

បទថា ន ធម្មសញ្ញិតំ សេចក្តីថា មិនប្រកបដោយលោកុត្តរធម៌ ៩ ។ បទថា ន អាទិព្រហ្មចរិយកំ សេចក្តីថា មិនជាខាងដើមនៃព្រហ្មចរិយៈក្នុងសាសនា ពោលគឺ ត្រៃសិក្ខា ទាំងមិនជាអធិសីលសិក្ខាផង បទថា ន និព្វិទាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍នៃសេចក្តីនឿយណាយក្នុងសង្សារ-វដ្ត ។ បទថា ន វិរាគាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍នៃការប្រាសចាកវដ្ត ។ បទថា ន និរោធាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍នៃការរលត់វដ្តៈ ។ បទថា ន ឧបសមាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងការស្ងប់រម្ងាប់វដ្តៈ ។ បទថា ន អភិញ្ញាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់នូវវដ្តៈ គឺ ដើម្បីធ្វើឲ្យប្រចក្ស ។

បទថា ន សម្ពោធាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការដឹងប្រពៃនូវវដ្តៈ ។

បទថា ន និព្វានាយ សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីធ្វើឲ្យប្រចក្សនូវអមតមហានិព្វាន ។

**[៩៥]** ក្នុងបទថា **នេះទុក្ខ** ជាដើម មានអត្ថថា ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិបីវៀរតណ្ហា តថាគតព្យាករណ៍ថា **ទុក្ខ** , តណ្ហា ដែលមានខន្ធ ៥

នោះជាបច្ច័យ ព្រោះជាអណ្តូងកើតនៃទុក្ខនោះ តថាគតព្យាករណ៍ថា **ទុក្ខ-សមុទ័យ** , ការមិនប្រព្រឹត្តទៅនៃខន្ធ និងតណ្ហាទាំងពីរនោះ តថាគតព្យាករណ៍ថា **ទុក្ខនិរោធ** , មគ្គមានអង្គ ៨ ដ៏ប្រសើរ តថាគតព្យាករណ៍ថា **ទុក្ខនិរោធគាមិនីបដិបទា** ។ ព្រះដ៏មានព្រះភាគ លុះត្រាស់ដូច្នេះហើយ ទ្រង់ត្រិះរិះថា ឈ្មោះថា ការប្រោកដនៃមគ្គ ឬការធ្វើឲ្យច្បាស់នូវផល មិនមានដល់បរិព្វាជកនេះ ហើយក៏ជាវេលាកិច្ចាចាររបស់តថាគតដល់ហើយ ទើបទ្រង់នៅស្ងៀម ។ ចំណែកបរិព្វាជកដឹងព្រះអាការនោះ ដូចជាការប្រាប់ដល់វេលាស្តេចត្រូវយាងរបស់ព្រះដ៏មានព្រះភាគ ទើបទូលថា ឯវមេតំ ជាដើម ។

**[៩៦]** បទថា វាចាយ សន្និបតោទកេន សេចក្តីថា ជន្ទួញ គឺ ពាក្យ ។ បទថា សញ្ឆម្ភរិមកំសុ សេចក្តីថា បានធ្វើការចាក់ដោតបោដ្ឋបាទបរិព្វាជកដោយជុំវិញ គឺ ប៉ះខ្ទប់ជាប់ជានិច្ច ។ លោកពោលថា ចាក់ដោតខាងលើ ។

**[៩៧]** បទថា ភូតំ សេចក្តីថា មានហើយដោយសភាវៈ ។ បទថា តច្ឆំ តថំ ជាវេវចនៈរបស់បទនោះឯង ។ បទថា ធម្មដ្ឋិតតំ សេចក្តីថា សភាពតាំងនៅក្នុងលោកុត្តរធម៌ ៩ ។

បទថា ធម្មនិយាមតំ សេចក្តីថា ត្រឹមត្រូវតាមគន្លងនៃលោកុត្តរធម៌ ។

ពិតមែន ដែលឈ្មោះថា ការនិយាយដែលរួចផុតចាកសច្ចៈទាំង បួន រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ការនិយាយទើបមានដូច្នេះ ។

# រឿងចិត្តហត្ថិសារីបុត្ត

[៩៨] *បទថា ចិត្តោ ច ហត្ថិសារិបុត្តោ សេចក្ដីថា បានឮថា ចិត្តហត្ថិសារីបុត្រនោះ ជាបុត្ររបស់ទេមាក់ដំរីក្នុងក្រុងសាវត្ថី បួសក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ រៀនសូត្រព្រះត្រៃបិដក ជាអ្នកឆ្លាតក្នុងចន្លោះនៃអត្ថទាំងឡាយដ៏ល្អិតល្អន់ ។ តែបួសហើយសឹកជាគ្រហស្ថដល់ ៧ ដង ដោយអំណាចនៃបាបកម្មដែលធ្លាប់ធ្វើទុកក្នុងកាលមុន ។*

*បានឮថា ក្នុងព្រះសាសនារបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមថាកស្សបៈ មានសម្លាញ់ពីរនាក់ ព្រមព្រៀងគ្នាស្វាធ្យាយរួមគ្នា ។ ក្នុងសម្លាញ់ទាំងពីរនោះ សម្លាញ់ម្នាក់មិនមានសេចក្ដីត្រេកអរ ញុំាងចិត្តឲ្យកើតឡើងក្នុងភាពជាគ្រហស្ថ ទើបពោលដល់សម្លាញ់ម្នាក់ទៀត ។ សម្លាញ់ម្នាក់នោះ សម្ដែងទោសក្នុងភាពជាគ្រហស្ថ និងអានិសង្សនៃបព្វជ្ជា ក៏ប្រៀនប្រដៅលោក ។ សម្លាញ់ម្នាក់ជំបូងនោះ ស្ដាប់សម្លាញ់ម្នាក់នោះហើយ ក៏មានចិត្តត្រេកអរក្នុងថ្ងៃមួយ គ្រាចិត្តដូច្នោះកើតឡើងហើយ ទើបប្រាប់ចំពោះសម្លាញ់ថា លោកដ៏មានអាយុ ចិត្តបែបនោះកើតឡើងដល់ខ្ញុំ ខ្ញុំនឹងឲ្យបាត្រ និងចីវរ*

នេះ ដល់លោក ។ សម្លាញ់ម្នាក់នោះ ព្រោះមានសេចក្តីលោភក្នុងបាត្រ និងចីវរ ទើបសម្តែងអានិសង្សក្នុងភាពជាគ្រហស្ថ សម្តែងទោសនៃបព្វជ្ជាវិញ ។ គ្រានោះ ព្រោះការស្តាប់សម្លាញ់ហើយ ក៏ជាគ្រហស្ថ ចិត្តក៏ទៀយណាយក្នុងបព្វជ្ជា ។ លោកនោះ បានសឹកដល់ ៦ ដង ក្នុងកាលឥឡូវនេះ ព្រោះលោកសម្តែងអានិសង្សក្នុងភាពជាគ្រហស្ថដល់ភិក្ខុអ្នកមានសីល ក្នុងកាលនោះ ក៏បួសក្នុងលើកទី ៧ បានជំទាស់ឡើង ក្នុងចន្លោះដែលព្រះមហាមោគ្គល្លាន និងព្រះមហាកោដ្ឋិតត្ថេរៈ ពោលអភិធម្មកថា ។ លំដាប់នោះ ព្រះមហាកោដ្ឋិតត្ថេរៈ ទើបបានតិះដៀលលោក ។ លោកកាលមិនអាចតាំងនៅក្នុងវាទៈដែលមហាសាវកពោលបាន ទើបបានសឹកជាយាវាស ។ ក៏លោកនេះ ជាសម្លាញ់កាលនៅគ្រហស្ថ របស់បោដ្ឋបាទបរិព្វាជក ព្រោះដូច្នោះ ទើបសឹកទៅកាន់សម្នាក់របស់បោដ្ឋបាទបរិព្វាជក ដោយកន្លងទៅពីរ-បីថ្ងៃ ។

តមកបោដ្ឋបាទនោះឃើញគេហើយ ទើបនិយាយថា នែ៎សម្លាញ់ លោកមានរឿងអ្វី ទើបចេញចាកសាសនារបស់ព្រះសាស្តាបែបនេះ ចូរមកលោកសមគួរបួសក្នុងកាលឥឡូវនេះ ហើយក៏នាំគេទៅកាន់សម្នាក់របស់ព្រះមាន-ព្រះភាគ ។ ដោយហេតុនេះ លោកទើបពោលថា ចិត្តហត្ថិសារីបុត្រ និង

បោដ្ឋបាទបរិព្វាជក ដូច្នេះ ។

**[៩៩-១០០]** បទថា អន្ធា សេចក្ដីថា ព្រោះចក្ខុ គឺ បញ្ញាមិនមាន ។ ឈ្មោះថា មិនមានចក្ខុ ព្រោះមិនមានចក្ខុ គឺ បញ្ញានោះ ។

បទថា ត្វមេវ នេសំ ឯកោ ចក្ខុមា សេចក្ដីថា មានចក្ខុ គឺ បញ្ញា ត្រឹមតែដឹងសុភាសិត និងទុព្ភាសិត ។ បទថា ឯកំសិកា សេចក្ដីថា ចំណែកមួយ ។ បទថា បញ្ញត្តា សេចក្ដីថា បញ្ញត្តិហើយ ។ បទថា អនេកំសិកា សេចក្ដីថា មិនមែនចំណែកតែមួយ អធិប្បាយថា មិនបានត្រាស់ថា ទៀង ឬថាមិនទៀង ដោយចំណែកតែមួយ ។

## ឯកាំសិកាជម្ម

[១០១] ព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធពាក្យថា សន្តិ ចោដ្ឋចាន នេះ ព្រោះហេតុណា ។ ដើម្បីទ្រង់សម្តែងដល់បញ្ញត្តិទីបំផុត ដែលពួកពាហិរៈទាំងឡាយបញ្ញត្តិទុក មិនមែនជាគ្រឿងចេញចាកទុក្ខបាន ។ តិរ្ថិយសូម្បីទាំងពួង រមែងបញ្ញត្តិទីបំផុតដោយអំណាចថា លោកមានទីបំផុតជាដើម ក្នុងលទ្ធិរៀងៗ ខ្លួន ដូចព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តិអមតនិព្វានដូច្នោះ ។ ក៏បញ្ញត្តិទីបំផុតនោះ មិនជាទីនាំចេញចាកទុក្ខបាន មានត្រឹមតែបញ្ញត្តិ រមែងមិននាំចេញចាកទុក្ខបាន ដែលបណ្ឌិតទាំងឡាយបដិសេធការប្រព្រឹត្តត្រឡប់ដោយប្រការដទៃ ដើម្បីទ្រង់សម្តែង បញ្ញត្តិទីបំផុតនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់យ៉ាងនេះ ។ ក្នុងបទទាំងនោះ បទនេះថា ឯកន្តសុខំ លោកំ ជាដំបូង សេចក្តីថា លោកទាំងឡាយកាលដឹង កាលឃើញយ៉ាងនេះថា ក្នុងទិសខាងកើត លោកមានសុខដោយចំណែកតែមួយ ឬក្នុងទិសណាមួយ បណ្តាទិសទាំងឡាយ មានទិសខាងលិចជាដើមចុះ វត្ថុទាំងឡាយ មានទ្រង់ទ្រាយនៃរាងកាយជាដើម របស់មនុស្សទាំងឡាយក្នុងលោកនោះ លោកទាំងឡាយ

ធ្លាប់ឃើញហើយ ។ បទថា អប្បាដិហិរីកតំ សេចក្ដីថា ភាសិតគ្មានផល គឺ វៀរចាកការឲ្យជាក់ច្បាស់ ឲ្យជ្រាប លោកពោលថា មិននាំចេញចាកទុក្ខ ។

## ការចោទអត្តភាពបីយ៉ាង

**[១០២-១០៣]** បទថា ជនបទកល្យាណី សេចក្តីថា មិនដូចជាស្រីទាំងឡាយដទៃ ដែលមានពណ៌សម្បុរ ទ្រង់ទ្រាយ អាកប្បកិរិយាជាដើម លើលាក្នុងជនបទ ។

**[១០៤]** ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងការបញ្ញត្តិទីបំផុត ក្នុងសមណព្រាហ្មណ៍ពួកដទៃ មិននាំចេញចាកទុក្ខយ៉ាងនេះហើយ ទើបត្រាស់ថា តយោ ខោ មេ ចោដ្ឋបាទ ជាដើម ដើម្បីទ្រង់សម្តែងការបញ្ញត្តិរបស់ព្រះអង្គជាធម៌នាំចេញចាកទុក្ខបាន ។ ក្នុងបទទាំងនោះ បទថា អត្តបដិលាភោ សេចក្តីថា ការត្រឡប់បានអត្តភាព ។ ក៏ក្នុងបទថា អត្តបដិលាភោ នោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងភព ៣ ដោយការត្រឡប់បានអត្តភាព ៣ យ៉ាង ។ ទ្រង់សម្តែងកាមភពតាំងពីអវិចី ដល់បរនិម្មិតវសវត្តីជាទីបំផុត ដោយការត្រឡប់បានអត្តភាពដែលគ្រោតគ្រាត ។ ទ្រង់សម្តែងរូបភពតាំងពីជាន់បឋមជ្ឈាន ដល់អកនិដ្ឋព្រហ្មលោកជាទីបំផុត ដោយការត្រឡប់បានអត្តភាពដែលសម្រេចដោយចិត្ត ។ ទ្រង់សម្តែងអរូបភព តាំងពីអាកាសា-

នញ្ចាយតនព្រហ្មលោក ដល់នេវសញ្ញានាសញ្ញាយតនព្រហ្មលោកជាទីបំផុត ដោយការត្រឡប់បានអត្តភាពដែលមិនមានរូប ។ អកុសលចិត្តប្បាទដប់ពីរយ៉ាង ឈ្មោះថា **សង្កិលេសធម៌** ។ សមថវិបស្សនា ឈ្មោះថា **វោទានធម៌** ។

**[១០៥]** បទថា បញ្ញាចារិបូរិំ វេបុល្លត្តំ សេចក្តីថា សេចក្តីបរិបូណ៌ និងសេចក្តីទូលំទូលាយនៃមគ្គបញ្ញា និងផលបញ្ញា ។ ពាក្យថា **បាមុជ្ជៈ** បានដល់ បីតិទន់ខ្សោយ ។ បទថា **បីតិ** បានដល់ សេចក្តីត្រេកអរមានកម្លាំង លោកពោលយ៉ាងណា ។ លោកពោលយ៉ាងនេះថា ក្នុងបទដែលលោកពោលថា នឹងធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញាដោយខ្លួនឯង និងចូលដល់ កាលភិក្ខុនោះនៅយ៉ាងនេះ ក៏នឹងមានបាមោជ្ជៈ បីតិ សេចក្តីស្ងប់ចិត្ត និងកាយ សតិតាំងមាំល្អ ឧត្តមញាណ និងនៅជាសុខ និងក្នុងបណ្តាការនៅទាំងពួង ការនៅយ៉ាងនេះ សមគួរពោលថា ជាសុខ គឺ ស្ងប់ហើយ មានសេចក្តីសុខយ៉ាងក្រៃលែង ។

បណ្តាឈានទាំងនោះ ក្នុងបឋមជ្ឈាន រមែងបានធម៌សូម្បី ៦ យ៉ាង មានបាមោជ្ជៈជាដើម ។ ក្នុងទុតិយជ្ឈាន បាមោជ្ជៈ ពោលគឺ បីតិតិចតួចរមែងប្រព្រឹត្តទៅ រមែងបានធម៌ ៥ យ៉ាងដ៏សេស ។ ក្នុងតតិយជ្ឈាន

សុខប្បីតិរមែងប្រព្រឹត្តទៅ រមែងបានធម៌ ៤ យ៉ាងដ៏សេស ។ ក្នុងចតុត្ថ-ជ្ឈានក៏ដូចគ្នា ។ ក៏ក្នុងឈានទាំងនេះ លោកពោលឈានដែលជាបាទនៃវិបស្សនាបរិសុទ្ធិប៉ុណ្ណោះ ទុកក្នុងសម្បសាទសូត្រ ។ ពោលវិបស្សនាព្រមនឹងមគ្គបួន ក្នុងបាសាទិកសូត្រ ។ ពោលផលសមាបត្តិ ដែលជាប់ទាក់ទងនឹងចតុត្ថជ្ឈានក្នុងទសុត្តរសូត្រ ។ ផលសមាបត្តិជាប់ទាក់ទងនឹងទុតិយជ្ឈានធ្វើបាមោជ្ជៈឲ្យជាវេវចនៈជាមួយបីតិ គប្បីជ្រាបថា លោកពោលទុកហើយក្នុងបោដ្ឋបាទសូត្រនេះ ។

**[១០៨]** ***វា*** សព្ទក្នុងបទនេះថា អយំ វា សោ ជាអត្ថបុះក្នុងការធ្វើឲ្យច្បាស់ ។ យើងឲ្យជាក់ច្បាស់ហើយ ប្រកាសហើយថា នេះនុ៎ះ គប្បីព្យាករណ៍ ។ សេចក្តីថា សមណព្រាហ្មណ៍ពួកដទៃ ត្រូវតថាគតសួរយ៉ាងនេះថា លោកទាំងឡាយស្គាល់ខ្លួនដែលមានសុខដោយចំណែកតែមួយ ឬក៏នឹងពោលថា មិនស្គាល់ដោយប្រការណា តថាគតនឹងមិនពោលអំពីប្រការនោះ ។

**[១០៩-១១០]** បទថា សប្បាដិហិរិកតំ សេចក្តីថា ភាសិតនឹងមានការឲ្យជ្រាបច្បាស់ គឺ ជាទីនាំចេញចាកទុក្ខ ។

**[១១១]** បទថា មោឃោ ហោតិ សេចក្ដីថា ជារបស់ទទេ ។ អធិប្បាយថា ការបានអត្តភាពនោះ រមែងមិនមានក្នុងសម័យនោះ ។ បទថា សច្ចោ ហោតិ សេចក្ដីថា ជារបស់មានពិត ។ អធិប្បាយថា ការបានអត្តភាពនោះឯង ជារបស់មានមែនក្នុងសម័យនោះ ។ ក៏ក្នុងសេចក្ដីនេះ ចិត្តបុត្រទ្រមាក់ដំរីនេះ សម្ដែងការបានអត្តភាព ៣ យ៉ាង ព្រោះខ្លួនមិនមែនជាសព្វញ្ញូ ទើបមិនអាចលើកឡើងអាងថា ធម្មតាការបានអត្តភាពនោះ មានត្រឹមតែបញ្ញត្តិ ទើបពោលបញ្ចៀសថា ការបានអត្តភាពប៉ុណ្ណោះ ។

**[១១២]** លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រាថ្នានឹងសម្ដែងដល់ចិត្តបុត្រទ្រមាក់ដំរីនោះថា ក៏ក្នុងសេចក្ដីនេះ ធម៌ទាំងឡាយមានរូបជាដើម ការបានអត្តភាពនោះមានត្រឹមតែឈ្មោះ លុះធម៌ទាំងឡាយមានរូបជាដើមនោះៗ មានវោហារដោយសភាពបែបនេះ ក៏រមែងមាន ទ្រង់ចាប់យកពាក្យរបស់ចិត្តបុត្រទ្រមាក់ដំរីនុ៎ះឯង បង្វែរតម្រាស់ដោយអំណាចនៃនាមបញ្ញត្តិ ទើបត្រាស់ពាក្យជាដើមថា ម្នាលចិត្តៈ ក្នុងសម័យណា ៗ ។

ក៏កាលត្រាស់យ៉ាងនោះហើយ ដើម្បីនឹងសាកសួរ ទើបត្រាស់ទៀតថា បើសមណព្រាហ្មណ៍ទាំងឡាយគប្បីសួរយ៉ាងនេះ នឹងចិត្តៈកូនទ្រមាក់ដំរី

នោះ ជាដើម ។

[១១៣] ក្នុងបទទាំងនោះ បទថា យោ មេ អហោសិ សេចក្តីថា ការបានអត្តភាពដែលជាអតីតរបស់ខ្ញុំព្រះអង្គ ជារបស់មានពិតក្នុងសម័យនោះ ។ ក្នុងបទថា **ការបានអត្តភាពដែលជាអនាគតជាមោឃៈ ដែលជាបច្ចុប្បន្នក៏ជាមោឃៈ** ចិត្តបុត្រទ្រមាក់ដំរីពោលសេចក្តីនេះ ត្រឹមតែប៉ុណ្ណេះថា ធម៌ទាំងឡាយដែលជាអតីត ដែលមិនមានក្នុងបច្ចុប្បន្ននេះ តែដល់ការរាប់ថា បានមានហើយ ព្រោះដូច្នោះ ការបានអត្តភាពរបស់ខ្ញុំព្រះអង្គនោះ ទើបមានពិតក្នុងសម័យនោះ ចំណែកការបានអត្តភាពដែលជាអនាគតក៏ជាមោឃៈ ដែលជាបច្ចុប្បន្នក៏ជាមោឃៈ ក្នុងសម័យនោះ ព្រោះធម៌ទាំងឡាយដែលជាអនាគត និងដែលជាបច្ចុប្បន្ន មិនមានក្នុងវេលានោះ ។ គេទទួលដឹងការបានអត្តភាពត្រឹមតែជានាម ដោយអត្ថយ៉ាងនេះ ។ សូម្បីក្នុងអនាគត និងបច្ចុប្បន្ន ក៏មានន័យដូចគ្នា ។

[១១៤-១១៥] លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រៀបធៀបព្យាករណ៍របស់ព្រះអង្គ និងព្យាករណ៍របស់ចិត្តបុត្រទ្រមាក់ដំរីនោះ ទើបត្រាស់ថា ឯវមេវ ខោ ចិត្ត ដូច្នេះជាដើម កាលទ្រង់សម្តែងអត្ថនេះដោយ

ឧបមាទៀត ទើបត្រាស់ថា សេយ្យថាបិ ចិត្ត គវា ខីរំ ម្នាលចិត្ត: ជាដើម ។ ក្នុងបទនោះ មានសេចក្តីដោយសង្ខេបដូច្នេះ ទឹកដោះស្រស់មានអំពីគោ ទឹកដោះជូរជាដើម មានពីទឹកដោះស្រស់ជាដើម ក្នុងសេចក្តីនេះ សម័យណានៅជាទឹកដោះស្រស់ សម័យនោះក៏មិនដល់ការរាប់ គឺ និរុត្តិ នាម វោហារថា ជាទឹកដោះជូរ ឬជាទឹកដោះថ្លាជាដើមណាមួយ ព្រោះហេតុអ្វី ព្រោះមិនមានធម៌ទាំងឡាយដែលបានវោហារជាដើមថា ទឹកដោះជូរ តែសម័យនោះដល់ការរាប់ថា ជាទឹកដោះស្រស់តែម្យ៉ាង ព្រោះហេតុណា ព្រោះមានធម៌ទាំងឡាយដល់នូវការរាប់ គឺ និរុត្តិ នាម វោហារថា ទឹកដោះស្រស់ ។ ក្នុងបទទាំងពួងក៏ន័យនោះ ។

បទថា ឥមា ខោ ចិត្ត សេចក្តីថា ម្នាលចិត្ត: ការបានអត្តភាពដែលគ្រោតគ្រាត ការបានអត្តភាពដែលសម្រេចអំពីចិត្ត និងការបានអត្តភាពដែលមិនមានរូប ទាំងនេះឯងជាលោកសញ្ញា ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងការបានអត្តភាព ៣ យ៉ាង យ៉ាងនេះថា ទាំងនោះមានត្រឹមតែឈ្មោះក្នុងលោក មានត្រឹមតែសញ្ញា ទាំងនោះមានត្រឹមតែភាសាក្នុងលោក មានត្រឹមតែគន្លងពាក្យនិយាយ មានត្រឹមតែវោហារ មានត្រឹមតែនាមបញ្ញត្តិ ដូច្នេះហើយ

ឥឡូវនេះទើបត្រាស់ថា ទាំងអស់នោះ មានត្រឹមតែវោហារ ។ ព្រោះហេតុអ្វី ព្រោះដោយបរមត្ថ មិនមានសត្វ លោកនោះសូន្យទទេ ។

ក៏កថារបស់ព្រះពុទ្ធទាំងឡាយ មានពីរយ៉ាង គឺ សម្មតិកថា និង បរមត្ថកថា ។ ក្នុងកថាទាំងពីរយ៉ាងនោះ កថាថា សត្វ មនុស្ស ទេវតា ព្រហ្មជាដើម ឈ្មោះថា **សម្មតិកថា** ។ កថាថា **អនិច្ចំ ទុក្ខំ អនត្តា ខន្ធ អាយតនៈ ធាតុ សតិប្បដ្ឋាន សម្មប្បធាន** ជាដើម ឈ្មោះថា បរមត្ថកថា ។ ក្នុងកថាទាំងនោះ អ្នកណាកាលព្រះមានព្រះភាគត្រាស់ថា សត្វ មនុស្ស ទេវតា ឬព្រហ្ម រមែងអាចដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនាំចេញចាកទុក្ខ ដើម្បីចាប់កាន់យកនូវទង់ គឺ ព្រះអរហត្តដោយសម្មតិទេសនា ព្រះដ៏មានព្រះភាគក៏ទ្រង់ត្រាស់ថា សត្វ មនុស្ស ទេវតា ឬថា ព្រហ្ម ជាខាង ដើមដល់អ្នកនោះ ។ អ្នកណាស្តាប់ធម៌យ៉ាងណាមួយជាដើមថា **អនិច្ចំ** ឬ **ទុក្ខំ** ដោយបរមត្ថទេសនា រមែងដឹងច្បាស់ ចាក់ធ្លុះរហូតដល់អស់អាសវៈ ដើម្បីនាំចេញចាកទុក្ខ ដើម្បីចាប់កាន់នូវទង់ គឺ ព្រះអរហត្ត ព្រះមានព្រះភាគ ក៏ទ្រង់សម្តែងធម៌យ៉ាងណាមួយជាដើមថា **អនិច្ចំ** ឬថា **ទុក្ខំ** ដល់អ្នកនោះ ។ ព្រោះដូច្នោះ ទើបមិនសម្តែងបរមត្ថកថាមុន សូម្បីដល់សត្វអ្នកនឹងដឹងដោយ

សម្មតិកថា តែទ្រង់ឲ្យដឹងដោយសម្មតិកថាហើយ ទើបទ្រង់សម្តែងបរមត្ថកថាក្នុងខាងក្រោយ និងទ្រង់មិនសម្តែងសម្មតិកថាមុន សូម្បីដល់សត្វអ្នកនឹងដឹងដោយបរមត្ថកថា តែទ្រង់សម្តែងឲ្យដឹងដោយបរមត្ថកថាហើយ ទើបទ្រង់សម្តែងសម្មតិកថាក្នុងខាងក្រោយ ។

តែដោយប្រក្រតី កាលទ្រង់សម្តែងបរមត្ថកថាមុន ទេសនាក៏នឹងមានអាការគ្រោតគ្រាត ព្រោះដូច្នោះ ព្រះពុទ្ធទាំងឡាយទ្រង់សម្តែងសម្មតិកថាមុនហើយ ទើបទ្រង់សម្តែងបរមត្ថកថាក្នុងខាងក្រោយ សូម្បីកាលនឹងទ្រង់សម្តែងសម្មតិកថា ក៏ទ្រង់សម្តែងតាមសេចក្តីពិត តាមសភាពពិត មិនកុហក សូម្បីទ្រង់សម្តែងបរមត្ថកថា ក៏ទ្រង់សម្តែងតាមសេចក្តីពិត តាមសភាពពិត មិនកុហក ។ បុរាណាចារ្យពោលគាថាទុកថា ៖

**ព្រះពុទ្ធដ៏ប្រសើរកាលនឹងត្រាស់ ក៏ត្រាស់សច្ចៈ ២ យ៉ាង**
**គឺ សម្មតិសច្ចៈ និងបរមត្ថសច្ចៈ មិនមានសច្ចៈទី ៣ សង្កេត**
**វចនៈ ជាសច្ចៈ ជាហេតុនៃលោកសម្មតិ បរមត្ថវចនៈ ជា**
**សច្ចៈ ជាលក្ខណៈមានពិតនៃធម៌ទាំងឡាយ ដូច្នេះ ។**

បទថា យាហិ តថាគតោ វោហរតិ អបរាមសន្តោ សេចក្តីថា

ព្រះតថាគតទ្រង់ប្រមូលទេសនាថា ឈ្មោះថា ទ្រង់មិនជាប់ជំពាក់ ព្រោះមិនមានារជាប់ជំពាក់ដោយតណ្ហា មានះ និងទិដ្ឋិ ត្រាស់ដោយលោកសមញ្ញា ដោយលោកនិរុត្តិ ទ្រង់បញ្ចប់ទេសនាដល់កំពូល គឺ ព្រះអរហត្ត ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយទាំងនោះឯង ។

" ចប់ ពោដ្ឋបាទសូត្រ ទី ៩ "

# សុភសូត្រ ទី ១០

## រឿងសុភមាណព

**[១១៦]** *សុភសូត្រមានបទផ្ដើមថា ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ល។ ក្នុងក្រុងសាវត្ថី ។*

*តទៅនេះជាការអធិប្បាយបទដែលលំបាកក្នុងសុភសូត្រនោះ បទថា **កាលព្រះមានព្រះភាគស្ដេចទ្រង់បរិនិព្វានទៅហើយ មិនយូរប៉ុន្មាន** អធិប្បាយថា កាលព្រះមានព្រះភាគ ស្ដេចបរិនិព្វានហើយមិនយូរ ប្រមាណ ១ ខែ បន្ទាប់ពីថ្ងៃបរិនិព្វាន សេចក្ដីនេះ លោកពោលសំដៅដល់ថ្ងៃដែលព្រះអានន្ទកាន់បាត្រ និងចីវររបស់ព្រះដ៏មានព្រះភាគ ហើយមកគង់ឆាន់ថ្នាំបញ្ចុះផ្សំដោយទឹកដោះក្នុងវិហារ ដោយន័យដែលពោលទុកហើយក្នុងនិទាន ។*

**[១១៧]** *បទថា តោទេយ្យបុត្ត ប្រែថា បុត្តរបស់តោទេយ្យព្រាហ្មណ៍ មានរឿងដំណាលថា មិនឆ្ងាយពីក្រុងសាវត្ថី មានស្រុកមួយឈ្មោះតុទិគ្រាម ព្រោះគេជាអ្នកធំសម្បើមក្នុងស្រុកទុតិគ្រាម ទើបមានឈ្មោះថា **តោទេយ្យ***

គេមានទ្រព្យសម្បត្តិប្រមាណ ៨៥ កោដិ តែគេជាអ្នកកំណាញ់យ៉ាងក្រៃលែង គេគិតថា ឈ្មោះថា ការមិនអស់នៃភោគសម្បត្តិ រមែងមិនមានដល់អ្នកឲ្យ ហើយគេក៏មិនឲ្យអ្វីដល់នរណាៗ គេទូន្មានបុត្រថា អ្នកឆ្លាតគួរមើលការអស់ទៅនៃថ្នាំបន្តក់ភ្នែក ការកពូនដំបូក ការសន្សំទឹកឃ្មុំ ហើយគប្បីគ្រប់គ្រងផ្ទះ កាលគេឲ្យបុត្រសញ្ជឹងគិតដល់ការមិនឲ្យយ៉ាងនេះហើយ គ្រាស្លាប់ទៅ ក៏ទៅកើតជាសុនខនៅត្រង់ផ្ទះនោះឯង សុភមាណពជាបុត្រ ស្រឡាញ់សុនខនោះណាស់ ឲ្យស៊ីអាហារដូចគ្នានឹងខ្លួន ពដេកលើទីដេកយ៉ាងល្អ ។

លុះថ្ងៃមួយ កាលសុភមាណពចេញចាកស្រុកទៅ ព្រះមានព្រះភាគស្តេចចូលទៅបិណ្ឌបាតក្នុងផ្ទះនោះ សុនខឃើញព្រះដ៏មានព្រះភាគ ទើបព្រុសដើរចូលទៅជិតព្រះអង្គ ព្រះដ៏មានព្រះភាគ បានត្រាស់ចំពោះសុនខនោះថា ម្នាលតោទេយ្យៈ សូម្បីកាលមុន អ្នកឯងក៏ពោលមើលងាយតថាគតថា នៃលោក នៃលោក ដូច្នេះ ទើបកើតជាសុនខ សូម្បីឥឡូវនេះ អ្នកឯងក៏នៅតែព្រុសយើង នឹងទៅអវិចីមហានរក ។ សុនខស្តាប់ដូច្នោះ មានសេចក្តីក្តៅក្រហាយ ទើបដេកលើផេះចន្លោះចង្ក្រានភ្លើង ។ ពួកមនុស្សមិនអាចនឹងលើកត្រកងពទៅឲ្យដេកលើទីដេកបាន ។ សុភមាណពត្រឡប់មកដល់ សួរថា

អ្នកណានាំសុនខនេះចុះពីទីដេក ។ ពួកមនុស្សទាំងឡាយនាំគ្នាប្រាប់ថា មិនមានអ្នកណាឈ្លើ ហើយពោលរឿងរ៉ាវឲ្យស្តាប់ ។

សុភមាណពបានស្តាប់ហើយ ក្រោធថា បិតារបស់យើងកើតក្នុងព្រហ្មលោក តែព្រះសមណគោតមហាមាត់ថា បិតារបស់យើងជាសុនខ លោកនេះនិយាយអ្វី សំដីស៊ិកសៀត ប្រាថ្នានឹងជំទាស់ជាមួយព្រះមានព្រះភាគ ថានិយាយកុហក ទើបទៅកាន់វិហារសួររឿងរ៉ាវនឹងព្រះអង្គ ។

ព្រះដ៏មានព្រះភាគទើបត្រាស់ដល់សុភមាណពដូចយ៉ាងនោះ ហើយត្រាស់សេចក្តីពិតថា ម្នាលសុភមាណព ទ្រព្យដែលបិតារបស់អ្នកឯងមិនទាន់បានប្រាប់មានទេ ។ សុភមាណពទូលថា ព្រះគោតម ម្ហូកមាសមានតម្លៃមួយសែន ស្បែកជើងមាសមានតម្លៃមួយសែន ថាសមាសមានតម្លៃមួយសែន កហាបណៈមួយសែនមានហើយ ។ ព្រះមានព្រះភាគត្រាស់ថា អ្នកចូរទៅឲ្យសុនខបរិភោគបាយមធុបាយាសមានទឹកតិច ហើយបីទៅកាន់ទីដេក ពេលសុនខលក់មួយស្របក់ ចូរសួរមើល សុនខនឹងប្រាប់វត្ថុគ្រប់យ៉ាងដល់អ្នក ក្នុងកាលនោះឯង អ្នកក៏នឹងដឹងថា សុនខនោះ គឺ បិតារបស់អ្នក ។ សុភមាណពបានធ្វើតាមនោះ ។ សុនខប្រាប់អស់វត្ថុគ្រប់យ៉ាង គេដឹងពិតថា សុនខនោះ

គឺ បិតារបស់គេ ទើបជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគ ទៅទូលសួរបញ្ហា ១៤ ប្រការ ចំពោះព្រះដ៏មានព្រះភាគ កាលចប់បញ្ហា គេសូមដល់ព្រះមានព្រះភាគជាសរណៈ លោកពោលសេចក្តីនោះ សំដៅដល់សុភមាណពតោទេយ្យបុត្រ ។

បទថា **អាស្រ័យនៅជិតក្រុងសាវត្ថី** សេចក្តីថា សុភមាណពមកពីកោគគ្រាមរបស់ខ្លួន ហើយអាស្រ័យនៅ ។ បទថា **ហៅមាណពម្នាក់មក** សេចក្តីថា កាលព្រះសាស្តាស្តេចបរិនិព្វានហើយ សុភមាណពបានស្តាប់ថា ព្រះអានន្ទ កាន់បាត្រ និងចីវររបស់ព្រះអង្គមក មហាជន រមែងនឹងចូលទៅរកលោកដើម្បីសួរសុខទុក្ខ ដូច្នេះ ទើបគិតថា កាលយើងនឹងទៅវិហារ ក៏គង់មិនអាចធ្វើបដិសណ្ឋារៈ ឬស្តាប់ធម្មកថាបានសប្បាយត្រង់កណ្តាលពួកជនជាច្រើន ឃើញលោកមកកាន់ផ្ទះទុំឯង នឹងធ្វើបដិសណ្ឋារៈបានដោយងាយ ហើយយើងមានសេចក្តីសង្ស័យក្នុងប្រការមួយ យើងក៏នឹងសួរលោក ទើបហៅមាណពតូចម្នាក់មក ។

វេទនាដែលជាសត្រូវ លោកពោលថា **អាពាធ** ក្នុងបទជាដើមថា **មានអាពាធតិច** ។ សុភមាណពពោលថា វេទនាណាកើតក្នុងចំណែកមួយហើយ ប្រកាន់ទុកនូវឥរិយាបថ ៤ ដូចយកផែនដែកសង្កត់ អ្នកបួរសួរ

សេចក្តីមិនមាននៃវេទនានោះ ។ បទថា **មានរោគតិចខ្លះ** លោកពោលដល់រោគដែលធ្វើជីវិតឲ្យលំបាក អ្នកចូរសួរ ការមិនមានសូម្បីនៃរោគនោះ ។ សុភមាណពពោលថា ឈ្មោះថា ការក្រោកឡើងរបស់អ្នកជម្ងឺទ្រុឌទ្រោម រមែងធ្ងន់ កម្លាំងកាយរមែងមិនមាន ព្រោះដូច្នោះ អ្នកចូរសួរការមិនមានជម្ងឺនិងការមានកម្លាំង ។

[១១៨] បទថា មាន**ការនៅជាសុខ** សេចក្តីថា អ្នកចូរសួរការរស់នៅជាសុខក្នុងឥរិយាបថ ៤ គឺ ដើរ ឈរ អង្គុយ ដេក គ្រាព្រះគន្ធរបទនាចារ្យកាលសម្តែងដល់អាការដែលគួរនឹងសួរដល់មាណពតូចនោះ ទើបពោលពាក្យជាដើមថា សុភោ ។ បទថា **អាស្រ័យវេលា និងសម័យ** សេចក្តីថា កាន់ គឺពិចារណាវេលា និងសម័យដោយបញ្ញា ។ មានអធិប្បាយថា បើស្អែកនេះនឹងជាវេលាទៅរបស់យើង កម្លាំងរបស់យើងនឹងជ្រួតជ្រាបទៅក្នុងកាយ និងមិនមានការមិនសប្បាយយ៉ាងដទៃ ព្រោះមិនមែនជាហេតុ យើងនឹងពិចារណាវេលានោះ និងសម័យ ពោលគឺ ការទៅ ហេតុ ពួក ក្រុម បើយ៉ាងណាគប្បីមកក្នុងថ្ងៃស្អែកនេះ ។

[១១៩] បទថា **ចេតកភិក្ខុ** សេចក្តីថា បានឈ្មោះថា ចេតកៈ ព្រោះ

កើតក្នុងចេតិយរដ្ឋ ។ បទថា **ពោលសម្មោទនីយកថាល្មមឲ្យរលឹកដល់គ្នា** សេចក្តីថា សុភមាណពបានពោលសម្មោទនីយកថាល្មមឲ្យរឭកដល់គ្នា ដែលជាប់ទាក់ទងនឹងមរណៈ បានកន្លងទៅហើយ ដោយន័យជាដើមយ៉ាងនេះថា ព្រះអានន្ទ ព្រះទសពលមានរោគអ្វី ព្រះដ៏មានព្រះភាគសោយអ្វី មួយវិញទៀត សេចក្តីសោកបានកើតឡើងដល់អ្នកទាំងឡាយ ដោយការបរិនិព្វានរបស់ព្រះសាស្តា ព្រះសាស្តារបស់លោកទាំងឡាយបរិនិព្វានហើយតែម្យ៉ាងក៏ទេ សេចក្តីសាបសូន្យដ៏ធំក៏កើតដល់មនុស្សលោក ព្រមទាំងទេវលោក ឥឡូវនេះអ្នកដទៃ នរណាហ្ន៎នឹងផុតសេចក្តីស្លាប់ ក៏បុគ្គលដ៏ប្រសើររបស់មនុស្សលោក ព្រមទាំងទេវលោក ញុំាងស្តេចបរិនិព្វានបាន ឥឡូវនេះមច្ចុរាជនឹងឃើញអ្នកណាដទៃហើយខ្លាស សុភមាណព ថ្វាយអាហារដែលសមគួរដល់ការឆាន់ និងភេសជ្ជៈដល់ព្រះថេរៈកាលថ្ងៃម្សិលមិញ កាលសម្រេចភត្តកិច្ចទើបអង្គុយក្នុងចំណែកម្ខាង ។ បទថា **ជាឧបដ្ឋាក នៅក្នុងសម្នាក់** សេចក្តីថា ជាឧបដ្ឋាកនៅក្នុងសម្នាក់មិនស្វែងរកទោស ។ បទថា **នៅជិតជិត** នេះ ជាវេវចនៈរបស់បទមុន ព្រោះហេតុណា សុភមាណពទើបសួរថា ព្រះគោតមបានត្រាស់សរសើរគុណនៃធម៌ពួកណា ។ ន័យថា សុភមាណពមានបរិវិតក្កៈ

យ៉ាងនេះថា ព្រះគោតមដ៏ចម្រើន ញ៉ាំងមនុស្សលោកនេះឲ្យតាំងនៅក្នុងធម៌ពួកណា ធម៌ទាំងនោះ ដែលព្រះគោតមកន្លងទៅហើយ សាបសូន្យទៅហើយ ឬហ្ន៎ ឬតាំងនៅ បើតាំងនៅ ព្រះអានន្ទនឹងដឹង ខ្ញុំសូមឱកាសសួរ ដូច្នេះ ព្រោះដូច្នោះ សុភមាណពទើបសួរឡើង ។ គ្រានោះ ព្រះថេរៈបានសង្គ្រោះបិដក ៣ ដោយខន្ធ ៣ កាលនឹងសម្តែងដល់សុភមាណព ទើបពោលថា **នៃខន្ធទាំងឡាយ ៣** ដូច្នេះជាដើម ។ សុភមាណពគិតថា យើងកំណត់សេចក្តីដែលលោកពោលដោយសង្ខេបមិនបាន នឹងសួរដោយពិស្តារ ទើបពោលថា **នៃខន្ធទាំងឡាយ ៣ ដូចម្តេច** ដូច្នេះជាដើម ។

# សីលក្ខន្ធ

[១២០-១២១] កាលព្រះអានន្ទសម្តែងខន្ធទាំងនោះ ដោយបទថា **នៃសីលក្ខន្ធដ៏ប្រសើរ** ដូច្នេះ សុភមាណពទើបសួរជាសេចក្តីមួយៗ ទៀតថា **បពិត្រព្រះអានន្ទដ៏ចម្រើន សីលក្ខន្ធដ៏ប្រសើរ តើដូចម្តេច** ។ សូម្បីព្រះថេរៈក៏សម្តែងដល់ការឧប្បត្តិរបស់ព្រះពុទ្ធដល់សុភមាណពនោះ កាលនឹងសម្តែងធម៌ដែលជាបែបផែន ទើបវិសជ្ជនាធម៌ទាំងពួង ដោយន័យដែលព្រះដ៏មានព្រះភាគត្រាស់ទុកដោយលំដាប់នោះឯង ។

[១២២] ក្នុងបទថា **ក្នុងព្រះធម្មវិន័យនេះ នៅមានកិច្ចដែលនឹងត្រូវធ្វើឲ្យក្រៃលែងឡើងតទៅទៀត** លោកសម្តែងថា ក្នុងសាសនារបស់ព្រះមានព្រះភាគនេះ មិនមែនត្រឹមតែសីលប៉ុណ្ណោះដែលមានសារៈ សីលនោះត្រឹមតែដូចផែនដីតែម្យ៉ាងប៉ុណ្ណោះ នៅមានកិច្ចដទៃដែលនឹងត្រូវធ្វើក្រៃលែងជាងនេះទៀត ។

បទថា **ខាងក្រៅអំពីសាសនានេះ** គឺ ខាងក្រៅពីព្រះពុទ្ធសាសនា ។

## សមាធិខន្ធ

[១២៣-១២៩] បទថា **ម្នាលមាណព ភិក្ខុជាអ្នកមានទ្វារគ្រប់គ្រង ហើយក្នុង ឥន្ទ្រិយទាំងឡាយ តើដូចម្តេច** ព្រះអានន្ទសូម្បីត្រូវសួរដល់សមាធិខន្ធ យ៉ាងនេះថា **បពិត្រព្រះអានន្ទដ៏ចម្រើន ចុះសមាធិខន្ធដ៏ប្រសើរនោះ តើដូចម្តេច** ព្រះថេរៈមានបំណងនឹងសម្តែងឲ្យឃើញ នូវធម៌មានឧបការៈដល់ធម៌ទាំងពីរ ក្នុងរវាងសីល និងសមាធិ ដែលមានឥន្ទ្រិយសំវរៈជាដើម ដែលលោកលើក ឡើងសម្តែងក្នុងលំដាប់សីលយ៉ាងនេះថា ភិក្ខុសម្បូរណ៍ដោយសីល មាន ទ្វារឃុំគ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ដល់ព្រមដោយសតិសម្បជញ្ញៈ ជាអ្នក សន្តោស ដូច្នេះហើយ សម្តែងសមាធិខន្ធ ទើបបានពោលពាក្យផ្តើមឡើង ។ ក្នុងទីនេះ សម្តែងដល់រូបឈានប៉ុណ្ណោះ ទើបមិនគួរនាំអរូបឈានមកសម្តែង ។ ព្រោះឈ្មោះថា អរូបសមាបត្តិមិនបានសង្គ្រោះដោយចតុត្ថជ្ឈាន ទើបមិនមាន ។

[១៣០-១៣៩] បទថា **ក្នុងធម្មវិន័យនេះ នៅមានកិច្ចដែលនឹងត្រូវធ្វើ ឲ្យក្រៃលែងឡើងទៀត** លោកសម្តែងថា ឈ្មោះថា ការកើតឡើងនៃទីបំផុត មិនមានក្នុងសាសនារបស់ព្រះដ៏មានព្រះភាគនេះ ដោយត្រឹមតែចិត្តមានអារម្មណ៍

តែមួយប៉ុណ្ណោះ នៅមានកិច្ចដទៃដែលនឹងត្រូវធ្វើក្រៃលែងជាងនេះទៀត ។

បទថា **ក្នុងធម្មវិន័យនេះ នៅមានកិច្ចដែលនឹងត្រូវធ្វើឲ្យក្រៃលែងឡើងទៀត** លោកសម្ដែងថា ឈ្មោះថា កិច្ចដែលនឹងត្រូវធ្វើឲ្យក្រៃលែងជាងនេះមិនមាន ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគនេះ ព្រោះសាសនារបស់ព្រះដ៏មានព្រះភាគមានព្រះអរហត្តជាទីបំផុត ។ បទដ៏សេសមានសេចក្ដីងាយក្នុងទីទាំងពួង ។

ចប់ អដ្ឋកថា សុភសូត្រទី ១០

# កេវដ្ដសូត្រទី ១១

## រឿងកេវដ្ដគហបតិបុត្ត

**[១៤០]** *កេវដ្ដសូត្រមានបទផ្ដើមថា ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ ចាវារិកម្ពវនេ ខ្ញុំ (ព្រះអានន្ទ) បានស្ដាប់មកយ៉ាងនេះ ។ល។ ជិតស្រុកនាលន្ទា ។ នឹងពណ៌នាបទដោយលំដាប់ក្នុងកេវដ្ដសូត្រនោះ ។*

*បទថា* ***បាវារិកម្ពវនេ*** *គឺ ព្រៃស្វាយរបស់បាវារិកសេដ្ឋី ។ បទថា កេវដ្ដ នេះ ជាឈ្មោះរបស់បុត្រគហបតី ។ មានរឿងដំណាលមកថា កេវដ្ដៈ បុត្រគហបតីនោះ មានទ្រព្យប្រមាណ ៤០ កោដិ ជាគហបតីស្ដុកស្ដម ជាអ្នកមានសទ្ធាជ្រះថ្លា (ព្រះពុទ្ធសាសនា) យ៉ាងក្រៃលែង ព្រោះហេតុដែលគេមានសទ្ធាដ៏ក្រៃលែង គេទើបគិតថា បើនឹងមានភិក្ខុត្រឹមតែមួយរូប ហោះទៅតាមអាកាស គប្បីសម្ដែងបាដិហារ្យច្រើនយ៉ាង រវាងកន្លះខែ ឬមួយខែ ឬមួយឆ្នាំ មហាជនក៏នឹងនាំគ្នាជ្រះថ្លាក្រៃលែង បើដូច្នោះ យើងនឹងក្រាបទូលសូមអង្វរព្រះដ៏មានព្រះភាគ ឲ្យទ្រង់អនុញ្ញាតភិក្ខុមួយរូបដើម្បីសម្ដែងបាដិហារ្យ*

ហើយចូលទៅចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលយ៉ាងនេះ ។

បទថា **ស្តុកស្តម្ភ** គឺ ស្តុកស្តម្ភសម្បូរណ៍ ។ បទថា **បរិបូណ៌** គឺ ដល់សេចក្តីចម្រើន ព្រោះច្រើនដោយភណ្ឌៈផ្សេងៗ ។ បទថា **មនុស្សកុះករ** អធិប្បាយថា កុះករទៅដោយពួកមនុស្សស្រេញរទៅមក មើលឃើញដូចជាជ្រៀតគ្នាដោយស្មានិងស្មា ។

បទថា **សូមបង្គាប់** សំដៅដល់ ស្មើសុំ គឺ ឲ្យទទួលតំណែង ។ បទថា **ធម៌ដ៏ក្រៃលែងរបស់មនុស្ស** អធិប្បាយថា ក្រៃលែងជាងធម៌របស់មនុស្សអ្នកក្រៃលែងបំផុត ឬធម៌របស់មនុស្ស បានដល់ កុសលកម្មបថ ១០ ។ បទថា **ភាពដ៏ក្រៃលែងបំផុតដែលនឹងប្រមាណបាន** អធិប្បាយថា នឹងជ្រះថ្លាយ៉ាងក្រៃលែងបំផុតដែលនឹងប្រមាណបាន ដូចដួងប្រទីបដ៏រុងរឿង សូម្បីជាងប្រក្រតី ព្រោះអាស្រ័យប្រេង ។

បទថា **តថាគតមិនសម្តែងធម៌យ៉ាងនេះ** មានអធិប្បាយថា ព្រះមាន-ព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទទុកក្នុងរឿងរាជគហសេដ្ឋី ព្រោះដូច្នោះ ទើបត្រាស់ពាក្យជាដើមថា តថាគតមិនសម្តែងធម៌យ៉ាងនេះ ។ បទថា **មិនកម្ចាត់** អធិប្បាយថា ព្រះមានព្រះភាគត្រាស់ថា តថាគតនឹងមិនទម្លាយឲ្យគុណវិសេស

វិនាសទៅ គឺ ឲ្យដល់ការទម្លាយសីល ហើយថយចុះពីឋានៈខ្ពស់ តាំងនៅក្នុងឋានៈទាបដោយលំដាប់ តាមការពិត ខ្ញុំព្រះអង្គប្រាថ្នាសេចក្ដីចម្រើនរបស់ព្រះពុទ្ធសាសនា ទើបពោលដូច្នោះ ។ បទថា **ជាគម្រប់ ៣ ដង** អធិប្បាយថា មិនមានអ្នកអាចនឹងពោលហាមព្រះតម្រាស់របស់ព្រះពុទ្ធដល់ ៣ ដង តែកេវដ្ដៈក្រាបទូលដល់ ៣ ដង ដោយគិតថា យើងជិតដិតនឹងព្រះដ៏មានព្រះភាគជា អ្នកមានមេត្តាប្រាថ្នាចំពោះប្រយោជន៍ ដូច្នេះ ។

# ឥទ្ធិបាដិហារិយ

[១៤១] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះចិន្តាថា ឧបាសកនេះ សូម្បីកាលតថាគតហាម ក៏នៅតែសូមអង្វររឿយៗ ណ្ហើយចុះ តថាគតនឹងសម្តែងទោសក្នុងការសម្តែងបាដិហារ្យដល់គេ ទើបត្រាស់ពាក្យជាដើមថា **បាដិហារ្យ ៣ យ៉ាងនេះ** ។

ក្នុងបទទាំងនោះ បទថា អមាហំ ភិក្ខុំ កាត់បទជា អមុំ អហំ ភិក្ខុំ ។

បទថា **វិជ្ជាឈ្មោះគន្ធារី** អធិប្បាយនេះ វិជ្ជានេះ ឥសីឈ្មោះគន្ធារៈ ជាអ្នកធ្វើ ឬជាវិជ្ជាដែលកើតឡើងក្នុងដែនគន្ធារៈ ។

មានរឿងដំណាលមកថា ក្នុងដែនគន្ធារៈនោះ ពួកឥសីអាស្រ័យនៅច្រើន បណ្តាឥសីទាំងនោះ ឥសីម្នាក់ធ្វើវិជ្ជានេះឡើង ។ បទថា **យើងលំបាកចិត្ត** អធិប្បាយថា យើងនឿយណាយ គឺ ហាក់បីដូចជាត្រូវបៀតបៀន ។ បទថា **ធុញទ្រាន់** គឺ ខ្មាស់ ។

បទថា **យើងខ្ពើមរអើម** គឺ យើងកើតការខ្ពើមរអើម ដូចឃើញលាមក ។

## អាទេសនាបាដិហារិយ

[១៤២] បទថា **នៃសត្វដទៃ** គឺ នៃសត្វទាំងឡាយពួកដទៃ ។ បទទី ២ គឺ **បុគ្គលដទៃ** ជាវេវចនៈរបស់បទនោះឯង ។ បទថា **រមែងទាយ** គឺ រមែងពោល ។

ពាក្យថា **ការដឹងក្នុងចិត្ត** សំដៅដល់ សោមនស្ស និងទោមនស្ស ។ បទថា **ចិត្តរបស់លោកប្រព្រឹត្តទៅដោយអាការយ៉ាងនេះ** អធិប្បាយថា ចិត្តរបស់លោកតាំងនៅក្នុងសោមនស្ស ទោមនស្ស ឬប្រកបដោយកាមវិតក្កៈជាដើម ។ បទទី ២ គឺ ជាវេវចនៈរបស់បទនោះឯង ។ បទថា **ចិត្តរបស់លោកមានយ៉ាងនេះ** គឺ ចិត្តរបស់លោកមានយ៉ាងនេះ ។ អធិប្បាយថា ចិត្តរបស់លោកគិតដល់រឿងនេះ និងរឿងនេះប្រព្រឹត្តទៅហើយ ។ បទថា **វិជ្ជាឈ្មោះមណិកា** លោកចង្អុលបង្ហាញថា មានវិជ្ជាមួយក្នុងលោក បានឈ្មោះយ៉ាងនេះថា **ចិន្តាមណី** បុគ្គលរមែងដឹងដល់ចិត្តរបស់អ្នកដទៃបាន ដោយវិជ្ជាចិន្តាមណីនោះ ។

# អនុសាសនីបាដិហារិយ

[១៤៣-១៤៤] បទថា **អ្នកទាំងឡាយចូរត្រិះរិះយ៉ាងនេះចុះ** គឺ ត្រិះរិះឲ្យប្រព្រឹត្តទៅក្នុងផ្លូវនេក្ខម្មវិតក្កៈជាដើម ។ បទថា **កុំត្រិះរិះយ៉ាងនេះឡើយ** គឺ កុំត្រិះរិះឲ្យប្រព្រឹត្តទៅក្នុងផ្លូវកាមវិតក្កៈជាដើម ។ បទថា **ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះចុះ** គឺ ធ្វើទុកក្នុងចិត្តដល់អនិច្ចសញ្ញា ឬយ៉ាងណាមួយក្នុងទុក្ខសញ្ញាជាដើម យ៉ាងនេះ ។ បទថា **កុំ........... យ៉ាងនេះ** គឺ កុំធ្វើទុកក្នុងចិត្តដោយន័យជាដើមថា ជារបស់ទៀង ដូច្នេះ ។ បទថា **ចូរលះបង់** គឺ ចូរលះបង់នូវតម្រេកដែលលាបដោយកាមគុណនេះ ។ បទថា **ចូរដល់** អធិប្បាយថា ចូរចូលដល់ គឺ សម្រេច ចាក់ធ្លុះលោកុត្តរធម៌ បានដល់ មគ្គ ៤ ផល ៤ នេះឯង ។ ព្រះមានព្រះភាគទ្រង់សម្ដែងឫទ្ធិផ្សេងៗ ឈ្មោះ **ឥទ្ធិបាដិហារិយ** ។ ការដឹងចិត្តរបស់អ្នកដទៃ ហើយនិយាយ ឈ្មោះ **អាទេសនាបាដិហារិយ** ។ ការសម្ដែងធម៌រឿយៗ របស់ព្រះសាវក និងរបស់ព្រះពុទ្ធ ឈ្មោះ **អនុសាសនីបាដិហារិយ** ។

ក្នុងបាដិហារិយទាំងនោះ ព្រះមហាមោគ្គល្លានសម្ដែងអនុសាសនីបាដិ-

ហារ្យដោយឥទ្ធិបាដិហារ្យ , ព្រះធម្មសេនាបតីសារីបុត្រសម្ដែងអនុសាសនី-បាដិហារ្យ ដោយអាទេសនាបាដិហារ្យ ។ កាលព្រះទេវទត្តទម្លាយសង្ឃ បាននាំភិក្ខុ ៥០០ រូបទៅ ហើយសម្ដែងធម៌ដល់ភិក្ខុទាំងនោះ ដោយពុទ្ធលីលាក្នុងតំបន់គយាសីសៈ កាលព្រះដ៏មានព្រះភាគ ទ្រង់បញ្ជូនព្រះអគ្គសាវក ២ រូបទៅ ព្រះធម្មសេនាបតីសារីបុត្រជ្រាបវារចិត្តរបស់ភិក្ខុទាំងនោះ ហើយសម្ដែងធម៌ ។ ភិក្ខុទាំង ៥០០ ស្ដាប់ធម៌ទេសនារបស់ព្រះថេរៈ ក៏សម្រេចសោតាបត្តិផល ។ តមកព្រះមហាមោគ្គល្លានត្ថេរៈ បានសម្ដែងការប្លែងឫទ្ធិផ្សេងៗ ហើយសម្ដែងធម៌ដល់ភិក្ខុទាំងនោះ ភិក្ខុទាំងអស់ស្ដាប់ធម៌របស់លោកហើយ ខ្លះបានសម្រេចព្រះអរហត្តផល ។ រួចហើយព្រះមហានាគទាំងពីរនាំភិក្ខុ ៥០០ រូប ហោះតាមអាកាសមកដល់វិហារវេឡុវ័ន ។ ការសម្ដែងធម៌រឿយៗ របស់ព្រះពុទ្ធទាំងឡាយ ជាអនុសាសនីបាដិហារ្យ ។ ក្នុងបាដិហារ្យទាំងនោះ ឥទ្ធិបាដិហារ្យ និងអាទេសនាបាដិហារ្យ ក៏នៅតិះដៀលបាន នៅមានទោស មិនតាំងនៅយូរ ព្រោះមិនយឺនយូរ ទើបមិននាំសត្វឲ្យផុតទុក្ខបាន ។ អនុសាសនីបាដិហារ្យប៉ុណ្ណោះ តិះដៀលមិនបាន មិនមានទោស តាំងនៅបានយូរ ព្រោះតាំងនៅបានយូរ ទើបនាំសត្វឲ្យផុតទុក្ខបាន ។ ព្រោះដូច្នោះ

ព្រះដ៏មានព្រះភាគ ទើបទ្រង់តិះដៀលឥទ្ធិបាដិហារ្យ និងអាទេសនាបាដិហារ្យ ទ្រង់សរសើរអនុសាសនីបាដិហារ្យតែម្យ៉ាង ។

# ភូតនិរោធេសកវត្ថុ

[១៨៥] បទថា ***រឿងធ្លាប់មានមកហើយនេះ*** ព្រោះហេតុណា ព្រះមាន-ព្រះភាគ ទើបទ្រង់ប្រារព្ធឡើង ។ ទ្រង់ប្រារព្ធឡើង ក៏ដើម្បីទ្រង់សម្ដែងដល់ឥទ្ធិបាដិហារ្យ និងអាទេសនាបាដិហារ្យ មិននាំសត្វឲ្យរួចចាកទុក្ខបាន និងដើម្បីទ្រង់សម្ដែងដល់អនុសាសនីបាដិហារ្យប៉ុណ្ណោះ ដែលនាំសត្វឲ្យផុតពីទុក្ខបាន ។ ម្យ៉ាងទៀត មានភិក្ខុមួយរូប ឈ្មោះ **មហាភូតបរិយេសកៈ** ស្វែងរកមហាភូតរូប ត្រាច់ទៅដរាបដល់ព្រហ្មលោក មិនបានឱកាសដោះស្រាយបញ្ហា ទើបមកទូលសួរព្រះពុទ្ធ ហើយក៏អស់សង្ស័យទៅ ។ ព្រោះហេតុអ្វី ។ ដើម្បីប្រកាសភាពជាធំក្រៃលែងរបស់ព្រះពុទ្ធទាំងឡាយ ។ ហេតុការណ៍យ៉ាងនេះបានបិទបាំងហើយ គ្រាតមក ព្រះដ៏មានព្រះភាគកាលនឹងទ្រង់បើកបង្ហាញ សម្ដែងហេតុការណ៍នោះ ទើបត្រាស់ពាក្យជាអាទិថា រឿងធ្លាប់មានមកហើយ ដូច្នេះ ។ បទថា **ក្នុងទីណាហ្ន៎** អធិប្បាយថា បុគ្គលអាស្រ័យអ្វីសម្រេចអ្វី មហាភូត ៤ នោះ ទើបរលត់ដោយមិនមានសល់ ដោយអំណាចប្រព្រឹត្តទៅមិនបានក្នុងទីណា ក៏មហាភូតកថានេះ លោកពោលទុកហើយក្នុង

វិសុទ្ធិមគ្គដោយពិស្តារ ។ ព្រោះដូច្នោះ គួរស្វែងរកពីសុទ្ធិមគ្គនោះចុះ ។

បទថា **ផ្លូវជាទីទៅកាន់ទេវលោក** គឺ ឈ្មោះថា ផ្លូវទៅទេវលោកនោះមិនមាន ។

ក៏បទនោះ ជាឈ្មោះរបស់ឥទ្ធិវិធញ្ញាណ ។ ពិតហើយ ផ្លូវនោះប្រព្រឹត្តទៅដោយអំណាចផ្លូវកាយ រមែងទៅកាន់ទេវលោក រហូតដល់ព្រហ្មលោកបានដោយផ្លូវនោះ ព្រោះដូច្នោះ លោកទើបពោលថា ផ្លូវទៅទេវលោក ។ បទថា **ដាន់ចាតុម្មហាភូត តើទីណា** សេចក្តីថា ភិក្ខុមិនទូលសួរព្រះដ៏មានព្រះភាគ សូម្បីប្រថាប់នៅក្នុងទីជិត សម្គាល់ថា តាមធម្មតាទេវតាដែលគេចោទគ្នា រមែងមានអានុភាពច្រើន ដូច្នេះទើបចូលទៅរក ។ សេចក្តីថា **ភិក្ខុ យើងទាំងឡាយនេះឯងមិនដឹង** សំដៅដល់ ពួកទេវតាត្រូវសួរបញ្ហាក្នុងពុទ្ធវិស័យ រមែងមិនដឹង ទើបបានពោលយ៉ាងនោះ ។ លំដាប់នោះ ភិក្ខុនោះ គម្រាមពួកទេវតាថា ពួកលោកឆ្លើយបញ្ហានេះ របស់យើងមិនបាន ក៏ចូរប្រាប់មករហ័សៗ ទើបសួរហើយសួរទៀត ។ ពួកទេវតាគិតថា ភិក្ខុរូបនេះគម្រាមយើង យើងនឹងដោះលែងភិក្ខុនោះឲ្យរួចផុតអំពីពួកយើងទៅ ទើបបានពោលពាក្យជាដើមថា បពិត្រភិក្ខុ នៅមានមហាភូត ៤ ព្រះអង្គទៀត ។

[១៨៦] បទថា **រុងរឿងក្រៃលែង** គឺ ល្អហួសប្រមាណ ។ បទថា **វិសេសជាង** គឺ ខ្ពស់បំផុតដោយវណ្ណៈ យស និងកាពជាធំជាដើម ។ គប្បីជ្រាបសេចក្ដីក្នុងគ្រប់វារៈដោយន័យនេះ ។ តែសេចក្ដីនេះពិសេស សេចក្ដីថា ស្ដេចសក្កទេវរាជទ្រង់ត្រិះរិះថា បញ្ហានេះជាពុទ្ធវិស័យ អ្នកដទៃមិនអាចដោះស្រាយបាន ក៏ភិក្ខុនេះ លះបង់ព្រះសម្មាសម្ពុទ្ធដែលជាអគ្គបុគ្គលក្នុងលោកត្រាច់សួរពួកទេវតា ដូចអ្នកវៀរភ្លើងកាន់យកពន្លឺអំពិលអំពែក និងដូចអ្នកលះបង់ស្គរ វាយពោះ យើងនឹងបញ្ជូនភិក្ខុនោះ ទៅកាន់សម្នាក់ព្រះសាស្ដា ។ លំដាប់នោះ ស្ដេចសក្កទេវរាជទ្រង់ត្រិះរិះទៀតថា ភិក្ខុនោះទៅឆ្ងាយណាស់ហើយ នឹងអស់សង្ស័យក្នុងសម្នាក់របស់ព្រះសាស្ដា មួយទៀត ធម្មតាបុគ្គលបែបនេះក៏មាននៅ កាលធ្វើដំណើរទៅបានត្រឹមតែបន្តិចបន្តួច នឹងមានសេចក្ដីលំបាកច្រើន តែខាងក្រោយនឹងដឹង ដូច្នេះ ទើបពោលនឹងភិក្ខុនោះជាដើមថា សូម្បីយើងក៏មិនដឹង ដូច្នេះ ។ សូម្បីផ្លូវទៅព្រហ្មលោក ក៏ដូចគ្នានឹងផ្លូវទៅទេវលោក ។ ផ្លូវទៅទេវលោកក្ដី ផ្លូវទៅព្រហ្មលោកក្ដី ការចូលដល់ធម៌ក្ដី ការតម្កល់មាំដោយខណៈចិត្តមួយក្ដី ការប៉ោនស្មានក្ដី ចិត្តទៅខ្ពស់ក្ដី ការដឹងក្រៃលែងក្ដី ទាំងអស់នេះ ជាឈ្មោះរបស់ឥទ្ធិវិធញ្ញាណ ទុំះឯង ។

[១៨៧] បទថា **បុព្វនិមិត្ត** លោកសម្តែងទុកថា និមិត្តចំណែកដំបូង ដែលនឹងមកដល់ ដូចពន្លឺអរុណមាន ព្រោះព្រះអាទិត្យរះឡើង ព្រោះដូច្នោះ ព្រះព្រហ្មនឹងមកក្នុងកាលឥឡូវនេះ ។ ពួកខ្ញុំដឹងត្រឹមនេះ ។ បទថា ធាតុ-រហោសិ ប្រែថា បានប្រាកដហើយ ។

[១៨៨] គ្រានោះឯង ព្រះព្រហ្ម កាលត្រូវភិក្ខុនោះសួរ ដឹងថា សេចក្តីនេះមិនមែនជាវិស័យរបស់ខ្លួន ទើបគិតថា បើយើងប្រាប់ថា យើងមិនដឹង ភិក្ខុនេះនឹងមើលងាយយើង បើយើងនឹងពោលអ្វីៗ ធ្វើដូចជាដឹង ភិក្ខុនេះមិនមានចិត្តប្រាថ្នាដោយពាក្យព្យាករណ៍របស់យើង នឹងលើកពាក្យនិយាយរបស់យើង កាលយើងប្រាប់ថា **បពិត្រភិក្ខុ ខ្ញុំជាព្រហ្ម** ដូច្នេះជាដើម នរណាៗជាដើម នរណាៗ ក៏នឹងមិនជឿពាក្យ បើយ៉ាងណា យើងនឹងប្រាប់បង្វៀងបញ្ជូនភិក្ខុនេះឲ្យទៅគាល់ព្រះសាស្តា ដូច្នេះ ទើបពោលថា **បពិត្រភិក្ខុ ខ្ញុំជាព្រហ្ម** ដូច្នេះជាដើម ។

[១៨៩] បទថា **នាំចេញទៅក្នុងទីសមគួរ** ដូច្នេះ ព្រោះហេតុណាទើបបានធ្វើយ៉ាងនោះ ព្រោះតែសេចក្តី ងឿងឆ្ងល់ ។ បទថា **ស្វែងរកខាងក្រៅ** អធិប្បាយថា ដល់ការស្វែងរកបុគ្គលខាងក្រៅ រហូតដល់ព្រហ្មលោក

ដូចអ្នកត្រូវការប្រេង ប្រាប់ខ្សាច់ ដូច្នោះ ។

[១៥០] បទថា សត្ថុស្សាប បានដល់ ក្អែក ឬស្ទាំង ។ សេចក្ដីថា **អ្នកមិនគួរសួរបញ្ហាយ៉ាងនេះ** មានអធិប្បាយថា ព្រោះភិក្ខុគួរសួរបញ្ហាឲ្យត្រូវ ក៏ភិក្ខុនេះកាន់វត្ថុមិនមានចិត្តគ្រប់គ្រង សួរក្រៅបញ្ហា ដូច្នោះ ព្រះមានព្រះភាគទើបទ្រង់បដិសេធ ។ ន័យថា ការសម្ដែងទោសនៃពាក្យសួររបស់អ្នកវង្វេងក្នុងពាក្យសួរ ហើយឲ្យសញ្ជឹងគិតពាក្យសួរ ទើបឆ្លើយក្នុងខាងក្រោយ ជាគោលបដិបត្តិរបស់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុណា ។ ព្រោះអ្នកមិនដឹងដើម្បីនឹងសួរ ទើបសួរ ឈ្មោះថា ជាអ្នកមិនឆ្លាត ។ ព្រះមានព្រះភាគទ្រង់ឲ្យពិចារណាបញ្ហា ទើបត្រាស់ថា អាបោធាតុ រមែងតាំងនៅមិនបានក្នុងទីណា ដូច្នេះជាដើម ។

[១៥១] បទថា **តាំងនៅមិនបាន** គឺ តាំងនៅមិនបាន មានអធិប្បាយថា មហាភូតរូបទាំង ៤ នេះ អាស្រ័យអ្វី ទើបតាំងនៅមិនបាន លោកសួរសំដៅដល់វត្ថុមានចិត្តគ្រងប៉ុណ្ណោះ ។ បទថា **វែង និងខ្លី** លោកពោលដល់ឧបាទាយរូបដោយសណ្ឋាន ។ បទថា **ល្អិត គ្រោតគ្រាត** សំដៅដល់ តូច ឬធំ ។ លោកពោលត្រឹមតែទ្រង់ទ្រាយក្នុងឧបាទាយរូបប៉ុណ្ណោះ សូម្បីដោយ

បទនេះ ។ បទថា **ស្អាត និងមិនស្អាត** គឺ ឧបទាយរូបដែលស្អាត និងមិនស្អាតនុ៎ះឯង ក៏គឺ ឧបាទាយរូបស្អាត និងមិនស្អាត មាន ឬមិនមាន ។ តែលោកពោលដល់ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ បទថា **នាម និងរូប** គឺ នាម និងរូប ដែលផ្សេងគ្នា មានវែងជាដើម ។ បទថា ឧបរុជ្ឈតិ ប្រែថា រមែងរលត់ទៅ ។

**[១៩២]** ព្រះដ៏មានព្រះភាគទ្រង់បង្អុលបង្ហាញពាក្យសួរថា គួរនឹងសួរយ៉ាងនេះថា នាម និងរូបនោះ អាស្រ័យអ្វីទើបប្រព្រឹត្តទៅមិនបាន ដោយមិនមាននៅសល់ កាលនឹងទ្រង់ដោះស្រាយបញ្ហា ទើបត្រាស់ថា ក្នុងបញ្ហានោះមានព្យាករណ៍ដូច្នេះ ហើយត្រាស់ថា **ធម្មជាតិដែលដឹងច្បាស់** ជាដើម ។

បទថា **គួរដឹងច្បាស់** គឺ ធម្មជាតិដែលគួរគួរដឹងច្បាស់ ។ ជាឈ្មោះរបស់និព្វាន ។ និព្វាននោះ **សម្តែងមិនបាន** ព្រោះមិនមានការសម្តែង ។ និព្វានឈ្មោះថា **គ្មានទីបំផុត** ព្រោះមិនមានការកើត មិនមានការរលត់ មិនមានបែបភាពយ៉ាងដទៃរបស់អ្នកតាំងនៅ ។ បទថា **ទឹកថ្លា** គឺ ទឹកស្អាត ។ ន័យថា បទនេះ ជាឈ្មោះរបស់កំពង់ទឹក ។ ជាទឹកដែលហូរ លោកធ្វើ **ប** អក្សរ ឲ្យជា **ក** អក្សរ កំពង់ធ្លងរបស់និព្វាននោះ មាននៅគ្រប់កន្លែង

ព្រោះដូច្នោះ ទើបឈ្មោះថា **មានកំពង់ចូលគ្រប់កន្លែង** ។ ជនទាំងឡាយ ប្រាថ្នានឹងចូលអំពីទីណាៗ របស់មហាសមុទ្រ មានកំពង់ជាខាងដើមផ្លូវ ដែលនឹងមិនមានកំពង់ក៏ទេ យ៉ាងណា ជនទាំងឡាយប្រាថ្នានឹងចូលឲ្យដល់ព្រះនិព្វាន ដោយឧបាយយ៉ាងណាក្នុងកម្មដ្ឋាន ៣៨ ជាកំពង់ ជាខាងដើមផ្លូវ កម្មដ្ឋានមិនមែនកំពង់របស់និព្វានមិនមាន ដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា មានកំពង់ចូលគ្រប់កន្លែង ។ ក្នុងបទថា **អាបោធាតុនេះ** លោកអាស្រ័យនិព្វាន ទើបពោលទាំងអស់នោះ ដោយន័យជាដើមថា អាបោធាតុធម្មជាតិដែលមានចិត្តគ្រប់គ្រង រមែងរលត់ដោយមិនមាននៅសល់ គឺ ប្រព្រឹត្តទៅមិនបាន ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងឧបាយរលត់មិនមានសល់នៃធម្មជាតិនោះ ទើបត្រាស់ថា **នាម និងរូប តែងរលត់ឥតមានសេសសល់ក្នុងធម្មជាតិនុ៎ះ** ដូច្នេះ ។

បទថា **វិញ្ញាណ** គឺ វិញ្ញាណខាងដើមខ្លះ វិញ្ញាណដែលតាក់តែងខ្លះ ។ ពិតណាស់ ព្រោះវិញ្ញាណខាងដើមរលត់ នាម និងរូបនោះ រមែងរលត់មិនមានសេសសល់ក្នុងធម្មជាតិនេះ គឺថា រមែងដល់ការមិនមានបញ្ញត្តិ ដូចអណ្ដាតប្រទីបដែលរលត់ ដូច្នោះ ព្រោះមិនកើតឡើង និងរលត់ទៅ ដោយ

មិនមានសល់នៃវិញ្ញាណដែលតាក់តែងនាម និងរូប ទើបរលត់ដោយមិនកើតឡើង ដូចទ្រង់ត្រាស់ទុកថា ព្រោះរលត់វិញ្ញាណដែលតាក់តែងដោយសោតាបត្តិមគ្គញ្ញាណ នាម និងរូប ដែលគប្បីកើតក្នុងសង្សារវដ្ដ ដែលមិនមានខាងដើម និងទីបំផុត វៀរកពទាំង ៧ រមែងរលត់ដោយមិនមានសេសសល់ក្នុងធម្មជាតិនេះ ដូច្នេះ ។ ទាំងអស់គប្បីជ្រាបតាមន័យដែលទ្រង់ត្រាស់ទុកហើយក្នុងមហានិទ្ទេសនោះឯង ។ បទដ៏សេសក្នុងគ្រប់ៗ បទ ងាយទាំងអស់ ។

" ចប់ អដ្ឋកថា កេវដ្ដសូត្រទី ១១ "

# លោហិច្ចសូត្រ ទី ១២

**[១៥៣]** *លោហិច្ចសូត្រ មានបទផ្តើមថា* ***(ព្រះអានន្ទត្ថេរ)*** *ខ្ញុំបាន ស្តាប់មកហើយយ៉ាងនេះ ....... ក្នុងដែនកោសល ។*

*តទៅនេះ ជាការអធិប្បាយបទ ដែលលំបាកក្នុងលោហិច្ចសូត្រនោះ ពាក្យថា* ***សាលវតិកា*** *ជាឈ្មោះរបស់ស្រុកនោះ ។ បានឮមកថា ស្រុកនោះ ឡោមព័ទ្ធដោយឈើសាលៈ ដុះជាជួរទៅតាមលំដាប់ ដូចឡោមព័ទ្ធជារបង ព្រោះដូច្នោះទើបហៅថា ស្រុកសាលាតិកា ។ បទថា* ***លោហិច្ចៈ*** *ជាឈ្មោះ ព្រាហ្មណ៍នោះ ។*

**[១៥៤]** *បទថា* ***លាមក*** *គឺ ឈ្មោះថា លាមក ព្រោះវៀរចាកការ អនុគ្រោះអ្នកដទៃ ។ តែមិនមែនឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិ ណាមួយ ។ បទថា* ***កើតហើយ*** *គឺ បង្កើតហើយ បានដល់ មិនមែនត្រឹមតែកើតក្នុងចិត្ត តែម្យ៉ាងប៉ុណ្ណោះ ។ ន័យថា លោហិច្ចព្រាហ្មណ៍នោះ និយាយយ៉ាងនោះ សូម្បីត្រង់កណ្តាលបរិស័ទ តាមអំណាចរបស់ចិត្ត ។ បទទាំងឡាយថា* ***ព្រោះអ្នកដទៃ នឹងធ្វើដល់អ្នកដទៃបាន*** *ដូច្នេះ អធិប្បាយថា អ្នកដទៃនឹង*

និយាយថា អ្នកដែលត្រូវគេទូន្មាននឹងធ្វើអ្វី ដល់អ្នកទូន្មាននោះបាន ខ្លួនឯង នុំះឯង គួរសក្ការៈ គោរពកុសលធម៌ដែលខ្លួនបានហើយ ។

[១៥៥-១៥៦] ពាក្យថា **លោហិច្ចព្រាហ្មណ៍ ហៅជាងកោរកាត់**១ **ឈ្មោះភេសិកា** មានសេចក្តីថា លោហិច្ចព្រាហ្មណ៍ ហៅជាងកោរកាត់ ដែល បានឈ្មោះជាឥត្ថីលិង្គយ៉ាងនេះថា **ភេសិកា** ន័យថា គេជ្រាបដល់ការស្តេចមក របស់ព្រះមានព្រះភាគ ហើយគិតថា ការដែលយើងនឹងទៅគាល់ព្រះសម្ពុទ្ធ ដែលប្រថាប់នឹងជាការៈ តែយើងអារាធនាឲ្យស្តេចមកកាន់ផ្ទះ ហើយចូល គាល់ និងនឹងថ្វាយអាគន្តុកភិក្ខាតាមកម្លាំង ព្រោះដូច្នោះ លោហិច្ចព្រាហ្មណ៍ ទើបហៅ **ភេសិកា** ជាងកោរកាត់នោះមក ។

[១៥៧] បទថា **តាមទៅខាងក្រោយ** សេចក្តីថា ភេសិកាដើរតាម ពីខាងក្រោយព្រះមានព្រះភាគ ដើម្បីសប្បាយក្នុងការទូលសន្ទនា ។ បទថា **សូមទ្រង់យកចេញ** គឺ ភេសិកាក្រាបទូលព្រះដ៏មានព្រះភាគថា សូមព្រះដ៏- មានព្រះភាគទ្រង់យកចេញឲ្យផុត គឺ កម្ចាត់អំពីការឃើញដ៏លាមក ន័យថា ភេសិកានេះ ជាឧបាសក ជាមិត្រសំឡាញ់របស់លោហិច្ចព្រាហ្មណ៍ ព្រោះ

---

១-បិដក ប្រែថា : អ្នកដូតទឹក

ដូច្នោះ ទើបក្រាបទូលយ៉ាងនោះ ព្រោះប្រាថ្នាប្រយោជន៍ដល់លោហិច្ច-ព្រាហ្មណ៍ ។ ក្នុងបទថា **មិនមានអ្វី រោសិកា** នេះ ព្រះដ៏មានព្រះភាគទ្រង់បន្ទឺព្រះសូរសៀងដោយព្រះតម្រាស់ដំបូង ទ្រង់បន្ទឺព្រះសូរសៀងដដែលទៀតដោយព្រះតម្រាស់ទីពីរ ។ ក្នុងបទនេះ គប្បីជ្រាបអធិប្បាយដូច្នេះ ព្រះមាន-ព្រះភាគកាលនឹងទ្រង់សម្ដែងសេចក្ដីនេះថា ម្នាលរោសិកា តថាគតធ្វើទុក្кរ-កិរិយាច្រើនយ៉ាង និងបំពេញបារមីរហូតដល់អស់បួនអសង្ខេយ្យ និងសែនកប្ប ក៏ដើម្បីប្រយោជន៍នេះឯង តថាគតដឹងច្បាស់ដោយសព្វញ្ញុតញ្ញាណក៏ដើម្បីប្រយោជន៍នេះឯង ការកម្ចាត់សេចក្ដីឃើញលាមករបស់លោហិច្ច-ព្រាហ្មណ៍មិនមែនជារឿងធ្ងន់របស់តថាគត ដូច្នេះ ឈ្មោះថា ទ្រង់បន្ទឺព្រះសូរ-សៀងដោយព្រះតម្រាស់ដំបូង ។ និងកាលនឹងទ្រង់សម្ដែងសេចក្ដីនេះថា ម្នាលរោសិកា ការមកក្ដី ការអង្គុយក្ដី ការសន្ទនាប្រាស្រ័យក្ដី ក្នុងសម្នាក់របស់លោហិច្ចព្រាហ្មណ៍ ទាំងអស់នេះចូរលើកទុកសិនចុះ សូម្បីថា បុគ្គលដូចលោហិច្ចព្រាហ្មណ៍ មានសេចក្ដីសង្ស័យក្នុងបញ្ហាទាំងសែនប្រការ តថាគតក៏មានកម្លាំងល្មមនឹងបន្ទោបង់សេចក្ដីសង្ស័យបាន តែក្នុងការបន្ទោបង់ការឃើញដ៏លាមក របស់លោហិច្ចព្រាហ្មណ៍ត្រឹមតែម្នាក់ ដូចម្ដេច ? នឹងជារឿង

*ធ្វន់របស់តថាគត ដូច្នេះ ទើបទ្រង់បន្ទឹព្រះសូរសៀងដដែល ដោយព្រះតម្រាស់ទីពីរ ។*

# រឿងលោហិច្ចព្រាហ្មណ៍

[១៥៨] បទថា **ផលប្រយោជន៍ដែលកើតឡើង** បានដល់ ការកើតឡើងនៃបច្ច័យ គឺ ការកើតឡើងនៃភោគទ្រព្យ អធិប្បាយថា ទ្រព្យ និងស្រូវដែលកើតឡើងពីផលប្រយោជន៍នោះ ។ បទថា **អ្នកចូលទៅអាស្រ័យការចិញ្ចឹមជីវិត** គឺ ជនទាំងឡាយ មានញាតិ បរិវារ ទាសៈ និងកម្មករជាដើម អាស្រ័យគេចិញ្ចឹមជីវិត ។ បទថា **អ្នកធ្វើអន្តរាយ** គឺ អ្នកធ្វើអន្តរាយដល់លោក ។ ពាក្យថា **ប្រយោជន៍** ក្នុងបទថា **អនុគ្រោះដោយប្រយោជន៍** បានដល់ សេចក្ដីចម្រើន ។ បុគ្គលរមែងអាណិត ព្រោះដូច្នោះ ឈ្មោះថា អ្នកអនុគ្រោះ សេចក្ដីថា រមែងប្រាថ្នា លោកពោលអធិប្បាយថា ប្រាថ្នាសេចក្ដីចម្រើន ឬមិនប្រាថ្នា ។

បទថា **នរក ឬកំណើតតិរច្ឆាន** មានអធិប្បាយថា បើថា ការឃើញខុសនោះសម្បូរណ៍ គឺ មានពិតប្រាកដ រមែងកើតក្នុងនរកដោយចំណែកមួយ បើមិនមានពិតប្រាកដ រមែងកើតក្នុងកំណើតតិរច្ឆាន ។

[១៥៩] ឥឡូវនេះ ព្រោះព្រះដ៏មានព្រះភាគ មានព្រះបំណងនឹងឲ្យ

ព្រាហ្មណ៍កើតសេចក្តីតក់ស្លុតក្រៃលែងឡើង ដូចជាសត្វទាំងឡាយតក់ស្លុតដោយអន្តរាយ ព្រោះលាភរបស់ខ្លួនឯង មិនមែនតក់ស្លុតដោយអន្តរាយព្រោះលាភរបស់អ្នកដទៃ ដូច្នោះ ទើបត្រាស់រឿងកើតឡើងជាលើកទីពីរថា **ម្នាលលោហិច្ចៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច** ដូច្នេះ ។

[១៦០-១៦១] បទថា **កុលបុត្តទាំងឡាយពួកនេះ** បានដល់ កុលបុត្រទាំងនេះ ស្តាប់ព្រះធម៌ទេសនារបស់ព្រះតថាគត ហើយមិនអាចឈានចុះកាន់អរិយភូមិបាន ។ បទថា **គតិដែលជាទិព្វ** រូបស័ព្ទជាបឋមាវិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ប្រែថា គតិដែលជាទិព្វ ។ មួយទៀត បទថា **គតិដែលជាទិព្វនេះ** ជាឈ្មោះរបស់ទេវលោក ៦ ជាន់ ។ បទថា **កុលបុត្តទាំងឡាយ រមែងទំនុកបម្រុង** អធិប្បាយថា កុលបុត្រទាំងឡាយបំពេញបដិបទា ដើម្បីទៅកាន់ទេវលោក ឲ្យទាន រក្សាសីល ធ្វើការបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម ចម្រើនភាវនា ឈ្មោះថា រមែងបរិហារ រមែងអប់រំ គឺថា រមែងយល់ដល់ការមិនទៀង បទថា **ដើម្បីកើតក្នុងភពដែលជាទិព្វ** អធិប្បាយថា វិមានរបស់ទេវតាទាំងឡាយ ឈ្មោះថា ភពជាទិព្វ ដើម្បីនឹងទៅកើតក្នុងវិមានទាំងនោះ ។ម្យ៉ាងទៀត បទថា **គតិដែលជាទិព្វ** សំដៅដល់បុណ្យ

ពិសេស មានទានជាដើម ។ បទថា **គតិដែលជាទិព្វ** អធិប្បាយថា ភព ទាំងឡាយជាវិបាកខន្ធក្នុងទេវលោក កុលបុត្រទាំងឡាយធ្វើបុណ្យដើម្បីកើត ក្នុងភពទាំងនោះ ។ បទថា **ធ្វើអន្តរាយដល់ជនទាំងនោះ** គឺ ធ្វើអន្តរាយ ដល់មគ្គសម្បត្តិ ផលសម្បត្តិ និងសេចក្តីពិសេសនៃភពដែលជាទិព្វរបស់ ជនទាំងនោះ ។

## ការចោទបីប្រការ

[១៦២] ព្រះដ៏មានព្រះភាគ កាលទ្រង់ទម្លាយមានះរបស់ព្រាហ្មណ៍ដែលឡើងទៅដរាបដល់កវគ្គព្រហ្ម ដោយវិធីឧបមាដោយមិនកំណត់ ហើយទ្រង់សម្ដែងដល់សាស្ដា ៣ ពួក អ្នកគួរចោទប្រកាន់ ទើបត្រាស់ព្រះតម្រាស់មានជាអាទិថា ម្នាលលោហិច្ចៈ សាស្ដា ទាំង ៣ ពួកនេះ ។

បទថា **ការចោទនោះ** គឺ ការចោទប្រកាន់របស់អ្នកចោទប្រកាន់សាស្ដាទាំង ៣ ពួកនោះ ។ បទថា **មិនចូលទៅដើម្បីដឹង** គឺ មិនចូលទៅតាំងចិត្តដើម្បីដឹងជុំវិញ គឺ ដើម្បីប្រយោជន៍ដល់ការដឹងទូទៅ ។

បទថា **ចៀសវាង** អធិប្បាយថា មិនធ្វើតាមពាក្យប្រៀនប្រដៅរបស់សាសនានោះគ្រប់វេលា ប្រព្រឹត្តគេចចេញចាកពាក្យទូន្មាននោះ ។ បទថា **គប្បីក្រោកចូលទៅរកស្ត្រីដែលកំពុងថយចេញ** គឺ ចូលទៅរកអ្នកដែលថយចេញ ត្រូវការស្ត្រីដែលគេមិនត្រូវការ អធិប្បាយថា ស្ត្រីម្នាក់ដែលមិនប្រាថ្នារួមសំវាសជាមួយ ក៏នៅត្រូវការ ។ បទថា **បុរសគប្បីឱបស្ត្រីអំពីខាងក្រោយ** អធិប្បាយថា បុរសទៅពីខាងក្រោយ ហើយក្រសោបស្ត្រីអ្នកមិនប្រាថ្នាទោះបីឃើញឈរបែរខ្នងក៏ដោយ ។ បទថា **សេចក្ដីឧបមេយ្យនេះ ដូច្នោះ**

អធិប្បាយថា កាលសាស្តានេះគិតថា ទាំងនេះជាសាវករបស់យើង ហើយទូន្មានសាវកដែលប្រព្រឹត្តគេចចេញពីពាក្យទូន្មានដោយសេចក្តីលោភ យើងទើបពោលធម៌ គឺ សេចក្តីលោភនេះថា មានការឧបមេយ្យដូច្នោះ សាស្តានោះ គួរត្រូវចោទប្រកាន់ថា លោកបានដូចជាបុរសដែលរុកចូលទៅរកស្ត្រីដែលកំពុងគេចចេញ ដូចបុរសគប្បីឱបស្ត្រីអំពីក្រោយខ្នងដោយធម៌ គឺ សេចក្តីលោភណា ធម៌ គឺ សេចក្តីលោភរបស់អ្នកនោះ ក៏យ៉ាងនេះ ដោយប្រការដូច្នេះ ។ ពាក្យដែលថា **ព្រោះអ្នកដទៃនឹងធ្វើអ្វីដល់អ្នកដទៃបាន** មានអធិប្បាយថា សាស្តារមែងគួរត្រូវចោទប្រកាន់ថា លោកទូន្មានអ្នកដទៃដោយធម៌ណា លោកចូរញ៉ាំងខ្លួនឲ្យដល់ព្រមក្នុងធម៌នោះជាមុន គឺ លោកចូរធ្វើខ្លួនឯងឲ្យត្រង់ ព្រោះបុគ្គលដទៃ ដូចម្តេចនឹងធ្វើអ្វីឲ្យបុគ្គលដទៃបាន ។

[១៦៣] បទថា **ដែលគេគប្បីទំនុកបម្រុង** អធិប្បាយថា គួរដកស្មៅដែលទម្លាយស្រូវ ហើយធ្វើឲ្យរៀបរយ ។

[១៦៤] សេចក្តីនៃការចោទប្រកាន់លើកទី ៣ ថា **អ្នកដទៃនឹងធ្វើអ្វីដល់អ្នកដទៃបាន** សំដៅសេចក្តីថា បុគ្គលដទៃដែលត្រូវទូន្មានតាំងពីវេលាដែលមិនទទួលពាក្យទូន្មាន នឹងធ្វើអ្វីដល់បុគ្គលដទៃ គឺ បុគ្គលទូន្មានបាន

អធិប្បាយថា សាស្តានោះ គួរត្រូវចោទប្រកាន់យ៉ាងនេះថា ខ្លួនទុំឯងគួរដល់កាលជាអ្នកខ្វល់ខ្វាយតិច ទើបគួររាប់អាន បូជាធម៌ដែលខ្លួនដឹងច្បាស់ហេតុហើយមិនមែនឬ ។

## សាស្តាមិនគួរចោទ

**[១៦៥-១៦៦]** បទថា **មិនគួរចោទ** អធិប្បាយថា ព្រោះសាស្តានេះ តាំងខ្លួនទុកក្នុងសេចក្តីសមរម្យហើយជាមុន ទើបសម្តែងធម៌ដល់សាវក និងសាវករបស់គេជាអ្នកជឿ ស្តាប់ បដិបត្តិតាមពាក្យទូន្មាន រមែងសម្រេចគុណវិសេសដ៏ធំក្រៃលែង ដូច្នោះ គេទើបមិនគួរចោទប្រកាន់ ។

បទថា **ធ្លាក់ទៅកាន់ជ្រោះ គឺ នរក** សេចក្តីថា ព្រោះយើងប្រកាន់ទិដ្ឋិលាមក យើងទើបធ្លាក់ទៅកាន់ជ្រោះ គឺ នរក ។ បទថា **ព្រះមានព្រះភាគទ្រង់លើកយើងដាក់លើគោក** សេចក្តីថា លោហិច្ចព្រាហ្មណ៍ពោលថា យើងដែលព្រះដ៏មានព្រះភាគទ្រង់កាត់ទិដ្ឋិលាមកឲ្យហើយ ទ្រង់លើកឡើងពីជ្រោះ គឺ អបាយ ដោយព្រះហស្ត គឺ ព្រះធម៌ទេសនា ហើយដាក់យើងទុកលើគោក គឺ ផ្លូវសួគ៌ ដូច្នេះ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានសេចក្តីងាយយល់ទាំងអស់ ដោយប្រការដូច្នេះ ។

" ចប់ អដ្ឋកថា លោហិច្ចសូត្រ ទី ១២ "

# អដ្ឋកថា តេវិជ្ជសូត្រទី ១៣

**[១៦៧]** *តេវិជ្ជសូត្រមានសេចក្តីចាប់ផ្តើមថា ។ល។ ក្នុងដែនកោសល ។ តទៅនេះនឹងពណ៌នាបទដែលលំបាកក្នុងព្រះសូត្រនោះ ។*

*បទថា មនសាកត ជាឈ្មោះរបស់ស្រុកនោះ ។ បទថា **ដោយផ្លូវទិសខាងជើងនៃស្រុកមនសាកតៈ** គឺ ទិសខាងជើង មិនឆ្ងាយអំពីស្រុកមនសាកតៈ ។ បទថា **ក្នុងព្រៃស្វាយ** គឺ ក្នុងពួកដើមស្វាយជំទង់ បានឮថា ភូមិភាគនោះគួររីករាយ ខាងក្រោម ក្រាលខ្សាច់ដូចគ្នានឹងផែនប្រាក់ ខាងលើជាព្រៃស្វាយ មានមែក និងស្លឹកក្រាស់ ដូចពិតានប្រក់ដោយកែវមណី ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងអម្ពវន ដែលមានសេចក្តីសុខកើតពីវិវេក សមគួរដល់ព្រះពុទ្ធទាំងឡាយ ។*

**[១៦៨-១៦៩]** *បទថា **ព្រាហ្មណ៍មហាសាលដែលគេដឹងទូទៅ** គឺ ជាអ្នកដែលគេដឹងទូទៅក្នុងតំបន់នោះៗ ព្រោះដល់ព្រមដោយគុណសម្បត្តិ មានកុលចារីតជាដើម ។ បទថា **វង្កី** ជាដើម ជាឈ្មោះរបស់ព្រាហ្មណ៍មហាសាលទាំងនោះ ។ បណ្តាព្រាហ្មណ៍មហាសាលទាំងនោះ វង្កីនៅស្រុក*

ឱបសាទៈ តារុក្ខៈនៅស្រុកឥច្ឆានង្គលៈ ។ បោក្ខរសាតិនៅឧក្កដ្ឋនគរ ជាណុស្សោណិនៅសាវត្ថី តោទេយ្យៈនៅតុទិគ្រាម ។ បទថា **ព្រាហ្មណ៍មហាសាលដទៃទៀត** សេចក្ដីថា ក៏បណ្ដាជនជាច្រើនពួកដទៃ មកពីទីនៅរៀងៗ ខ្លួន ហើយអាស្រ័យនៅក្នុងស្រុកមនសាកតនោះ ។ បានឮថា ព្រោះស្រុកមនសាកតគួរជាទីរីករាយ ព្រាហ្មណ៍ទាំងនោះ ទើបនាំគ្នាសាងផ្ទះជិតត្រើយទន្លេក្នុងស្រុកមនសាកតនោះ ធ្វើរបងព័ទ្ធជុំវិញ ហាមអ្នកដទៃចូលទៅ នាំគ្នាទៅនៅក្នុងទីនោះ តាមលំដាប់ ។

បទថា **វាសេដ្ឋមាណព និងភារទ្វាជមាណព** សេចក្ដីថា វាសេដ្ឋមាណពជាសិស្សរបស់បោក្ខរសាតិព្រាហ្មណ៍ ភារទ្វាជមាណពជាសិស្សរបស់តារុក្ខព្រាហ្មណ៍ ។ បានឮថា មាណពទាំងពីរនោះសម្បូរណ៍ដោយជាតិ សិក្សាចប់ត្រៃវេទហើយ ។ បទថា ជង្ឃវិហារ គឺ ដើរចុះឡើងឲ្យស្រួលជើង ដើម្បីបន្ទោបង់ការឈឺចុកចាប់ ព្រោះអង្គុយយូរពេកជាហេតុ ។ បានឮថា មាណពទាំងពីរនោះ អង្គុយទន្ទេញមន្តរហូតអស់កន្លះថ្ងៃ ពេលល្ងាចទើបក្រោក ឲ្យអ្នកកាន់របស់ក្រអូប ផ្កាឈើ ប្រេង និងសំពត់ស្អាត ដែលជាគ្រឿងប្រើសម្រាប់ងូតទឹក ហែហមដោយបរិវាររៀងៗ ខ្លួន ប្រាថ្នានឹងងូតទឹក

ទៅប្រាំងទន្លេ ដើរទៅដើរមក លើទួលខ្សាច់ពណ៌ដូចផែនប្រាក់ ។ ម្នាក់ដើរម្នាក់ទៀតដើរតាម ម្នាក់ទៀតក៏ដើរតាមម្នាក់ទៀត តគ្នាទៅ ដោយហេតុនោះលោកទើបពោលថា ដើរទៅតាមគ្នា ។

បទថា **ក្នុងផ្លូវ និងមិនមែនផ្លូវ** គឺ ក្នុងរឿងផ្លូវផង មិនមែនផ្លូវផង ។ អធិប្បាយថា មាណពទាំងពីរសន្ទនាគ្នាប្រារព្ធដល់រឿងផ្លូវ និងមិនមែនផ្លូវយ៉ាងនេះថា យើងនឹងបំពេញបដិបទាយ៉ាងណាហ្ន៎ ទើបនឹងអាចទៅកាន់ព្រហ្មលោកដែលជាសុខបាន ដោយផ្លូវណា ។ បទថា **ក្រសែផ្លូវដើរ** ជាវេវចនៈរបស់ផ្លូវត្រង់ ឬផ្លូវត្រង់នោះឯង ។ បុគ្គលរមែងដើរ គឺ រមែងមកដោយផ្លូវនោះ ព្រោះដូច្នោះ ផ្លូវនោះទើបឈ្មោះថា ក្រសែផ្លូវដើរ ។

បទថា **ជាផ្លូវនាំចេញ រមែងចេញ** គឺ កាលនាំចេញ រមែងនាំចេញទៅបាន អធិប្បាយថា កាលទឹងទៅ ក៏ទៅបាន ។

សួរថា ទៅណា ?

ឆ្លើយថា ដើម្បីឲ្យអ្នកបដិបត្តិតាមនោះនៅរួមជាមួយព្រហ្មបាន អធិ-ប្បាយថា អ្នកដែលទៅដើម្បីការនៅរួមនឹងព្រហ្ម ដើម្បីសេចក្តីប្រាកដក្នុងទីតែមួយ រមែងដើរតាមផ្លូវនោះ ។ បទថា យ្វាយំ កាត់បទជា យោ អយំ ។

បទថា **តារុក្ខព្រាហ្មណ៍ប្រាប់ទុ** គឺ ពោលទុក បានដល់ សម្តែងទុក ។ បទថា **បោក្ខរសាតិព្រាហ្មណ៍** គឺ វាសេដ្ឋមាណពអាងដល់អាចារ្យរបស់ខ្លួន ។ វាសេដ្ឋមាណពដើរអួតសរសើរវាទៈរបស់អាចារ្យខ្លួនតែម្យ៉ាង សូម្បីភារទ្វាជៈក៏ដើរសរសើរ... តែម្យ៉ាង ដូចគ្នា ។ ដោយហេតុនោះ លោកទើបពោលថា **វាសេដ្ឋមាណពមិនអាចឲ្យភារទ្វាជមាណពរីករាយបាន** ជាដើម ។

**[១៧០-១៧១]** លំដាប់នោះ វាសេដ្ឋមាណព គិតថា ពាក្យរបស់យើងសូម្បីទាំងពីរ មិនជាផ្លូវនាំចេញបានពិត ដែលឈ្មោះថា អ្នកច្លាតក្នុងផ្លូវក្នុងលោកនេះ ដូចជាព្រះគោតមដ៏ចម្រើនមិនមាន ព្រះគោតមដ៏ចម្រើនប្រថាប់នៅមិនឆ្ងាយ ព្រះអង្គនឹងកម្ចាត់សេចក្តីសង្ស័យរបស់យើងបាន ដូចឈ្នួញអង្គុយកាន់ជញ្ជីងថ្លឹងដូច្នោះ ហើយទើបប្រាប់សេចក្តីនោះដល់ ភារទ្វាជមាណពទាំងពីរនាក់ ក៏នាំគ្នាទៅក្រាបទូលពាក្យចំពោះព្រះមាន-ព្រះភាគជាម្ចាស់ ។ ដោយហេតុនោះ លោកទើបពោលថា គ្រានោះ វាសេដ្ឋមាណព ។ល។ ផ្លូវដែលលោកតារុក្ខព្រាហ្មណ៍ប្រាប់ទុក ជាត្រូវត្រង់ ដូច្នេះ ។

បទថា **បពិត្រព្រះគោតម ក្នុងសេចក្តីនេះ** គឺ ក្នុងរឿងផ្លូវ និងមិនមែនផ្លូវនេះ ។

ក្នុងបទថា **ការប្រកាន់ខុស ការពោលខុស** ជាដើម សេចក្តីថា ប្រកាន់ខុសកើតឡើងមុន ពោលខុសកើតឡើងខាងក្រោយ ។ សូម្បីទាំងពីរ ក៏មានវាទៈផ្សេងពីវាទៈរបស់បណ្ឌាចារ្យផ្សេងៗ ។ ក្នុងបទថា **ក៏បើដូច្នោះ ពួកអ្នកទីងប្រកាន់ខុស ពោលខុសគ្នាក្នុងប្រការណា** សេចក្តីថា ព្រះមាន-ព្រះភាគត្រាស់សួរថា សូម្បីអ្នកក៏លើកតម្កើងវាទៈអាចារ្យរបស់ខ្លួនប៉ុណ្ណោះ ដែលអះអាងបញ្ជាក់ថា នេះប៉ុណ្ណោះជាផ្លូវ , សូម្បីការទ្វាជមាណព ក៏លើក តម្កើងវាទៈអាចារ្យរបស់ខ្លួនដូចគ្នា សេចក្តីសង្ស័យរបស់ម្នាក់ រមែងមិនមាន ក្នុងម្នាក់ បើដូច្នោះ ពួកអ្នកប្រកាន់ផ្សេងគ្នាក្នុងរឿងអ្វី ។ បទថា **បពិត្រ ព្រះគោតមដ៏ចម្រើន ក្នុងផ្លូវ និងមិនមែនផ្លូវ** សេចក្តីថា បពិត្រព្រះគោតម ដ៏ចម្រើន ក្នុងផ្លូវ និងមិនមែនផ្លូវ អធិប្បាយថា ក្នុងផ្លូវត្រង់ និងមិនមែនផ្លូវ ត្រង់ ។

បានឮថា មាណពនោះ មិនពោលដល់ផ្លូវ សូម្បីរបស់ព្រាហ្មណ៍ម្នាក់ ថា មិនមែនផ្លូវ ក៏ផ្លូវអាចារ្យរបស់ខ្លួន ជាផ្លូវត្រង់យ៉ាងណា គេមិនទទួល ដឹងរបស់អ្នកដទៃដូច្នោះ ព្រោះដូច្នោះ កាលទីងសម្តែងសេចក្តីនោះ គេទើប ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ.... ដោយពិត

ជាដើម ។

បទថា សព្វានិ តានិ លោកពោលទុកដោយលិង្គវិបល្លាស (ខុសលិង្គ) អធិប្បាយថា សព្វេ តេ ដូច្នេះ ។ បទថា **ផ្លូវផ្សេងៗ ច្រើន** គឺ ៨ ផ្លូវ ឬ ១០ ផ្លូវ ។ បទថា **ផ្លូវផ្សេងៗ** គឺ ផ្លូវដែលមកពីស្រុក ទន្លេ ស្រះ និងស្រែជាដើម ជិតគ្នាច្រើនផ្លូវ ទាំងធំ និងតូច ដោយជាផ្លូវជើង និងផ្លូវរទេះជាដើម ហើយចូលស្រុក ។ បទថា **ម្នាលវាសេដ្ឋ អ្នកពោលថា ផ្លូវទាំងនោះរមែងនាំចេញឬ** សេចក្ដីថា ព្រះដ៏មានព្រះភាគ ឲ្យវាសេដ្ឋមាណពថ្លែងវាចា ៣ ដង ហើយឲ្យធ្វើបដិញ្ញាណ ។ ព្រោះហេតុណា ? ព្រោះពួកតិត្ថិយបដិញ្ញាណហើយ ខាងក្រោយកាលត្រូវសង្កត់សង្កិន នឹងមើលងាយ វាសេដ្ឋមាណពនឹងមិនអាចធ្វើយ៉ាងនោះបាន ។

**[១៧២]** បទថា តេវ តេវិជ្ជា បានដល់ ពួកព្រាហ្មណ៍ចប់ត្រៃវេទ ។ **វ** អក្សរ ត្រឹមតែជាអាគមសន្ធិ ។

**[១៧៣]** បទថា អន្ធវេណី ប្រែថា មនុស្សមានភ្នែកខ្វាក់ដើរជាជួរ អធិប្បាយថា មនុស្សខ្វាក់ភ្នែកម្នាក់ ចាប់ចុងឈើច្រត់ដែលមនុស្សភ្នែកល្អកាន់ មនុស្សដទៃៗ ក៏ចាប់មនុស្សខ្វាក់ភ្នែកតៗ គ្នាទៅ ដោយប្រការដូច្នេះ

មនុស្សខ្វាក់ភ្នែក ៥០-៦០ នាក់ ចាប់បន្តគ្នាទៅដោយលំដាប់ ហៅថា ជួរ មនុស្សភ្នែកខ្វាក់ ។ បទថា **គោងគ្នានិងគ្នា** គឺ តោងខ្នងគ្នានិងគ្នា ។ អធិប្បាយថា ត្រូវអ្នកភ្នែកល្អកាន់ឈើច្រត់គេចចេញទៅ ។ មានរឿងថា អ្នកលេងម្នាក់ ឃើញពួកអ្នកភ្នែកខ្វាក់ ទើបឲ្យពួកអ្នកខ្វាក់ភ្នែកកើតសេចក្តីឧស្សាហ៍ ដោយនិយាយថា នៅស្រុកឯណោះ រករបស់ទំពារ របស់ស៊ីបានងាយ កាលពួកអ្នកខ្វាក់ភ្នែកនិយាយថា បាទ ! នាយ បើដូច្នោះ សូមលោកនាំពួកយើងទៅកាន់ស្រុកនោះ ពួកយើងនឹងឲ្យវត្ថុនេះដល់លោក អ្នកលេងទទួលថ្លៃឈ្នួលហើយ ទើបចុះចេញពីផ្លូវក្នុងចន្លោះផ្លូវ ដើរវិលជុំវិញគល់ឈើធំ ទើបឲ្យពួកមនុស្សខ្វាក់ភ្នែកចាប់ជាយសំពត់គ្នា តាមលំដាប់មុនក្រោយ ហើយប្រាប់ថា ខ្ញុំមានធុរៈ ពួកលោកចូរទៅមុន ហើយគេចចេញទៅ ។ ពួកមនុស្សខ្វាក់ភ្នែក សូម្បីទៅរហូតដល់អស់មួយថ្ងៃ ក៏មិនជួបផ្លូវ នាំគ្នាទួញយំថា មនុស្សភ្នែកល្អទៅណា ផ្លូវនៅទីណា កាលមិនជួបផ្លូវ ក៏ស្លាប់ទាំងអស់គ្នាក្នុងទីនោះឯង ។ លោកពោលថា តោងខ្នងគ្នានិងគ្នា សំដៅដល់ពួកអ្នកសូមទានទាំងនោះ ។

បទថា **សូម្បីអ្នកមុខ ក៏មិនឃើញ** គឺ បណ្តាព្រាហ្មណ៍ ១០ នាក់

សូម្បីតែម្នាក់ក៏មើលមិនឃើញ ។ បទថា **សូម្បីអ្នកកណ្តាល ក៏មិនឃើញ** មានន័យថា បណ្តាអាចារ្យ និងអាចារ្យ ក្នុងកណ្តាល សូម្បីម្នាក់ក៏មើលមិនឃើញ ។ បទថា **សូម្បីអ្នកក្រោយ ក៏មិនឃើញ** មានន័យថា បណ្តាព្រាហ្មណ៍អ្នកចេះចប់ត្រៃវេទក្នុង កាលឥឡូវនេះ សូម្បីតែម្នាក់ក៏មិនឃើញ ។ បទថា ទស្សនាយេវ ប្រែថា គួរសើចចំអកដោយពិត ។ បទថា ធាមកំយេវ ប្រែថា ថោកទាបដោយពិត ។ ភាសិតនោះ ជាពាក្យទទេ ព្រោះមិនមានប្រយោជន៍ ។ ជាពាក្យសោះសូន្យ ព្រោះជាពាក្យមិនគួរឲ្យជឿបាន ។

**[១៧៤-១៧៧]** ឥឡូវនេះ ព្រះដ៏មានព្រះភាគ ដើម្បីទ្រង់សម្តែងថា ព្រហ្ម ដែលព្រាហ្មណ៍អ្នកចប់ត្រៃវេទមិនធ្លាប់ឃើញ លើកទុកសិន ព្រាហ្មណ៍អ្នកចប់ត្រៃវេទ រមែងមើលឃើញព្រះចន្ទ និងព្រះអាទិត្យណាបាន តែមិនអាចនឹងសម្តែងផ្លូវ ដើម្បីការនៅរួមនឹងព្រះច័ន្ទ ព្រះអាទិត្យនោះបាន ទើបត្រាស់ពាក្យជាដើមថា **តំ កឹ មញ្ញសិ វាសេដ្ឋ** អ្នកសម្គាល់ហេតុនោះដូចម្តេច ។ បណ្តាបទទាំងនោះ បទថា **ព្រះច័ន្ទ និងព្រះអាទិត្យរះឡើងកាលណា** គឺ រះឡើងក្នុងកាលណា ។ បទថា **លិចទៅក្នុងកាលណា** គឺ ដល់ការលេត់ទៅក្នុងកាលណា ។ អធិប្បាយថា ជនទាំងឡាយ រមែងឃើញក្នុងវេលារះឡើង ក្នុង

វេលាលិចទៅ ។ បទថា **ព្រាហ្មណ៍ទាំងឡាយរមែងអង្វរ** គឺ អង្វរយ៉ាងនេះថា សូមព្រះច័ន្ទ ដ៏ចម្រើនចូររះឡើង សូមព្រះអាទិត្យដ៏ចម្រើន ចូររះឡើង ។ បទថា **រមែងរីករាយ** អធិប្បាយថា ជនទាំងឡាយរមែងពោលសរសើរថា ព្រះច័ន្ទសុភាព ព្រះអាទិត្យរៀបរយ ព្រះច័ន្ទ មានរស្មីជាដើម ។ បទថា **ប្រណមដៃ** គឺ ផ្គងដៃ ។

បទថា **មនស្ការ** គឺ ពោលថា **នមោ នមោ** ដូច្នេះ ។ ពាក្យថា យំ ក្នុងបទថា យំ បស្សន្តិ ត្រឹមតែនិបាត ។ ក្នុងបទថា **ក៏នឹងពោលសួរគ្នាធ្វើអ្វី** គប្បីឃើញសេចក្ដីយ៉ាងនេះថា ក្នុងទីនេះ គួរនិយាយគ្នារឿងអ្វី បានព្ថា ព្រាហ្មណ៍អ្នកបានត្រៃវេទ មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែកខ្លួនទេ ។

## ឧបមាអំពីស្ទឹងអចិរវតី

[១៧៨] បទថា **ស្មើច្រាំង** បានដល់ ពេញដល់ច្រាំង បទថា **ក្អែកផឹកបាន** អធិប្បាយថា ក្អែកឈរនៅលើច្រាំងណាមួយ ក៏អាចផឹកស៊ីបាន ។ បទថា **ប្រាថ្នានឹងឆ្លងត្រើយ** គឺ ប្រាថ្នានឹងឆ្លងស្ទឹងទៅដល់ត្រើយឯណោះ បទថា អវ្ហយេ្យ គឺ ហៅ ។ នែ៎! ត្រើយឯណោះ អ្នកចូរមកត្រើយនេះ អធិប្បាយថា គេស្រែកហៅថា ម្នាលត្រើយឯណោះ អ្នកចូរមកត្រើយនេះ កាលបើដូច្នោះ អ្នកនឹងនាំយើងឆ្លងទៅបានដោយរហ័ស យើងមានកិច្ចដែលនឹងត្រូវធ្វើឆាប់ៗ ។ ក្នុងបទថា **ធម៌ទាំងឡាយណា ដែលធ្វើឲ្យព្រាហ្មណ៍** នេះ គប្បីជ្រាបថា ធម៌ដែលធ្វើឲ្យជាព្រាហ្មណ៍ បានដល់ សីល ៥ សីល ១០ កុសលកម្មបថ ១០ ។ ធម៌ដែលផ្ទុយពីនោះ មិនមែនធម៌ដែលធ្វើឲ្យជាព្រាហ្មណ៍ ។

បទថា ឥន្ទមវ្ហយាម កាត់បទជា ឥន្ទំ អវ្ហយាម យើងហៅរកព្រះ-អាទិត្យ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងដល់ពាក្យស្រែកហៅរបស់ព្រាហ្មណ៍មិនមានប្រយោជន៍ ដែលទ្រង់រុងរឿងដូចព្រះអាទិត្យក្នុងផ្ទៃមហាសមុទ្រ ទ្រង់ហែហមដោយព្រះភិក្ខុ ៥០០ រូប ប្រថាប់អង្គុយលើត្រើយស្ទឹងអចិរវតី កាល

នឹងទ្រង់នាំស៊ីងដទៃៗ មកប្រៀបធៀបទៀត ទើបត្រាស់ថា **ប្រៀបដូច** ជាដើម ។

[១៧៩] បទថា **កាមគុណទាំងឡាយ** អធិប្បាយថា ឈ្មោះថា **កាម** ព្រោះអត្ថថា គប្បីប្រាថ្នា ។

ឈ្មោះថា **គុណ** ព្រោះអត្ថថា **ចង្កៀក** ។ **គុណ** ស័ព្ទ មានសេចក្ដីថា **ជាន់** ក្នុងពុទ្ធវចននេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឃាដិពីរជាន់នៃសំពត់ថ្មី ។

**គុណ** ស័ព្ទ មានសេចក្ដីថា **លំដាប់** ក្នុងបទគាថានេះថា ៖

***កាលរមែងកន្លងទៅ រាត្រីរមែងកន្លងផុតទៅ លំដាប់នៃវ័យ***

***រមែងលះលំដាប់ទៅ ។***

**គុណ** ស័ព្ទ មានសេចក្ដីថា **អានិសង្ស** ក្នុងបទថា ទក្ខិណាគប្បីសង្ឃឹមបានអានិសង្សទាំងរយ ។ **គុណ** ស័ព្ទ មានសេចក្ដីថា **ជោតក្រង** ក្នុងបទនេះថា **ខ្សែធំ តូច** គួរធ្វើការជោតក្រងក្នុងមាល័យឲ្យច្រើន ។ ក្នុងទីនេះលោកប្រាថ្នាយកស័ព្ទនេះ ព្រោះដូច្នោះ ទើបពោលថា **គុណ** ស័ព្ទ ដោយអត្ថថា **ជោតក្រង** ។ បទថា **គប្បីដឹងដោយចក្ខុវិញ្ញាណ** គឺ គប្បីឃើញដោយចក្ខុវិញ្ញាណ ។ គប្បីជ្រាបសេចក្ដីសូម្បីក្នុងបទថា **សំឡេងដែល**

**គប្បីដឹងបានដោយត្រចៀក** ជាដើម ដោយឧបាយនោះ ។

បទថា **គួរប្រាថ្នា** សេចក្ដីថា កាមគុណ ៥ ទីងជាវត្ថុដែលគួរស្វែងរក ឬមិនគួរក៏ដោយ អធិប្បាយថា រមែងជាអារម្មណ៍ដែលមិនគួរប្រាថ្នា បទថា កន្តា បានដល់ ជាទីតាំងនៃសេចក្ដីប្រាថ្នា ។ បទថា មនាបា បានដល់ ជាទីចម្រើនចិត្ត ។ បទថា បិយរូបា បានដល់ មានសេចក្ដីស្រឡាញ់ជាប្រក្រតី ។ បទថា **ជាប់ដោយកាម** បានដល់ ចូលទៅទាក់ទងដោយកាមធ្វើឲ្យជាអារម្មណ៍ ហើយកើតឡើង ។ បទថា **គួរត្រេកត្រអាល** គឺ ពេញចិត្ត អធិប្បាយថា ជាហេតុកើតនៃរាគៈ ។ បទថា **តម្រេក** គឺ ត្រូវតម្រេកគ្របសង្កត់ ។ បទថា **ជាប់ជក់នៅ** គឺ ត្រូវតណ្ហាមានប្រមាណក្រៃលែងដែលដល់អាការគ្របសង្កត់ ។ បទថា **លិចលង់** គឺ លិចចុះ ធ្លាក់ចុះ គឺ ជាអ្នកដល់ការធ្លាក់ចុះថា នេះជាសារៈ ដូច្នេះ ។ បទថា អនាទីនវទស្សាវិនោ បានដល់ មិនសម្លឹងឃើញទោស ។ បទថា និស្សរណំ ក្នុងពាក្យថា អនិស្សរណាប្បញ្ញា នេះ បានដល់ បញ្ញាដែលវៀរចាកបញ្ញាជាគ្រឿងកំណត់ដឹង អធិប្បាយថា បញ្ញាវៀរចាកការបរិភោគដោយការពិចារណា ។

[១៨០] ក្នុងពាក្យថា អាវរណា ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅ

នេះ ៖

កាមគុណ ឈ្មោះថា អាវរណា ព្រោះជាគ្រឿងឃឹតឃូរ ។

ឈ្មោះថា នីវារណា ព្រោះជាគ្រឿងរារាំង ។

ឈ្មោះថា ឱនាហនា ព្រោះជាគ្រឿងចងរឹត ។

កាមគុណ ឈ្មោះថា បរិយោហនា ព្រោះជាគ្រឿងរួបរឹត ។

សេចក្តីពិស្តាររបស់នីវរណៈ មានកាមឆន្ទៈជាដើម គប្បីស្វែងរកពីវិសុទ្ធិមគ្គ ។

**[១៨១]** បទថា **ឃឹតឃូរ រារាំង ចងរឹត រួបរឹត** លោកពោលទុកដោយអំណាចនៃកាមគុណ មានគ្រឿងឃឹតឃូរជាដើម ។

**[១៨២]** បទថា សបរិគ្គហា លោកពោលដល់ ការជាប់ជំពាក់ជាមួយស្ត្រី ។ សូម្បីក្នុងបទមានជាអាទិថា **បពិត្រព្រះគោតមដ៏ចម្រើន** ព្រាហ្មណ៍មិនមានគ្រឿងជាប់ជំពាក់ជាមួយស្ត្រី ដូច្នេះ លោកពោលការមិនជាប់ជំពាក់ជាមួយស្ត្រី ព្រោះមិនមានកាមច្ឆន្ទៈ ឈ្មោះថា មិនមានពៀរ ដោយចិត្តគិតចងពៀរនឹងនរណាៗ ព្រោះមិនមានព្យាបាទ ។ ឈ្មោះថា មិនមានព្យាបាទដោយការព្យាបាទ ពោលគឺ ការឈឺចាប់ផ្លូវចិត្ត ព្រោះមិនមានថីនមិទ្ធៈ ។

ឈ្មោះថា មិនមានចិត្តសៅហ្មងដោយគ្រឿងសៅហ្មង មានឧទ្ធច្ចកុក្កុច្ចៈជាដើម , ព្រោះមិនមានឧទ្ធច្ចកុក្កុច្ចៈ ឈ្មោះថា អ្នកមានចិត្តបរិសុទ្ធិដោយល្អ ។ ឈ្មោះថា **វសវត្តី** ព្រោះធ្វើចិត្តឲ្យនៅក្នុងអំណាច ព្រោះហេតុមិនមានវិចិកិច្ឆា និងមិនដូចជាព្រាហ្មណ៍អ្នកធ្លាក់នៅក្នុងអំណាចនៃចិត្ត គឺ ប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត ។

[១៨៣] បទថា **ក៏ក្នុងលោកនេះឯង** គឺ ក្នុងផ្លូវនៃព្រហ្មលោកនេះ ។ បទថា **លិចចុះហើយ** គឺ ចូលទៅរកវត្ថុមិនមែនផ្លូវ ថាជាផ្លូវ ។ បទថា **កំពុងលិច** គឺ លិចចុះទៅ ដូចបុគ្គលជាន់ភក់ ដោយសម្គាល់ថា ជាដីរាបស្មើ ។ បទថា **លិចចុះហើយ រមែងដល់សេចក្ដីលំបាក** អធិប្បាយថា កាលលិច ដូចលិចក្នុងភក់យ៉ាងនេះ រមែងដល់សេចក្ដីលំបាក គឺ ការបាក់បែកនៃអវយវៈតូចធំ ។ បទថា **សម្គាល់ថាឆ្លងបានងាយ** អធិប្បាយថា ជនទាំងឡាយគិតថា យើងនឹងឆ្លងដោយសម្គាល់ថា ស្ទឹងមានទឹកពេញស្មើច្រាំងក្អែកផឹកបាន ទើបព្យាយាមទាំងដៃទាំងជើងសម្គាល់ថា ឆ្លងបានងាយ ព្រោះបញ្ឆោតភ្នែក ដូចថ្ងៃបណ្ដើរកូន ។ ព្រោះដូច្នោះ គេទាំងឡាយរមែងដល់សេចក្ដីលំបាក ទីងបាក់បែកក្នុងអបាយ ដូចដៃ និងជើងជាដើម ដល់សេចក្ដី

លំបាកដោយការបាក់បែកដូច្នោះ គឺ មិនបានសេចក្តីសុខ ឬសេចក្តីសប្បាយក្នុងលោកនេះឡើយ ។ បទថា តស្មា តេវិជ្ជានំ ព្រាហ្មណានំ សេចក្តីថា ព្រោះហេតុនោះ នេះជាបាវចនៈ គឺ ត្រៃវេទដែលសម្តែងដល់ផ្លូវ ដើម្បីសេចក្តីនៅរួមជាមួយព្រហ្ម របស់ព្រាហ្មណ៍ទាំងឡាយអ្នកចប់ត្រៃវេទ ។

បទថា តេវិជ្ជាឥរិណំ បានដល់ ព្រៃ គឺ ត្រៃវិជ្ជា ក៏ព្រៃធំដែលមិនមានស្រុកលោកពោលថា **ព្រៃ** ។ បទថា តេវិជ្ជាវិវនំ បានដល់ ព្រៃដែលមិនមានទឹក ហ៊ុំព័ទ្ធដោយដើមឈើដែលមានផ្លែផ្កាបរិភោគមិនបាន ។ លោកពោល ព្រះដ៏មានព្រះភាគត្រាស់ថា គេហៅថា ព្រៃធំ គឺ ត្រៃវេទ ដូច្នេះក៏មាន ទ្រង់សំដៅដល់ព្រៃដែលនរណាៗ មិនអាចនឹងរកផ្លូវចូលបាន ។ បទថា **សេចក្តីវិនាសត្រៃវេទ** ពាក្យនេះ ដូចគ្នានឹងសេចក្តីវិនាស ៥ យ៉ាង របស់ត្រៃវេទ ។ លោកសម្តែងថា អ្នកចប់ត្រៃវេទ រមែងមិនមានសេចក្តីសុខ ព្រោះអាស្រ័យពាក្យទូន្មានជាគោល បានដល់ ត្រៃវេទ ដូចអ្នកដែលដល់សេចក្តីវិនាសនៃញាតិ រោគ ភោគៈ ទិដ្ឋិ និងសីល រមែងរកសេចក្តីសុខមិនបាន ដូច្នោះ ។

[១៨៤] បទថា **កើតហើយ ធំធាត់ហើយ** បានដល់ កើត និងធំធាត់ ។

អធិប្បាយថា ព្រោះផ្លូវទៅស្រុកជិតខាងរបស់អ្នកដែលកើតក្នុងកន្លែងមួយហើយ ទៅធំធាត់ក្នុងកន្លែងដទៃ មិនប្រចក្សដោយប្រការទាំងពួង ដូច្នោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា កើតហើយ ធំធាត់ហើយ ដូច្នេះ ។ អ្នកដែលកើតហើយ ធំធាត់ហើយ តែចាកចេញទៅយូរ រមែងមិនប្រចក្សដោយប្រការទាំងពួង ដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា ចេញទៅហើយក្នុងពេលក្លាមៗនោះ ។ អធិប្បាយថា ចេញទៅក្នុងខណៈនោះឯង ។ បទថា **ភាពជាអ្នកយឺតយូរ** គឺ យឺតយូរដោយសង្ស័យថា ផ្លូវនេះ ឬមិនមែនហ្ន៎ ។ បទថា **ភាពជាអ្នកអឹមអៀន** បានដល់ ការដល់ភាពជាអ្នកអល់អែក ដូចនរណាម្នាក់កាលត្រូវសួរក្លាមៗ ដល់រឿងដែលកើតឡើងយ៉ាងល្អិត គេដល់ភាពជាអ្នកមានសរីរៈរឹង ដូច្នោះ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដល់ព្រះសព្វ-ញ្ញុតញ្ញាណមិនត្រូវជំទាស់ ដោយបទថា **មិនយឺតយូរ មិនអល់អែក** ដូច្នេះ ។ លោកអធិប្បាយថា ការជំទាស់ញាណរបស់បុរសនោះ គប្បីមានបាន ដោយអំណាចត្រូវមារបណ្តាលចិត្តជាដើម ដោយហេតុនោះ បុរសនោះគប្បីយឺតយូរ ឬអឹមអៀម តែព្រះសព្វញ្ញុតញ្ញាណមិនត្រូវជំទាស់ នរណាៗ មិនអាចធ្វើអន្តរាយចំពោះព្រះសព្វញ្ញុតញ្ញាណនោះបាន ។

[១៨៥] បទថា ឧល្លុម្បតុ ភវំ គោតមោ បានដល់ សូមព្រះគោតមដ៏ចម្រើនមេត្តាលើកឡើង ។

បទថា ព្រាហ្មណិំ បជំ សំដៅដល់ ក្មេងរបស់ព្រាហ្មណ៍ ។ អធិប្បាយថា សូមព្រះគោតមដ៏ចម្រើន មេត្តាលើកព្រាហ្មណ៍ និងបុត្ររបស់ព្រាហ្មណ៍ឡើងអំពីផ្លូវអបាយ ហើយឲ្យតាំងនៅក្នុងផ្លូវព្រហ្មលោកចុះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគមានព្រះបំណងនឹងសម្តែងដល់ការឧប្បត្តិនៃព្រះពុទ្ធ ហើយទ្រង់សម្តែងផ្លូវទៅព្រហ្មលោក មានមេត្តាវិហារធម៌ជាដើម ព្រមដោយការបដិបត្តិជាខាងដើមដល់គេ ទើបត្រាស់ពាក្យមានជាអាទិថា ម្នាលវាសេដ្ឋៈ បើដូច្នោះ អ្នកចូរប្រុងស្តាប់ ។

បណ្តាបទទាំងនោះ បទថា **ព្រះតថាគតទ្រង់ឧប្បត្តិក្នុងលោកនេះ ជាដើម** ក្នុងសូត្រនេះ បានពោលទុកពិស្តារហើយក្នុងសាមញ្ញផលសូត្រ ។ ប្រការដែលគួរពោលទាំងអស់ ក្នុងបទថា **មានចិត្តប្រកបដោយមេត្តា** ជាដើម លោកពោលទុកហើយ ក្នុងព្រហ្មវិហារកម្មដ្ឋានកថា ក្នុងវិសុទ្ធិមគ្គ ។

ពាក្យថា សេយ្យថាបិ ពលវា សង្ខធមោ ជាដើម មិនធ្លាប់មានក្នុងទីនេះ ។ បណ្តាបទទាំងនោះ បទថា ពលវា គឺ សម្បូរណ៍ដោយកម្លាំង ។

បទថា សង្ខធមោ គឺ អ្នកផ្លុំស័ង្ខ ។

បទថា អប្បកសិរេន បានដល់ មិនលំបាក គឺ មិនលំបាក ។ អធិប្បាយថា ពិតហើយ អ្នកផ្លុំស័ង្ខទុព្វលភាព សូម្បីផ្លុំស័ង្ខ ក៏មិនអាចឲ្យឮសំឡេងគ្រប់ទិសទាំង ៤ សំឡេងស័ង្ខរបស់គេមិនខ្វះខ្វាយទូទៅ តែសម្រាប់អ្នកមានកម្លាំងនឹងខ្វះខ្វាយទូទៅ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា **បុរសមានកម្លាំង** ជាដើម ។ កាលត្រាស់ថា មេត្តា ក្នុងបទថា មេត្តាយ ចេតោវិមុត្តិយា នេះ គួរទាំងឧបចារៈ ទាំងអប្បនា ។ តែកាលត្រាស់ថា ចេតោវិមុត្តិ គួរដល់អប្បនាតែម្យ៉ាង ។ បទថា **កម្មដែលធ្វើល្មមប្រមាណណា** មានន័យថា ដែលឈ្មោះថា កម្មដែលល្មមប្រមាណ លោកពោលថា ជាកាមាវចរកម្ម ។ កម្មដែលធ្វើរកប្រមាណមិនបាន លោកពោលថា ជារូបាវចរកម្ម និងអរូបាវចរកម្ម ។ លោកពោលថា កម្មដែលធ្វើរកប្រមាណមិនបាន ព្រោះកន្លងប្រមាណហើយ ធ្វើឲ្យចម្រើនដោយអំណាចការផ្សាយទៅក្នុងទិសដោយចំពោះ និងមិនចំពោះ ។

បទថា **កម្មនោះមិនសល់ មិនតាំងនៅក្នុងរូបាវចរកម្ម និងអរូបាវចរកម្ម** នោះ អធិប្បាយថា កម្មដែលជាកាមាវចរនោះ មិនឈប់ មិនតាំងនៅ ក្នុង

កម្មដែលជារូបាវចរ និងអរូបាវចរនោះ ។ លោកអធិប្បាយទុកយ៉ាងណា ។ អធិប្បាយថា កម្មជាកាមាវចរនោះ មិនអាចជាប់នៅ ឬតាំងនៅក្នុងរវាងកម្មដែលជារូបាវចរ និងអរូបាវចរនោះបាន ឬដើម្បីនឹងផ្សាយកម្មដែលជារូបាវចរ និងអរូបាវចរហើយរក្សាទុក ដល់ឱកាសរបស់ខ្លួនតាំងនៅបាន តាមការពិត កម្មដែលជារូបាវចរ និងអរូបាវចរនោះឯង នឹងផ្សាយទៅ ហើយរក្សាទុកនូវកាមាវចរកម្ម ដល់ឱកាសរបស់ខ្លួនតាំងនៅ ដូចអន្លង់ទឹកធំ ជោរជន់ទឹកបន្តិចបន្តួចចេញទៅ ក៏តាំងនៅ ដូច្នោះ រមែងហាមវិបាករបស់កម្មដែល ជាកាមាវចរនោះ នាំចូលកាន់ភាពជាអ្នកនៅរួមជាមួយព្រហ្មដោយខ្លួនឯង ដូច្នេះ ។

[១៨៦] បទថា **ភិក្ខុមានធម៌ជាគ្រឿងនៅយ៉ាងនេះ** គឺ មានធម៌គ្រឿងនៅ មានមេត្តាជាដើម យ៉ាងនេះ ។

[១៨៧] បទថា **ខ្ញុំព្រះអង្គទាំងពីរនាក់** សូមដល់ព្រះគោតមដ៏ចម្រើនជាសរណៈ នេះ ជាការដល់សរណៈលើកទីពីររបស់មាណពទាំងពីរនោះ ។ ក៏មាណពទាំងពីរនោះ ស្តាប់ **វាសេដ្ឋសូត្រ** ក្នុងមជ្ឈិមបណ្ណាសកៈហើយ ដល់សរណៈជាលើកដំបូង ស្តាប់ **តេវិជ្ជសូត្រ** នេះហើយ ដល់សរណៈជាលើកទីពីរ កន្លងទៅ ២-៣ ថ្ងៃ បានបព្វជ្ជាហើយបានឧបសម្បទា ក៏សម្រេច

-២០៧- អដ្ឋកថា តេវិជ្ជសូត្រ ទី ១៣

*ព្រះអរហត្ត ក្នុង* ***អគ្គញ្ញសូត្រ*** *ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយទាំងនោះ ដូច្នេះឯង ។*

ចប់ អដ្ឋកថា តេវិជ្ជសូត្រទី ១៣

ការពណ៌នាសេចក្តីនៃសីលក្ខន្ធវគ្គ

ដែលប្រដាប់ដោយព្រះសូត្រ ១៣ ក៏ចប់ស្រេចហើយដែរ ។

សុមង្គលវិលាសិនី ទីឃនិកាយ សីលក្ខន្ធវគ្គ ចប់

រួមព្រះសូត្រដែលមានក្នុងវគ្គនេះគឺ

ព្រហ្មជាលសូត្រ ១ សាម័ញ្ញផលសូត្រ ១ អម្ពដ្ឋសូត្រ ១ សោណទណ្ឌសូត្រ ១

កូដទន្តសូត្រ ១ មហាលិសូត្រ ១ ជាលិនីសូត្រ ១ មហាសីហនាទសូត្រ ១

ចោដ្ឋចាទសូត្រ ១ សុភសូត្រ ១ កេវដ្តសូត្រ ១ លោហិច្ចសូត្រ ១ តេវិជ្ជសូត្រ ១

រួមជា ១៣ សូត្រ ។

# នាមសប្បុរសជន

## ចូលរួមជាធម្មទាន

-ព្រះភិក្ខុ ធម្មប្បញ្ញោ វ៉ាន វឿន ................................ 150 $

-ព្រះភិក្ខុ អគ្គទិន្នោ នូវ ប៊ូវ៉ា ................................ ២០០.០០០ រៀល

-ឧបាសិកា ចាន់ បុប្ផាណា ព្រមទាំងបុត្រ ....................... 100 $

-ឧបាសិកា ពូ ហ៊ាង ................................ 50 $

-លោក ពៅ សុតូង អ្នកស្រី ស៊ឺ យក់លី ព្រមទាំងបុត្រ

ឧបាសិកា ពៅ ស៊ូវ៉ាង ................................ 50 $